ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- រឿងរ៉ាវនៃការឡើងកាន់អំណាចរបស់ខ្មែរក្រហមកាលពី៥០ឆ្នាំមុន
- អគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ផ្តល់ទីតាំងសម្រាប់កម្មវិធីពិនិត្យសុខភាពឥតគិតថ្លៃដល់ប្រជាពលរដ្ឋរស់នៅស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣០៤ ខែមេសា ឆ្នាំ២០២៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- រឿងរ៉ាវនៃការឡើងកាន់អំណាចរបស់ខ្មែរក្រហម កាលពី៥០ឆ្នាំមុន....................................១


### ផ្នែកឯកសារ


- សេ-អ៊ី-អា និងការបរាជ័យនៃការវាយកាន់...... ៤
- សៅ ថន៖ អាត្មោតមិនដែលឈ្នះអាចំប៉ាទេ...... ៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ឌុច សុភាព ហៅ ភេន៖ ពីជនបដិវត្តន៍ដ៏.......... ៩
- ឌីន ឆៃរ៉ែន ហៅ រ៉េន៖ យុទ្ធនារីបដិវត្តន៍ ......... ១៣
- កួយ សៀង៖ ករណីបាត់បង់ប្រុសកួយ សឿន .. ១៦
- អតីតអ្នកធ្លាប់ជាប់ឃុំឃាំងក្នុងគុកពពករវិល.... ១៨
- ហោម សាមិត្ត៖ អតីតអ្នកធ្វើការនៅមន្ទីរ .... ២៣
- យូ សារ៉េន៖ អតីតគ្រូពេទ្យ នៅតំបន់៣២ ......២៦
- គ្រូបង្រៀននៅស្រុកមេសាង ខេត្តព្រៃវែង......២៩
- ថ្ងៃជម្លៀស១៧ ខែមេសា ឆ្នាំ១៩៧៥ ......... ៣៤
- ម៉ី អ៊ិន រំឭករឿងរ៉ាវដែលបានកើតឡើងក្នុង..... ៣៧
- សុខ ជិន៖ បានរស់ជីវិតដោយសារ............. ៤០
- សូ ចំរើន៖ អ្នកដាំស្លនៅសហករណ៍............ ៤៣
- ជនជាតិដើមភាគតិចស្ទៀងរស់នៅភូមិក្ដុលលើ រៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ ឬបុណ្យភូមិ.... ៤៦
- អគារមរតកសង្គមរាស្ត្រនិយមសម្ដេចឪ- សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ផ្ដល់ទីតាំង............ ៥០
- បណ្ដាញស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន (CGTN) ពិភាក្សាជាមួយយុវជនកម្ពុជា........ ៥២


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- វេទិកាពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ.............. ៥៣
- សិស្សានុសិស្សនៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្ដុលដង្ហារ ធ្វើទស្សនកិច្ចសិក្សា ............... ៥៥




កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយប្រយុទ្ធនៅលើសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


- លោកអភិបាលនៃគណៈអភិបាលស្រុក និងមន្ត្រីរដ្ឋបាលស្រុក បរិច្ចាគសៀវភៅជូន ............ ៥៨


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ខ្ញុំគ្មានទិសវ័យជាមួយកូនចិញ្ចឹម ទាំងពីរនាក់.... ៦១



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** លី សុខឃាង, អេង សុខម៉េង, សុភ័ក្ត្រ ភាណា, មឿន ស្រីណុច, ផេង ពង្សរ៉ាស៊ី, ឡុង ដានី, ស្រេង លីដា, ជីម សុខគា, ឈុំ រ៉ា, ស្រ៊ាង លីហ៊ួរ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# រឿងរ៉ាវនៃការឡើងកាន់អំណាចរបស់ខ្មែរក្រហមកាលពី៥០ឆ្នាំមុន

*លី សុខឃាង*



*យោធាខ្មែរក្រហមដើរចូលទីក្រុងភ្នំពេញ បន្ទាប់ពីរំដោះបានពីរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានចារឹកទុកយ៉ាងជ្រាលជ្រៅនៅក្នុងដួងចិត្តនិងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងត្រូវបានពិភពលោកទាំងមូលចងចាំថាជាចំណុចរបត់ប្រកបដោយសោកនាដកម្ម ដែលជាការរអិលធ្លាក់ចូលទៅក្នុងមហន្តរាយដោយស្នាដៃមនុស្សផ្ទាល់។ ថ្ងៃនេះបានកំណត់ថាជាចំណុចចាប់ផ្ដើមនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលបានឆក់យកអាយុជីវិតប្រជាជនកម្ពុជាប្រមាណជាជិតពីរលាននាក់។ ក្នុងអំឡុងរយៈកាលនោះ ទ្រឹស្ដីនិងការបកស្រាយច្រើនរាប់មិនអស់បានលេចឡើងទាក់ទងនឹងខ្លឹមសាររបស់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងការឆ្លុះបញ្ចាំងនៃថ្ងៃនេះ ខ្ញុំសូមផ្ដល់នូវទស្សនមួយចំនួន ដើម្បីជាការចូលរួមដល់ការចងចាំនៃដំណើររយៈពេល៥០ឆ្នាំកន្លងមកដែលបានឆ្លងកាត់សង្គ្រាម អំពើប្រល័យពូជសាសន៍ ហើយនៅទីបំផុត យើងបានទទួលសន្តិភាព។

នៅក្នុងកម្រិតប្រទេសជាតិ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានចាត់ទុកថាជាមហាជ័យជម្នះលើរបបលន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ដោយសារតែរបបនេះបានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។



ប្រជាជនកម្ពុជាវិលត្រឡប់មករស់នៅស្រុកកំណើតវិញបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាប់ប្រជាជនកម្ពុជា ថ្ងៃនេះបានក្លាយជានិមិត្តរូបនៃភាពជាញជ័យ ដែលបានរង់ចាំជាយូរណាស់មកហើយ។

ភាពមោទកភាពយ៉ាងធំធេងត្រូវបានស្តែងឡើង តាមរយៈគំនិតមួយដែលថាកងទ័ពកម្ពុជាអាចវាយឈ្នះលើរបបមួយមានបំពាក់សព្វាវុធគ្រប់គ្រាន់ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ បើប្រៀបធៀបនឹងប្រទេសវៀតណាមវិញទៀតសោត ដែលទទួលបានជ័យជម្នះរយៈពេលពីរសប្តាហ៍ក្រោយមក គឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ជ័យជម្នះរបស់កម្ពុជានៅក្រោមចលនាបដិវត្តន៍របស់ខ្មែរក្រហម ត្រូវបានមើលឃើញថាមានភាពឆាប់រហ័សនិងប្រត្យក្សភាពជាង។ ប៉ុន្តែអ្វីដែលគួរទទួលស្គាល់ជាទូទៅនោះគឺថា ជ័យជម្នះនេះអាចនឹងមិនកើតឡើងបានឡើយ បើគ្មានការជួយគាំទ្រពីសំណាក់ប្រទេសចិន។

តែទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកម្រិតបុគ្គលម្នាក់ៗវិញ ការឡើងកាន់អំណាចរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បង្កឱ្យមានប្រតិកម្មចម្រុះគ្នា ដូចជា ភាពរីករាយ ភាពច្របូកច្របល់ និងភាពភ័យខ្លាច។ ភាពរីករាយកើតមានដោយសារតែសង្គ្រាមត្រូវបានបញ្ចប់ ប៉ុន្តែភាពមិនច្បាស់លាស់ក៏ចាប់ផ្តើមលេចឡើងបន្តិចម្តងៗ។ ប្រជាជនមិនដឹងថាតើកងទ័ពដែលទទួលបានជ័យជម្នះនឹងមានសណ្តានចិត្តល្អជាមួយខ្លួនឬអត់។ ភាពភ័យខ្លាចក៏បានខិតចូលមកដល់ដែរ ខណៈដែលប្រជាជនមានមន្ទិលថាតើអនាគតនឹងទៅជាយ៉ាងណា។ នៅថ្ងៃដដែលនេះ ការជម្លៀសប្រជាជនបានចាប់ផ្តើម ដោយបានបំផ្លាញ

ចោលនូវរបៀបរបបរស់នៅរាប់សតវត្សរ៍របស់ប្រជាជនកម្ពុជា និងបង្ខំប្រជាជនឱ្យធ្វើការនៅក្នុងសហករណ៍ នៅតាមតំបន់ជនបទៗ រចនាសម្ព័ន្ធសង្គមទាំងស្រុងត្រូវបានផ្លាស់ប្ដូរភ្លាមៗ។

ដោយហេតុនេះហើយ យើងគួរឆ្លុះបញ្ចាំងអំពីអតីតកាល នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលមិនគ្រាន់តែដើម្បីការចងចាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីការយល់ដឹងអំពីបច្ចុប្បន្ន និងជាមាគ៌ាបង្ហាញផ្លូវទៅកាន់អនាគតទៀតផង។ ខណៈដែលរឿងរ៉ាវជាច្រើនពីជនរងគ្រោះត្រូវបានចែករំលែកនាពេលកន្លងមក ការស្ដាប់រឿងរ៉ាវពីអតីតសមាជិកខ្មែរក្រហមពិតជាសំខាន់ដែរ។

អតីតទាហានខ្មែរក្រហមជាច្រើននាក់ ដែលត្រូវបានសួរនាំអំពីការចងចាំរបស់ខ្លួនអំពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបង្ហាញនូវទឹកចិត្តមួយ ដែលមិនសូវខុសប្លែកគ្នាអំពីប្រជាជននាពេលនោះដែរទេ។ អតីតទាហានខ្មែរក្រហមទាំងនោះ បានបង្ហាញនូវភាពធូរស្បើយ ដោយសារសង្គ្រាមបានបញ្ចប់ ហើយសង្ឃឹមថានឹងជួបជុំក្រុមគ្រួសាររបស់ខ្លួនសារជាថ្មីតែប៉ុណ្ណោះ ដែលមិនមែនជាការសង្ឃឹមចង់បានអំណាចឬបុណ្យស័ក្តិអ្វីទេ។

ស្ត្រីវ័យ៧៥ឆ្នាំ ហង់ ហ៊ុច ដែលធ្លាប់បម្រើការជាកងទ័ពខ្មែរក្រហម បានរំឭកអំពីទឹកចិត្តសប្បាយរីករាយ នៅពេលដែលខ្លួននិងយុទ្ធមិត្តរួមអាវុធបានវាយចូលក្នុងទីក្រុងភ្នំពេញដោយជោគជ័យ ហើយលែងភ័យព្រួយអំពីការវាយប្រហារតាមផ្លូវអាកាសតទៅទៀតហើយ។ ក្រោយមក ហ៊ុច ដែលមានកំណើតនៅក្នុងស្រុកបុរីជលសារនៃខេត្តតាកែវ ត្រូវបានបញ្ជូនឱ្យទៅធ្វើស្រែនៅកំពង់សោម។

ស្រដៀងគ្នានេះដែរ ណុប មុត ដែលមានវ័យ៧១ឆ្នាំ និងធ្លាប់ជាទាហានខ្មែរក្រហមនៅអន្លង់វែង បានចាត់ទុកថ្ងៃនេះថាជាថ្ងៃដ៏រីករាយ និងសន្តិភាព។ មុត បាននិយាយត្រង់ៗថា ខ្លួនមិនដែលមានសេចក្ដីប្រាថ្នាឡើងបុណ្យស័ក្តិអ្វីនោះទេ។ អ្វីដែល មុត ចង់បានពិតប្រាកដនោះ គឺការវិលត្រឡប់ទៅជួបជុំជាមួយឪពុកម្ដាយវិញ។ ជាការពិតណាស់ សេចក្ដីសង្ឃឹមបែបនេះទំនងជាមានភាពផ្ទុយស្រឡះពីមហិច្ឆតារបស់មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់។

នៅពេលសួរថាតើថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គួរត្រូវបានចងចាំថាជាការចាប់ផ្ដើមនៃមហាសោកនាដកម្មនៅប្រទេសកម្ពុជា មុត ដែលមានដើមកំណើតនៅក្នុងស្រុកត្រាំកក់នៃខេត្តតាកែវ ហាក់មានភាពស្ទាក់ស្ទើរ។ មុត បានបង្ហាញពីភាពមិនយល់ស្របក្នុងការទម្លាក់កំហុសគ្រប់យ៉ាងមកលើខ្មែរក្រហម ហើយយល់ថា ខ្មែរក្រហមតែងតែត្រូវបានចាត់ទុកថាជាអ្នកទទួលកំហុសតែម្នាក់គត់ នៅក្នុងប្រវត្តិសាស្ត្រ។

សូម្បីតែរយៈពេល៥០ឆ្នាំបានកន្លងផុតទៅហើយក៏ដោយ ការចងចាំអំពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហាក់នៅថ្មីៗនៅឡើយ បើទោះជាការបកស្រាយផ្សេងៗបន្តប្រែប្រួលជាប្រចាំក៏ដោយ។ រឿងរ៉ាវរបស់ មុត គឺគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ។ ប៉ុន្តែ ការពិតចំនួនបីយ៉ាងដែលយើងត្រូវតែទទួលស្គាល់។ ទីមួយគឺជាឯកសារ។ ឯកសារដើមរាប់សែនទំព័រដែលបន្សល់ទុកពីជំនាន់ខ្មែរក្រហមបានបង្ហាញច្បាស់អំពីបន្សុទ្ធកម្ម និងការសម្លាប់បែបរាលដាល និងជាប្រព័ន្ធ ដែលបានកើតមានឡើង។ ទីពីរគឺជាការស្វែងរកយុត្តិធម៌។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ជាទូទៅថាជាតុលាការខ្មែរក្រហម បានជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ទីបីគឺជារឿងរ៉ាវរបស់អ្នករស់រានមានជីវិត។ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតបានបន្តជួយយើងឱ្យលាតត្រដាងការពិតឱ្យបានកាន់តែទូលំទូលាយអំពីរបបខ្មែរក្រហម។

ការអប់រំយុវជននាពេលបច្ចុប្បន្ន និងមនុស្សជំនាន់បន្តបន្ទាប់ អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅតែមានសារសំខាន់ដដែល។ មានតែតាមរយៈការស្វែងយល់អំពីអតីតកាលទេ ទើបយើងអាចធានាបានថាអំពើឃោរឃៅបែបនេះនឹងមិនកើតឡើងទៀតនៅក្នុងប្រទេសកម្ពុជា និងទីកន្លែងផ្សេងៗទៀតនៅលើពិភពលោក។

# សេ-អ៊ី-អា និងការបរាជ័យនៃការវាយកាន់កាប់ស្រុកថ្មពួក និងស្វាយស៊ីសុផុន នៅក្នុងឆ្នាំ១៩៧៧

លី សុខឃាង



កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយប្រយុទ្ធនៅលើសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចម្លើយសារភាពរបស់ ធា ស អ៊ួម អនុលេខាកងវរសេនាតូច៨១៥ នៃកងវរសេនាធំ៨០ នៅក្នុងកងពលធំទី១ បានគូសបញ្ជាក់ពីការរៀបចំកម្លាំង ដើម្បីវាយប្រហារផ្តួលរំលំបដិវត្តន៍ខ្មែរក្រហម នៅក្នុងភូមិសាស្ត្រស្រុកថ្មពួក និងស្វាយស៊ីសុផុនដែលគ្រោងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧។ ចម្លើយសារភាពនេះបានបង្ហាញថា ការរៀបចំកសាងកម្លាំង និងការត្រៀមធ្វើសកម្មភាពមិនអាចធ្វើទៅបានដោយជោគជ័យ ដោយសារតែ ធា ស អ៊ួម ត្រូវបានចាប់ខ្លួន និងសួរចម្លើយដោយក្រុមអ្នកសួរចម្លើយឈ្មោះ ម៉ាក និង ឡាត់ ដែលមានចុះកាលបរិច្ឆេទថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៧។

នៅក្នុងចម្លើយសារភាព មនុស្សចំនួន១៧ នាក់ផ្សេងទៀត ដែលត្រូវបានឆ្លើយដាក់ថាបានពាក់ព័ន្ធនឹងផែនការក្បត់បដិវត្តន៍ សុទ្ធសឹងស្ថិតនៅក្នុងកងពលធំទី១ និងកងកម្លាំងមូលដ្ឋាននៅក្នុងតំបន់៥។ សំណេរខាងក្រោម បង្ហាញអំពីចម្លើយសារភាពរបស់ ធា ស អ៊ួម ដែលរៀបរាប់អំពីសាវតារដើមហេតុនៃប្រវត្តិនយោបាយ សកម្មភាពខ្សែបង្កប់របស់សេ-អ៊ី-អា ព្រមទាំងសកម្មភាពក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មុនពេលឈានដល់ដំណាក់កាលត្រៀមធ្វើសកម្មភាពវាយប្រហារ ដូចបានគ្រោងទុក។

ធា ស អ៊ួម មានស្រុកកំណើតនៅក្នុងភូមិខ្នា ឃុំក្រូចគ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលស្ថិតនៅក្នុងតំបន់១០៦។ នៅក្នុងឆ្នាំ១៩៦៤ អ៊ួម បានបួស

និងរៀនសូត្រនៅក្នុងសាលាបាលី នៃវត្តថ្មីៗ អាចារ្យ បឿន និង ឆន គឺជាអ្នកបង្រៀន អ៊ួម។ ក្រៅពីនេះ បឿន ក៏បានអប់រំ អ៊ួម អំពីផលវិបាកនៃចលនាបដិវត្តន៍ខ្មែរក្រហម ដោយបាននិយាយថា៖ «ខ្មែរក្រហមស៊ីអង្ករកំប៉ុង អនាគតខ្មែរទាល់តែពឹងអាមេរិក»។ បឿន ក៏បានពន្យល់ថា ការប្រយុទ្ធប្រឆាំងនឹងលទ្ធិកុម្មុយនីស្តមានន័យស្មើនឹងការការពារព្រះពុទ្ធសាសនាដែរ ដោយសារកុម្មុយនីស្តនឹងបំបិទព្រះពុទ្ធសាសនា។ ពីរឆ្នាំក្រោយមក បឿនបានបញ្ចូល អ៊ួម ឱ្យបម្រើការជាភ្នាក់ងារសេ-អ៊ី-អា ដែលមានភារកិច្ចបំផុសប្រជាជនឱ្យស្អប់ខ្មែរក្រហម តាមដានសភាពការណ៍ខ្មែរក្រហម និងកសាងកម្លាំងសេ-អ៊ី-អា នៅតាមមូលដ្ឋាន។ ជារួម ខ្សែរយៈដឹកនាំសេ-អ៊ី-អា គឺលោកស័ក្តិ៥ សេក សំអៀត ដែលក៏ជាចៅហ្វាយខេត្តបាត់ដំបងផង។ នៅក្នុងឆ្នាំ១៩៦៦ បឿន បានចាត់តាំងឱ្យ អ៊ួម និង ប៊ុង សឹក និងកសាងកម្លាំងសេ-អ៊ី-អា នៅតាមស្រុកកំណើតរៀងៗខ្លួន។

រយៈពេលបីឆ្នាំក្រោយមក អ៊ួមបានកសាងកម្លាំងសេ-អ៊ី-អាបានចំនួន៥នាក់រួមមាន៖ រី, លីវ, លាប, យឿង និង ឌី ដែលសុទ្ធសឹងជាកសិករនៅក្នុងខេត្តសៀមរាប។ នៅក្នុងឆ្នាំ១៩៧០ បឿន បានដាក់ផែនការឱ្យ អ៊ួម បំផុសប្រជាជនមិនឱ្យឧបត្ថម្ភដល់កងទ័ពបដិវត្តន៍ និងរៀបចំកម្លាំងសេ-អ៊ី-អាបង្កប់ក្នុងជួរកងទ័ពសារជាថ្មី។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៣ អ៊ួម យ៉ុក ដេង និង ស្រួចបានដឹកនាំយុទ្ធជនឱ្យរត់បោលសមរភូមិព្រៃចាស់ចំនួនពីរដង ដែលនាំឱ្យខ្មាំងវាយយកសមរភូមិនោះបានវិញ។

អ៊ួម និងប៊ុងបន្តរាយការណ៍ជូនបឿនរហូតដល់ឆ្នាំ១៩៧៣។ នៅពាក់កណ្ដាលឆ្នាំដដែល អ៊ួម ត្រូវបានចាត់តាំងឱ្យបង្កប់ខ្លួន និងធ្វើសកម្មភាពនៅក្នុងជួរកងទ័ព ព្រមទាំងបានទាក់ទងជាមួយ ស្រួច ដែលបម្រើការខាងសេដ្ឋកិច្ចតំបន់៥ និង ដេង ដែលបម្រើការនៅក្នុងកងអនុសេនាធំ។ ដេង ក៏ត្រូវបានអង្គការកម្ទេច នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៤។

បន្ទាប់ពីជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អ៊ួម ក៏បានចាត់តាំងឱ្យ តង់ ថាវ ធឿត ព្រិច និង យួត ដែលជាកម្លាំងកសាងថ្មីនៅក្នុងឆ្នាំដដែល ដើម្បីដើរប្រមូលសមាសភាពអ្នក១៧ មេសាចំនួន១២០នាក់ឱ្យចូលក្នុងអង្គភាព៣៨១៥។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ អ៊ួម ក៏បានទទួលផែនការចុងក្រោយពីយិត និង ឈឿន ហៅ ឈន ដើម្បីរើសទាហានកុម្មង់ដូរចាស់ និងស្វាយត្រាណឱ្យចូលក្នុងកងពលធំទី១ និងទី២ រៀបចំកន្លែងលាក់ស្បៀងនិងអាវុធ និងចាត់តាំងឱ្យកម្លាំងដែលទើបកសាងបានរួមជាមួយសមាសភាពថ្មីឱ្យធ្វើការនៅទល់ដែនសៀម សម្រាប់ជាកម្លាំងបង្អែក។

មេបញ្ជាការ ឈន នៃកងពលធំទី១ និងកងកម្លាំងមូលដ្ឋាននៅក្នុងតំបន់៥ ទទួលបន្ទុកអនុវត្តផែនការវាយប្រហារ ចាប់ពីស្រុកថ្មពួក រហូតដល់ខេត្តឧត្ដរមានជ័យ ខណៈដែល អ៊ួម និង យ៉ិត ក៏បានដឹកនាំកងវរសេនាធំដែរ។ កងមូលដ្ឋានតំបន់៥ ទទួលមុខសញ្ញាវាយលុកនៅតាមជាយស្រុកថ្មពួក និងតភ្ជាប់ជាមួយកងពលធំទី១ ដែលស្ថិតនៅក្បែរជួរភ្នំដងរែក។ ការវាយលុក និងកាន់កាប់ស្រុកថ្មពួក និងស្វាយស៊ីសុផុនគឺជាការចាំបាច់ ដើម្បីបម្រើជាមូលដ្ឋានបង្អែក។ មូលដ្ឋានទាំងពីរនេះមានស្រូវច្រើន។ ក្នុងករណីដែលបរាជ័យ កងកម្លាំងត្រូវជម្លៀសប្រជាជន និងកងទ័ពឱ្យធ្វើដំណើរឆ្ពោះទៅតំបន់ព្រំដែនសៀម។

អ៊ួម បន្តភ្ជាប់ខ្សែបណ្ដាញជាមួយ យ៉ិត ដែលជាខ្សែសេ-អ៊ី-អារបស់នៅ និង ឈន។ អ្នកទាំងអស់ទាក់ទងគ្នារហូតដល់អង្គការចាប់ខ្លួននៅខែកក្កដា ឆ្នាំ១៩៧៧ ដែលមានរយៈពេលពីរខែមុនពេលអនុវត្តផែនការ (ដែលគ្រោងនៅខែកញ្ញា ឆ្នាំ១៩៧៧)។ នៅក្នុងចម្លើយសារភាព ធាស អ៊ួម បានចុះហត្ថលេខា និងមានចុះកាលបរិច្ឆេទថ្ងៃទី១១ខែកក្កដា ឆ្នាំ១៩៧៧។ អ៊ួម ត្រូវបានសួរចម្លើយដោយមនុស្សពីរនាក់ គឺ មាក និង ឡាត់ ដែលមានកាលបរិច្ឆេទដូចគ្នាដែរ។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពលេខ J00១៧៩។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ធាស អ៊ួម ពិតប្រាកដបុយ៉ាងណានោះទេ។***

# សៅ ផន ៖ អាត្លោតមិនដែលឈ្នះអាចំប៉ាទេ

**លី សុខឃាង**



*កងចល័តក្នុងរបបខ្មែរក្រហមកំពុងភ្ជួរស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

«អាត្លោតមិនដែលឈ្នះអាចំប៉ាទេ» នេះបើយោងតាមសម្តីនៅក្នុងចម្លើយសារភាពរបស់ សៅ ផន ដែលជាយុវជនខ្មែរកម្ពុជាក្រោម ហើយយុវជនរូបនេះត្រូវបានចាប់ខ្លួននៅក្នុងជំនាន់ខ្មែរក្រហម។

តាមន័យត្រង់ ប្រជាជនកម្ពុជាច្រើនតែពណ៌នាឬដាក់ឈ្មោះគោ ទឹមរបស់ខ្លួនស្របទៅតាមពណ៌សម្បុរ ឬឈ្មោះរណ្តំជូនគ្នា ដើម្បីងាយស្រួលហៅឈ្មោះ។ គោសម្រាប់ទឹមសម្បុរត្លោតត្រូវបានហៅឈ្មោះថា«អាត្លោត» ហើយគោទឹមម្ខាងទៀតច្រើនដាក់ឈ្មោះថា «អាចំប៉ា» ដែលជាឈ្មោះពីររណ្តំគ្នាឬជាគូរនឹងគ្នា។ «អាត្លោត និង «អាចំប៉ា» តែងតែត្រូវបានដាក់ទឹម ដើម្បីប្រើប្រាស់ជាកម្លាំងអូសទាញក្នុងការងារកសិកម្មរបស់កសិករ។

ចំណែកឯនៅក្នុងបរិបទនៃចម្លើយសារភាពនេះវិញ ផន បានប្រើការនិយាយបែបន័យប្រៀបធៀបថា«អាត្លោត» សំដៅលើរបបកម្ពុជាប្រជាធិបតេយ្យឬខ្មែរក្រហម ហើយ «អាចំប៉ា» សំដៅលើប្រទេសវៀតណាម។ សៅ ផន ហៅ សាន ជឿជាក់ថា «អាត្លោត» ខ្មែរក្រហមមិនអាចមានឱកាសឈ្នះ«អាចំប៉ា» វៀតណាមឡើយ។ ដូច្នេះហើយ ផន បានចូលរួមយ៉ាងសកម្មក្នុងកិច្ចខំប្រឹងប្រែង ដើម្បីផ្តួលរំលំខ្មែរក្រហម។ ខាងក្រោមនេះគឺសេចក្តីសង្ខេបពីចម្លើយសារភាពរបស់ សៅ ផន ហៅ សាន។

ផនមានដើមកំណើតនៅភូមិទួលរមែង ឃុំអាងទឹក ស្រុកស្វាយទង ខេត្តមាត់ជ្រូក នៃទឹកដីកម្ពុជាក្រោម។

ថន មានឪពុកឈ្មោះ សៅ យែម (ស្លាប់) និង ម្តាយឈ្មោះ មុំ ដែលប្រកបមុខរបរធ្វើស្រែចម្ការ។ ថន មានបងប្អូនបីនាក់ (ប្រុសពីរនាក់ និងស្រីមួយនាក់)។ ថន បានប្រកបមុខរបរលក់ការ៉េម នៅក្នុងទីរួមខេត្តស្វាយរៀង រយៈពេលបីខែ នៅក្នុងឆ្នាំ១៩៦៨។ មួយឆ្នាំក្រោយមក ថន ក៏បានសុំម្តាយចូលបម្រើក្នុងជួរកងទ័ពវៀតកុង នៅភ្នំវែង ប្រទេសវៀតណាម។

បន្ទាប់ពីរដ្ឋប្រហារនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ កងទ័ពវៀតណាមបានចូលមកម្តុំភ្នំដិន ស្រុកគិរីវង្ស ខេត្តតាកែវ និងបន្តឆ្ពោះទៅកាន់ភ្នំម្រោមទៀត។ មេបញ្ជាការវៀតណាមរួមមាន៖ លោកស័ក្តិប្រាំ ប៉ាវ បាវ និងលោកស័ក្តិបួន ចាវ ដោក បានប្រាប់ ថន, នី, និង តួ ដែលជាខ្មែរកម្ពុជាក្រោមដូចគ្នា ឱ្យអប់រំបំពាក់បំប៉នមនោគមវិជ្ជាបង្កប់ស៊ីរូងផ្ទៃក្នុងជួរបដិវត្តន៍ ដើម្បីកម្ទេចបដិវត្តន៍ ក្នុងខ្លឹមសារថា៖ «១) អប់រំថាទ័ពយើងត្រូវវាយអាធំវគី ២) អប់រំថាទ័ពយើងត្រូវវាយអាលន់ នល់ ៣) អប់រំថាទ័ពយើងត្រូវវាយខ្មែរក្រហម ៤) អប់រំថាទ័ពយើងត្រូវវាយប្រទេសលាវទៀត»។ ថន បានឆ្លើយទៀតថា គោលបំណងរបស់វៀតណាម គឺត្រូវវាយកាន់កាប់និងប្រែក្លាយប្រទេសទាំងនេះឱ្យទៅជាប្រទេសតែមួយ នៅក្រោមការគ្រប់គ្រងរបស់វៀតណាម។

មួយឆ្នាំក្រោយមក (នៅក្នុងឆ្នាំ១៩៧១) ថន បានរត់ចេញពីប្រទេសវៀតណាម ដោយយកមកតាមខ្លួននូវកាំភ្លើងអាការមួយដើម និងបេ-៤០មួយដើមដែរ។ ថន បានចាប់ផ្តើមបម្រើការជាឈ្លបឃុំមានជ័យ នៅក្រោមការគ្រប់គ្រងរបស់ ង្លួន អស់រយៈពេល៦ខែ មុនពេលក្លាយជាកងទ័ពស្រុកឈូក និងក្រោយមក ក្លាយជាកងទ័ពតំបន់។ ថនបានរៀបរាប់ថាខ្លួនអាចក្តាប់ចំណុចខ្សោយ និងចំណុចខ្លាំងរបស់កងទ័ពតំបន់ និងរាយការណ៍ជូន យ៉ាន នៅក្នុងខែឧសភា ឆ្នាំ១៩៧៣ ថា កងទ័ពតំបន់៣៥ត្រូវបានបញ្ជូនទៅសមរភូមិមុខអស់ហើយ ព្រមទាំងប្រឈមមុខនឹងការខ្វះស្បៀង និងគ្រាប់រំសេវជាខ្លាំង។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ ថនបានផ្លាស់ទៅបម្រើការក្នុងកងពលទី៣ នៅក្រោមការដឹកនាំបញ្ជារបស់មុត (មាស មុត) ដែលមានមូលដ្ឋាននៅ «រាម» នៃក្រុងកំពង់សោម។ ពីរខែបន្ទាប់មក ថន បានជួបជាមួយ វ៉េត និង យ៉ាន ដែលជាខ្សែចាត់តាំងបង្កប់របស់វៀតណាមតាំងពីឆ្នាំ១៩៧១ ក្នុងខណៈដែលខ្លួនដេកសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យក្រុងកំពង់សោម។ ថន បានរៀបរាប់ពីការកសាងកម្លាំងបានចំនួនពីរនាក់ តុប មុិន និង រិន ក្នុងរយៈពេលបួនឆ្នាំកន្លងមក និងមិនបានកសាងកម្លាំងបន្ថែមនៅ «រាម» ទេ ដោយសារតែមានការដាក់ចេញវិន័យយ៉ាងតឹងរ៉ឹង និងការតាមដានខ្លាំងយ៉ាងខ្លាំងក្លា។ ថនបានចលនា និងកសាងទំនុកចិត្តបន្ថែមឱ្យ រិន ថា៖ «មិត្តរិនឯងមើលអាគ្មោតមិនដែលឈ្នះអាចំប៉ាទេ គឺកងទ័ពខ្មែរពុំដែលឈ្នះកងទ័ពយួន»។ ថន ក៏បានរៀបរាប់ទៀតថា រិន មិនឆ្លើយតបអ្វីទេ ប៉ុន្តែនៅស្ងៀមហើយសើច។

ថន បានបន្តជួបជាមួយនារីពេទ្យ រឿន នៅពេលដែលខ្លួនបានធ្វើជាលេសដើម្បីបានដេកសម្រាកព្យាបាលនៅពេទ្យ១៧ មេសា ក្នុងក្រុងភ្នំពេញ។ អ្នកទាំងពីរបានថ្លែងអំពីការដាច់ខ្សែរយៈបង្កប់របស់ខ្លួន ប៉ុន្តែត្រូវស្វែងរកវិធីដើម្បីតភ្ជាប់ឡើងវិញ។

រឿនបានប្រាប់ ថនឱ្យប្រើសញ្ញា «ឡេវអាវពណ៌ក្រហម» នៅលើអាវរបស់ខ្លួនដែលអាចដេរនៅលើបីកន្លែងដើម្បីធ្វើការទាក់ទងរកខ្សែរយៈគឺ៖ (១) ឡេវអាវពណ៌ក្រហមអាចដេរដាក់នៅលើគល់ «ក» ឬខាងលើបង្អស់, (២) ឡេវអាវពណ៌ក្រហមអាចដេរដាក់នៅខាងក្រោមបង្អស់, ឬ (៣) ឡេវអាវពណ៌ក្រហមអាចដេរដាក់នៅលើហោប៉ៅអាវខាងស្តាំក៏បាន ឬខាងឆ្វេងក៏បាន។ ថនបានជួប យ៉ាន នៅភ្នំក្រោល ក្នុងឃុំមានជ័យ ដូចគោលបំណង ហើយបានរាយការណ៍ឱ្យគាត់ថា ខ្លួនបានចលនា និងចាត់តាំងនារី ចាន់ និង ខុន ឱ្យបន្តសកម្មភាព ព្រមទាំងជួប វ៉ុត នៅក្រុងតាកែវ។

ថនបានឆ្លើយសារភាពទៀតថា ការផ្ទុះអាវុធនឹងត្រូវធ្វើឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៧។ ប៉ុន្តែបើផែនការដំបូងនេះបរាជ័យ ការផ្ទុះអាវុធនឹងកើតឡើងម្តងទៀតនៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ដោយ

មានការគាំទ្រពីកងទ័ពវៀតណាមពីមុខសញ្ញា «ផ្លូវលក និងតន់ហាន់»។ កាំភ្លើងបេ-៤០ និងអាការចំនួន៥០ដើមបានកប់លាក់ទុកនៅឯភ្នំក្រោល និងនៅកំពត។ ថនបានបញ្ជាក់ថា ករណីបែកការណ៍ហើយអង្គការចាប់មិនបានទេ ក្រុមរបស់ខ្លួនត្រូវរត់ចូលក្នុងប្រទេសវៀតណាម ឬប្រទេសថៃ ឬចូលព្រៃសិន។

ចម្លើយសារភាពរបស់ ថន បានចង្អុលបង្ហាញឈ្មោះមនុស្សចំនួន១០នាក់ ក្នុងចំណោមមនុស្ស១២នាក់ ដែលបានសរសេរនៅក្នុងវង់ក្រចកថា៖ «មិនទាន់ចាប់ខ្លួន» ចំណែកម្នាក់ទៀតបញ្ជាក់ថាបាន «ស្លាប់» ហើយ។ មានតែ «ថន» ម្នាក់គត់ ដែលត្រូវបានចាប់ខ្លួនសួរចម្លើយ ព្រមទាំងឆ្លើយរៀបរាប់ឈ្មោះដែលជាប់ពាក់ព័ន្ធចំនួន១១នាក់ខាងលើ។

ផ្នែកចុងក្រោយបង្អស់នៃចម្លើយសារភាពរបស់ ថន មានចំណារដោយដៃថា៖ «ចម្លើយទាក់ទងកងទ័ពនិងពេទ្យខាងអង្គការ។ ៥/១២។ ភាគនិរតី (ហត្ថលេខា) ម៉ុក»។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពលេខ J00៣២៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់សៅ ថន ពិតប្រាកដ ឬយ៉ាងណានោះទេ។**



កងចល័តនៅក្នុងរបបខ្មែរក្រហមកំពុងភ្ជួរស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឌុច សុភាព ហៅ ភេន ៖ ពីជនបដិវត្តន៍ដ៏ស្មោះត្រង់ ក្លាយទៅជាអ្នកទោសនយោបាយ

មីន សាណាស់

ខ្ញុំឈ្មោះ ឌុច សុភាព ហៅ ភេន អាយុ៥០ឆ្នាំ (២០០៨) មានទីកន្លែងកំណើត និងរស់នៅបច្ចុប្បន្នក្នុងភូមិទួល ឃុំដំរិល ស្រុកអូររាំងឪ ខេត្តកំពង់ចាម (សព្វថ្ងៃដូរមកខេត្តត្បូងឃ្មុំ)។ ខ្ញុំមានឪពុកឈ្មោះ ឌុច និងម្ដាយឈ្មោះ ដៃ គាត់ទាំងពីររស់នៅក្នុងសង្កាត់ចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនចំនួន ៨ នាក់ ក្នុងនោះមានប្រុសចំនួន៣នាក់ និង ស្រីចំនួន៥នាក់។ ខ្ញុំជាកូនស្រីទី៤ក្នុងគ្រួសារ។ ឪពុកម្ដាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ និងមានវណ្ណៈភាពជាកសិករកណ្ដាលថ្នាក់ក្រោម។ ដោយសារតែឪពុកម្ដាយរបស់ខ្ញុំស្រឡាញ់ និងជឿជាក់លើចលនាបដិវត្តន៍ ទើបគាត់ឱ្យបងប្អូនរបស់ខ្ញុំចំនួន៥នាក់ ចូលបម្រើអង្គការបដិវត្តន៍។ ដំបូងបង្អស់គឺបងប្រុសច្បងរបស់ខ្ញុំឈ្មោះ ឌុច កន បានចូលបដិវត្តន៍ រួចក្រោយៗមកទៀត ក៏បាននាំប្អូនៗចូលធ្វើការស្ម័គ្រចិត្តតាមភូមិឃុំជាបន្តបន្ទាប់។ ឪពុកម្ដាយរបស់ខ្ញុំតែងតែណែនាំកូនៗឱ្យខ្ញុំប្រឹងប្រែងធ្វើការងារ កសាងខ្លួនឱ្យបានល្អ និងត្រូវស្មោះត្រង់ចំពោះអង្គការ។

រំឭកកាលពីក្មេង ខ្ញុំមានអាយុប្រហែលជា១៣ឆ្នាំ ខ្ញុំបានចូលរៀនសាលាក្នុងភូមិកំណើត។ ខ្ញុំរៀន បានត្រឹមថ្នាក់ទី១២ចាស់ សាលាក៏ត្រូវបិទព្រោះគ្មានគ្រូមកបង្រៀន។ ខ្ញុំរៀនបានត្រឹមចេះតិចតួច គ្រាន់តែអាចសរសេរអក្សរបាន និងអាចអានអក្សរ។ មុនឆ្នាំ១៩៧០ បងៗរបស់ខ្ញុំបានស្ម័គ្រចិត្តចូលរួមជាមួយកងទ័ពបដិវត្តន៍ ក៏ព្រោះតែស្រឡាញ់អង្គការ និងមួយទៀតដោយសារស្ថានភាពក្នុងគ្រួសារមានការលំបាក និងក្រីក្រខ្វះមុខខ្វះក្រោយ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីដំណែង។ បន្ទាប់ពីហេតុការណ៍រដ្ឋប្រហារភ្លាមៗ អ្នកស្រុកភូមិរបស់ខ្ញុំបាននាំគ្នាឡើងទៅធ្វើបាតុកម្ម ទាមទារឱ្យសម្ដេចព្រះ នរោត្តម សីហនុវិលត្រឡប់មកកាន់ប្រទេស និងចូលកាន់ដំណែងវិញ។ ប៉ុន្តែកម្លាំងបាតុករដែលភាគច្រើនជាយុវជនយុវនារី ក៏ត្រូវទាហាន លន់ នល់ ចុះបង្ក្រាបបង្កឱ្យមានអ្នកស្លាប់ និងរបួសជាច្រើន។ ការប៉ះទង្គិចរវាងកម្លាំងប្រជាជន និងទាហាន លន់ នល់ បានបញ្ជោះកម្លាំងអ្នកស្រុកអ្នកភូមិឱ្យរត់ចូលក្នុងចលនាខ្មែរក្រហមកាន់តែច្រើន និងជាហេតុនាំឱ្យខ្មែរក្រហមមានឱកាសចូលគ្រប់គ្រងភូមិឃុំជាច្រើននៅទូទាំងប្រទេស។

ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំបានចូលបម្រើក្នុងជួរបដិវត្តន៍នៅភូមិទួល សង្កាត់ដំរិល ស្រុកអូររាំងឪ ដោយមានសមមិត្តឈឿន មានតួនាទីជាគណៈស្រុកកោះសូទិន និង ឈាង ជាប្រធានសេដ្ឋកិច្ចស្រុកកោះសូទិនជាអ្នកនាំចូល។ មូលហេតុនៃការចូលបដិវត្តន៍របស់ខ្ញុំ គឺអង្គការឃើញថាខ្ញុំយល់ពីមាគ៌ាបក្ស និងអាចចូលរួមបម្រើបដិវត្តន៍បានល្អ។ បន្ទាប់មកទៀតអង្គការក៏ចាត់តាំងឱ្យខ្ញុំទៅរៀនវគ្គបណ្ដុះបណ្ដាលជំនាញពេទ្យរយៈពេល៣ខែ ស្ថិតនៅក្នុងឃុំដំរិលដដែល។ នៅពេលនោះអង្គការគ្រាន់តែបង្រៀនឱ្យខ្ញុំចេះចាក់ថ្នាំ និង មើលស្ថានភាពអ្នកជំងឺ ហើយវិភាគទៅតាមប្រភេទជំងឺនីមួយៗតែប៉ុណ្ណោះ។ រៀនចប់

រយៈពេល៣ខែ អង្គការបញ្ជូនខ្ញុំឱ្យមកធ្វើជាពេទ្យប្រចាំឃុំដំរិលផ្ទាល់ ព្រមទាំងមានបងប្អូនជាអ្នកគ្រប់គ្រងផ្នែកពេទ្យ។ ស្ថិតនៅឃុំដំរិល គឺអង្គការយកអ្នកគ្រប់គ្រងថ្មីមកពីខាងស្រុកកោះសូទិន ឈ្មោះ ណារិន (ប្រុស) ឱ្យមកកាន់តួនាទីជាគណៈឃុំ។ កាលនោះ ខ្ញុំរៀនមិនបានចេះស្ទីប៉ុន្មានទេ តែដោយសាររៀនបណ្តើរអនុវត្តបណ្តើរក៏អាចចាក់ថ្នាំជូនប្រជាជនក្នុងភូមិឃុំបាន។ ខ្ញុំធ្វើជាពេទ្យក្នុងឃុំបានរយៈពេល៤ខែ អង្គការក៏ផ្លាស់ឱ្យទៅខាងកងនេសាទប្រចាំស្រុកកោះសូទិន។ ហេតុនេះខ្ញុំត្រូវបន្ថែមតួនាទីថ្មីមួយទៀត គឺត្រូវជួយលក់ត្រីនៅភូមិរកាកោង ស្រុកកោះសូទិន។ ក្នុងឆ្នាំ១៩៧២ គឺស្រុកភូមិនៅចាយលុយរូបគោនៅឡើយ។ លុយដែលបានមកពីការលក់ត្រី គឺត្រូវយកទៅទិញថ្នាំទុកប្រើប្រាស់នៅតាមអង្គភាពផ្សេងៗ។

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៣ ខ្ញុំបានចូលក្នុងអង្គភាពយុវកកប្រចាំនៅមន្ទីរយុវជនស្រុកកោះសូទិន។ អ្នកខ្ទេសនាមឱ្យខ្ញុំចូលក្នុងអង្គភាពយុវកក គឺមានឈ្មោះសមមិត្ត នី។ ចំណែកអ្នកទទួលស្គាល់ គឺមានឈ្មោះសមមិត្ត សែម។ ដើមហេតុដែលនាំឱ្យខ្ញុំចូលក្នុងអង្គភាពយុវកក ពីព្រោះខ្ញុំមានប្រវត្តិរូបល្អ សកម្មការងារ និងអាចឱ្យមកធ្វើជាដៃស្តាំរបស់បក្សបាន។ ក្រោយពីចូលក្នុងអង្គភាពយុវកករួច ខ្ញុំនៅតែធ្វើជាប្រធានក្រុមនេសាទសម្រាប់ផ្គត់ផ្គង់ស្រុកកោះសូទិន ហើយត្រូវដឹកនាំកងចល័តផ្នែកនារីៗ ខាងនេសាទត្រីទៅគ្រប់ទីកន្លែងទាំងអស់ដូចជាទៅតាមស្ទឹង និងព្រែកជាច្រើន។ ក្រៅពីប្រធានក្រុមនេសាទ ថ្នាក់លើចាត់តាំងឱ្យខ្ញុំកាន់ផ្នែកនីសារ និងហេរញ្ញិក ព្រោះពីឆ្នាំ១៩៧០ដល់១៩៧៥ អង្គការនៅធ្វើការ ដោះដូរទំនិញនៅឡើយ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ អង្គការបានដកខ្ញុំឱ្យទៅធ្វើការងារផ្នែកកងទ័ព ស្ថិតនៅវរសេនាតូច និងត្រូវចូលហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ និង យុទ្ធវិធីរយៈពេល៦ខែ ស្ថិតនៅទីតាំងវត្តធម្មកេរប្រាសាទក្នុងភូមិប្រាសាទ (បច្ចុប្បន្ននៅក្នុងឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ)។ គោលបំណងរបស់អង្គការគឺដើម្បីឱ្យខ្ញុំត្រៀមខ្លួន និងត្រូវចេញទៅវាយប្រយុទ្ធគ្នានៅសមរភូមិឯទីក្រុងភ្នំពេញ។ ក្នុងរយៈពេល៦ខែ កាលនោះ ខ្ញុំត្រូវហាត់រៀនដោយខ្លួនឯង៣ខែ និង ៣ខែទៀតគឺមានគ្រូបង្រៀនឈ្មោះ ហុប រ៉ូវ មកបង្ហាត់បន្ថែមចំពោះកូនសិស្សចំនួនបីវរសេនាតូចៗ ក្រោយពីរៀនចប់ អាចជាភ័ព្វសំណាងសម្រាប់ខ្ញុំ ថ្ងៃដែលត្រូវធ្វើដំណើរឡើងទៅប្រយុទ្ធនៅទីក្រុងភ្នំពេញ បែរជាថ្ងៃដែលកងកម្លាំងខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរបានទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីអង្គការទទួលបានជ័យជម្នះនៅក្នុងឆ្នាំ១៩៧៥ កងវរសេនាតូច និង ខ្ញុំត្រូវអង្គការផ្លាស់ប្តូរទៅធ្វើការនៅពាណិជ្ជកម្ម កំពង់សោម។ ខ្ញុំនៅតែមានតួនាទីជាប្រធានក្រុមដដែល ប៉ុន្តែក៏ត្រូវធ្វើការលីសែងទំនិញពីរថភ្លើងបញ្ជូនចូលកប៉ាល់ជនជាតិចិននៅឯកំពង់ផែ សម្រាប់នាំចេញក្រៅប្រទេសដូចជា អង្ករ គ្រាប់កាហ្វេ គ្រាប់សណ្តែកគ្រប់មុខ និងអំបិល។ ចំណែកទំនិញដែលនាំចូលមកវិញពីប្រទេសចិនគឺមានដូចជាថ្នាំពេទ្យ គ្រឿងម៉ាស៊ីន ដែលភាគច្រើនជាប្រភេទគ្រឿងដែក។ ក្រុមខ្ញុំធ្វើការនៅពាណិជ្ជកម្មកំពង់សោមបានរយៈពេលមួយឆ្នាំក៏ត្រូវផ្លាស់ទៅកាន់ខេត្តកំពត ផ្នែកប្រមូលអំបិលរយៈពេលមួយឆ្នាំទៀត។ ការងាររបស់ខ្ញុំគឺចាំប្រមូលអំបិលច្រកបេ និងលីសែងដាក់ចូលឡាន។ ការងារក្នុងការដ្ឋានអំបិលគឺត្រូវធ្វើការជាប់រហូត គ្មានពេលឈប់សម្រាកក្នុងនាមជាប្រធានក្រុម ព្រោះមានវេនយប់ និង វេនថ្ងៃ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការដកឱ្យមករស់នៅតំបន់ផ្សារចាស់ ទីក្រុងភ្នំពេញវិញ។ នៅទីក្រុងភ្នំពេញ ខ្ញុំចូលធ្វើការក្នុងក្រសួងពាណិជ្ជកម្មក្រៅប្រទេសដែលមានឈ្មោះអ៊ំញ៉ែម ជាប្រធានក្រសួងពាណិជ្ជកម្ម។ ចំណែកតួនាទីរបស់ខ្ញុំ គឺចាំទទួលភ្ញៀវបរទេសដែលចុះពីយន្តហោះ និងជូនភ្ញៀវទាំងនោះទៅទស្សនាក្រុមសិល្បៈ។ រាល់ពេលមានភ្ញៀវបរទេសមក ប៉ុល ពត, ខៀវ សំផន និង នួន ជា ផ្លាស់វេនគ្នាមក


59

I_ អំពីផ្ទាល់ខ្លួន

១ . ឈ្មោះដើម ឌុច ភេន ...... ឈ្មោះក្នុងបដិវត្ត ឌុច សុភាព .....

២ . ទីកន្លែង ថ្ងៃខែ ឆ្នាំកំណើត ......

៣ . ភេទស្រី ឬប្រុស ? ជនជាតិ ......

៤ . មានគ្រួសារ ឬនៅលីវ ? ...... លីវ ......

៥ . របរ រកស៊ី និងវណ្ណៈភាពដើមមុនចូលបដិវត្ត ? ......

៦ . របរ រកស៊ី និងវណ្ណៈភាពក្រោយចូលបដិវត្ត ? ......

៧ . មានចូលអង្គការនយោបាយណាទេ មុនចូលធ្វើបដិវត្ត ? មូលហេតុដែលនាំឱ្យ អង្គការនយោបាយនោះ ? ......

*ជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ឌុច ភេន ហៅ ឌុច សុភាព (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទទួល។ ភ្ញៀវបរទេសដែលមកទស្សនកិច្ចច្រើនជាង គេក្នុងរបបខ្មែរក្រហម គឺប្រទេសចិន ព្រោះកាល នោះជនជាតិចិនគឺជាអ្នកជួយក្នុងផ្នែកបច្ចេកទេស គ្រឿងម៉ាស៊ីន ឬ ការដឹកនាំធ្វើការងារផ្សេងៗ។ ក្រៅពីនោះក៏មានប្រទេសយូហ្គោស្លាវី អាឡឺម៉ង់ កូរ៉េ និង ទីម័រ។ ក្នុងរយៈពេលមួយខែ យ៉ាងហោច ណាស់ក៏អាចមានភ្ញៀវមកទស្សនកិច្ចពីពីរទៅបី ដង។ នៅពេលទំនេរពីការទទួលភ្ញៀវបរទេស ខ្ញុំត្រូវ ដឹកនាំក្រុមទៅធ្វើការងារបកផ្នែក ដើម្បីយកសំឡី ដាក់ឃ្លាំង។

នៅឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំភូមិភាគបូព៌ាត្រូវ អង្គការចោទថាក្បត់ និងជាប់និន្នាការនយោបាយ ខ្លាំង ដែលត្រូវចាប់ខ្លួនយកទៅសម្លាប់ ឬកម្ទេច ចោល។ ហេតុនេះអង្គការបានចុចឈ្មោះខ្ញុំ និង ប្រមូលអ្នករស់នៅភូមិភាគបូព៌ាទាំងអស់ ដែល កំពុងបម្រើការនៅទីក្រុងភ្នំពេញ យកទៅទីតាំង ស្ពានអូឡាំពិកដើម្បីធ្វើការកែប្រែ និង អប់រំ។ កាល នោះ តានួនជា និង តាវិទូ គឺជាអ្នកអប់រំផ្ទាល់។ កំពុង តែស្តាប់ការអប់រំ ស្រាប់តែមានឡានបរថយក្រោយ សំដៅមកកាន់ក្រុមខ្ញុំ។ កម្មាភិបាលទាំងនោះក៏ឱ្យ ឡើងឡានជាប្រញាប់។ រថយន្តបរសំដៅទៅទិស ខាងលិច ទើបដឹងថាអង្គការបញ្ជូនយើងទៅលត់ដំ ខ្លួននៅចំណុចព្រៃក្រាស់ជ្រោះពេជ្រនិល។ ដោយ សារខ្ញុំជាប់និន្នាការនយោបាយទី៣ ហេតុនេះ អង្គការ គ្រាន់តែឱ្យទៅលត់ដំខ្លួនជាមុនសិន បើខ្ញុំលត់ដំខ្លួន មិនបាន គឺអង្គការនឹងធ្វើការសម្លាប់។ ការងារដែល អង្គការប្រគល់ឱ្យខ្ញុំធ្វើនៅពេលនោះ គឺកាប់ព្រៃពី តំបន់សំរោងផ្គោះទៅពេជ្រនិល ចំណែកប្រុសៗគឺ ត្រូវកាប់ព្រៃពីកំពង់សោមសំដៅមកជួបគ្នានៅទីតាំង ពេជ្រនិល។ ក្រៅពីការងារកាប់ព្រៃ គឺអង្គការឱ្យខ្ញុំ



*ជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ឌុច ភេន ហៅ ឌុច សុភាព (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ធ្វើផ្លូវរថភ្លើង។ នៅខែកុម្ភៈ ឆ្នាំ១៩៧៨ អង្គការបានរៀបចំពិធីប្តេជ្ញា (រៀបការ)ឱ្យខ្ញុំ និងប្តីឈ្មោះ សន សុខន ដែលគាត់ធ្លាប់ស្នើសុំតាំងពីឆ្នាំ១៩៧៦។ ក្រោយពិធីប្តេជ្ញារួច អង្គការក៏បំបែកប្តីប្រពន្ធខ្ញុំឱ្យទៅធ្វើការតាមកន្លែងរៀងៗខ្លួន។

នៅដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានវាយរំដោះទីក្រុងភ្នំពេញ ហើយថ្ងៃនេះបានក្លាយជាថ្ងៃប្រវត្តិសាស្ត្រនៃការរំដោះជាតិ។ រណសិរ្សនេះ បានបង្កើតរបបថ្មីឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ ប៉ុន្តែខ្ញុំ ត្រូវរត់គេចខ្លួនតាមជួរភ្នំឱរ៉ាល់ជាមួយកងទ័ពខ្មែរក្រហម រួមទាំងតាម៉ុក ក្នុងគោលបំណងឆ្ពោះទៅព្រំដែនថៃ។ ប៉ុន្តែគ្រួសារខ្ញុំ ត្រូវស្នាក់នៅត្រឹមតំបន់រលាក់កងជើង ក៏ចុះមករស់នៅសហករណ៍ក្នុងខេត្តពោធិ៍សាត់។ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨០ ទើបប្តីប្រពន្ធខ្ញុំបានត្រឡប់មកស្រុកកំណើតវិញជួបជុំឪពុកម្តាយ និងបងប្អូន។

# ឌីន ឆែវ៉ន ហៅ វ៉េន ៖ យុទ្ធនារីបដិវត្តន៍

**មីន សាណាស់**

ក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោក សេនាប្រមុខ លន់ នល់ ក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយ ខ្មែរក្រហមបានសុំយាងសម្តេចព្រះ នរោត្តម សីហនុ ដែលគង់នៅក្រៅប្រទេសឱ្យមកកាន់ប្រទេសកម្ពុជាវិញ។ ខណៈនោះ ខ្មែរក្រហមទើបចាប់ផ្តើមគ្រប់គ្រងបានប្រទេសថ្មី ហេតុនេះមិនទាន់បានរៀបចំកងទ័ពឱ្យបានត្រឹមត្រូវឡើយ។ ឌីន ឆែវ៉ន ហៅ វ៉េន ក្នុងនាមជាយុទ្ធនារីកងទ័ពខ្មែរក្រហម ត្រូវបានអង្គភាពបញ្ជូនឱ្យទៅចាំទទួលសម្តេចឪ នៅឯព្រលានយន្តហោះពោធិ៍ចិនតុង។ កងទ័ពជាច្រើនបានមកឈររង់ចាំទទួលសម្តេចព្រះ នរោត្តម សីហនុ។ វ៉េន ត្រូវស្លៀកពាក់ជាឯកសណ្ឋានកងទ័ព ចំណែកសម្តេចឪក៏គាត់គ្រងសម្លៀកបំពាក់ជាកងទ័ពដូចគ្នា។ នៅពេលនោះ វ៉េន ត្រូវឈរនៅជួរខាងមុខ ពេលសម្តេចឪយាងចុះពីលើយន្តហោះ។ ប៉ុន្តែក្នុងនាមជាកងទ័ព វ៉េន មិនបានចាប់ដៃសម្តេចឪឡើយ។

ខ្ញុំឈ្មោះ ឌីន ឆែវ៉ន ហៅ វ៉េន (សព្វថ្ងៃដូរមកឈ្មោះ ហ៊ុន ឆែវ៉ន) ភេទស្រី អាយុ៤៥ឆ្នាំ (នៅឆ្នាំ២០០៨) ទីកន្លែងកំណើត និងបច្ចុប្បន្នរស់នៅភូមិពាមក្នុង ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ហ៊ុន ឌីន និង ម្តាយឈ្មោះ វន មានមុខរបរធ្វើចម្ការ។ គ្រួសារខ្ញុំស្ថិតក្នុងវណ្ណៈថ្នាក់កណ្តាល។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ក្នុងនោះមានស្រីចំនួន៣នាក់ និង ប្រុសចំនួន២នាក់។ ខ្ញុំជាកូនច្បងក្នុងគ្រួសារ។ ខ្ញុំបានរៀបការនៅក្រោយរបបខ្មែរក្រហមដួលរលំជាមួយប្តីឈ្មោះ ភួ បាក់ដេង។ ក្រោយពីរៀបការរួច ខ្ញុំមានកូនចំនួន៧នាក់ ក្នុងនោះមានកូនស្រីចំនួន៥នាក់ និង កូនប្រុសចំនួន២នាក់។

កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ចាស់ ដែលស្មើនឹងថ្នាក់ទី៣ ក្នុងពេលបច្ចុប្បន្ន។ មូលហេតុនៃការឈប់រៀនរបស់ខ្ញុំ គឺមកពីលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ការធ្វើរដ្ឋប្រហារពីសំណាក់លោក លន់ នល់ បានបង្កឱ្យប្រជាពលរដ្ឋក្នុងភូមិឃុំកើតក្តីខឹងសម្បា រួចនាំគ្នាងើបឡើងធ្វើបាតុកម្មប្រឆាំងជាមួយរបបសាធារណរដ្ឋខ្មែរ និងបណ្តាលឱ្យអ្នកភូមិមានរបួសជាដើម។ រីឯគ្រូៗដែលធ្លាប់បង្រៀនខ្ញុំ និង កូនសិស្សឯទៀត បាននាំគ្នារត់ចេញពីភូមិ ហើយសាលារៀនក៏ត្រូវបិទទ្វារ។ បន្ទាប់ពីនោះ កងទ័ពបដិវត្តន៍ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិបានទាំងស្រុង ព្រមទាំងមានការទទួលស្គាល់ និង គោរពពីប្រជាជនក្នុងភូមិថែមទៀតផង។

នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំមានអាយុប្រហែលជា១៨ឆ្នាំ ប្រធាននារីបដិវត្តន៍ភូមិពាមឈ្មោះ សុខឃីម បានហៅអ្នកភូមិទាំងអស់ទៅប្រជុំ ដើម្បីជ្រើសរើសបុ ចុចឈ្មោះយុវជនយុវនារីឱ្យចូលបម្រើកងទ័ពបដិវត្តន៍ ដោយគ្មានការសាកសួរជាមុន។ ឪពុកម្តាយរបស់ខ្ញុំបានបង្ហាញភាពមិនពេញចិត្ត ព្រោះខ្ញុំជាកូនស្រី។ ប៉ុន្តែគាត់ទាំងពីរបានត្រឹមនៅស្ងៀម។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៤ ខ្ញុំបានចូលបម្រើបដិវត្តន៍តាមរយៈឈ្មោះ នារី ស្រាន ជាផ្លូវការ។ ក្រោយមកទៀត អង្គការបញ្ជូនខ្ញុំ និង មិត្តភក្តិឯទៀតទៅសមរភូមិភ្នំបាសិត និង តំបន់កប់ស្រូវ ក្រោមការគ្រប់គ្រងពីឈ្មោះ អឿន ជាប្រធានកងពលទី១។ ការងារដែលខ្ញុំបានទទួលពី អឿន និងត្រូវចុះអនុវត្តគឺដឹកជញ្ជូនគ្រាប់ទៅសមរភូមិមុខ និងពេលត្រឡប់មកវិញត្រូវ

សែងអ្នករបួស ដែលបានវាយប្រយុទ្ធគ្នានៅសមរភូមិមុខយកមកព្យាបាលនៅមន្ទីរពេទ្យកងទ័ព។ ក្រៅពីការងាររកាន់ក្រែស្នែង គឺអង្គភាពឱ្យខ្ញុំហាត់រៀនផ្នែកក្បូនកងទ័ពជារៀងរាល់ថ្ងៃ។ ដៃរបស់ខ្ញុំត្រូវកាន់ក្រែស្នែង សែងអ្នករបួសរហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។

បន្ទាប់ពីរបបខ្មែរក្រហមទទួលបានជ័យជម្នះ ខ្ញុំនិងកងពលត្រូវផ្លាស់មកកាន់ទីក្រុងភ្នំពេញភ្លាមៗ។ ខ្ញុំបានឃើញប្រជាជនទីក្រុងភ្នំពេញជាច្រើនកំពុងធ្វើដំណើរចេញពីទីក្រុង ដោយខ្លះដឹកសម្ភារតាមរថយន្ត និងខ្លះទៀតទូលរែកសម្ភារដើររចេញពីផ្ទះរៀងៗខ្លួន ព្រមទាំងមានសំឡេងស្រែករបស់កងទ័ពខ្មែរក្រហម «សុំឱ្យប្រជាជនចេញពីក្រុងសិន»។ ចំណែកកងពលខ្ញុំត្រូវធ្វើដំណើរមករស់នៅក្នុងតំបន់ទួលគោក។ រស់នៅទីក្រុងភ្នំពេញ ដំបូងអង្គការបានផ្ដល់ការងារឱ្យខ្ញុំជ្រើសរើសមានពីរផ្នែក គឺនារីពេទ្យ និងនារីកាត់ដេរខោអាវ និងមុង សម្រាប់កងទ័ព។ ខ្ញុំរើសផ្នែកកាត់ដេរ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់កងពលទី១ដដែល។ ក្រៅពីការងារកាត់ដេរ អង្គការតែងតែដកសមាជិកកងពលខ្ញុំចំនួន១០នាក់ យកទៅដាំបាយ ធ្វើម្ហូបឱ្យយុវជនយុវនារីដែលត្រូវមករៀនផ្នែកជីវទស្សន៍។ កន្លងទៅប្រហែលជាមួយទៅពីរឆ្នាំ អឿន ដែលជាប្រធានកងពល ត្រូវអង្គការចោទប្រកាន់ថាក្បត់បដិវត្តន៍ និង ក្រោយមក អឿន ក៏បាត់ខ្លួនរហូត។ បន្តបន្ទាប់មកទៀត សមាជិកក្នុងកងពលត្រូវបាត់ខ្លួនដោយគ្មានមូលហេតុ។ សភាពការណ៍ក្នុងកងកាត់ដេរក៏ប្រែប្រួល និងត្រូវយកកម្មាភិបាលភូមិភាគនិរតីមកគ្រប់គ្រងជំនួសវិញ។ ខ្ញុំជាកម្មាភិបាលថ្នាក់ក្រោម មានតួនាទីតូចតាច គឺមិនត្រូវអង្គការចាប់ខ្លួនឡើយ ប៉ុន្តែត្រូវចូលរៀនវគ្គជីវទស្សន៍ជាច្រើនដង ស្ថិតនៅស្តាតអូឡាំពិក។ លើសពីនោះ អង្គការថែមទាំងចុះទៅធ្វើប្រវត្តិរូបរបស់ខ្ញុំផ្ទាល់នៅស្រុកកំណើតថែមទៀត។ ខ្ញុំត្រូវនិយាយ និងសម្ដែងការស្មោះត្រង់ចំពោះអង្គការជានិច្ច។ ពេលទំនេរពីការរៀន គឺខ្ញុំទៅជួយដាំបាយ ធ្វើម្ហូប និងជួយហាលស្រូវដែលកងទ័ពប្រមូលផលបានយកទៅទុកក្នុងឃ្លាំង។ ទីតាំងកងកាត់ដេរដែលខ្ញុំរស់នៅគឺប៉ុលពត និងអ្នកមានតួនាទីធំៗផ្សេងៗទៀត ខស្សាហ៍ដើរមកត្រួតពិនិត្យសួរសុខទុក្ខយុទ្ធនារីកាត់ដេរ ប៉ុន្តែខ្ញុំខ្លាចអ្នកធំក៏ចេះតែរត់លាក់ខ្លួន។ កងទ័ពតូចធំ តែងតែមកកងកាត់ដេរ ដើម្បីកាត់ខោអាវ។

ក្រោយពីប្រធានកងពលខ្ញុំត្រូវអង្គការចាប់ខ្លួនទៅ ខ្ញុំត្រូវផ្លាស់ប្ដូរចូលក្នុងកងពល៥០២វិញ ដែលមានប្រធានកងពលឈ្មោះ តាឆាំ និង តាញ៉ើវ។ កងពល៥០២ មានទីតាំងស្ថិតនៅចំណុចទួលកី តាមផ្លូវជាតិលេខ៣។ នៅកងពល៥០២ ខ្ញុំឈប់ធ្វើការក្នុងកងកាត់ដេរទៀតហើយ គឺត្រូវអង្គការចាត់តាំងឱ្យទៅធ្វើការលើកទំនប់ និងជីកប្រឡាយ នៅក្បែរព្រលានយន្តហោះពោធិ៍ចិនតុង ដែលមានក្រុមយុទ្ធជនអ្នកបើកយន្តហោះប្រដេញជាអ្នករែកដី។ ក្រុមយុទ្ធជនបើកយន្តហោះប្រដេញ ពេលមកធ្វើការគឺមានឡានប៉ុម្ប៉ូតូជូនមក និងដឹកយកទៅវិញ។ ពេលខ្ញុំធ្វើការនៅតាមទំនប់ប្រឡាយ គឺឃើញជនជាតិចិនចុះមកបង្រៀន និងដឹកនាំឱ្យធ្វើការងារផ្សេងៗ។ អ្នកបកប្រែភាសាចិននៅកាលនោះ ឈ្មោះ បងហុង (ស្រី)។ បន្ទាប់មកទៀត អង្គការដកខ្ញុំឱ្យមកកាន់ផ្នែកភស្តុភា ដែលមានយុទ្ធនារីប្រហែលជា៣០នាក់ ដែលត្រូវទទួលខុសត្រូវលើការរក្សាទុក និង ចែកចាយ ផ្អក ប្រហុក ត្រី និង សាច់។ ផ្អក ប្រហុក និង ត្រី ទាំងនោះ គឺទទួលបានមកពីអង្គភាពនេសាទព្រែកក្ដាម។ ខ្ញុំត្រូវធ្វើការចែកចាយទៅតាមកងតូចកងធំ នៅតាមទីក្រុងភ្នំពេញឱ្យហូបបានគ្រប់គ្រាន់ និងសល់ប៉ុន្មានរៀបចំដាក់ចូលឃ្លាំងវិញ។

នៅចុងឆ្នាំ១៩៧៨ កងពលខ្ញុំត្រូវចុះទៅច្រូតស្រូវនៅតំបន់ស្ទឹងមានជ័យ ក្បែរប៉ុស្តិ៍វិទ្យុដែលខ្មែរក្រហមចាក់ផ្សាយរាល់ថ្ងៃនៅពេលល្ងាចពេលសម្រាកពីការងារ។ ខ្ញុំទើបតែច្រូតស្រូវបានរយៈពេលពីរថ្ងៃ ក៏ស្រាប់តែវិទ្យុដាច់ប៉ុស្តិ៍ មិនអាចស្ដាប់ព័ត៌មានអ្វីបានទាំងអស់។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាវិទ្យុមិនពុសំឡេងផ្សាយ ព្រមទាំងក្នុងចិត្តអន្ទះសារង់ចាំស្ដាប់ព័ត៌មាន។ ព្រឹកឡើងខ្ញុំងើបទៅច្រូតស្រូវដូចធម្មតា ស្រាប់តែប្រធានកងពលដេញឱ្យត្រឡប់មកទីតាំងរៀងៗខ្លួនវិញ ព្រោះសភាពការណ៍មិនស្រួល និង

ឱ្យរៀបចំអីវ៉ាន់ត្រៀមខ្លួន ហើយនៅម៉ោង១២យប់ត្រូវមកស្ថានីយរថភ្លើងទាំងអស់គ្នា ដើម្បីធ្វើដំណើរតាមរថភ្លើងឆ្ពោះទៅកាន់ខេត្តបាត់ដំបង។

នៅពេលកងពលរបស់ខ្ញុំមកដល់ខេត្តបាត់ដំបង អង្គការចាត់តាំងឱ្យក្រុមខ្ញុំយាមប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា ជាពិសេសប្រជាជនរស់នៅខេត្តស្វាយរៀង និងជាអតីតកងទ័ពខ្មែរក្រហមដែលសុទ្ធតែជនពិការ ឱ្យកាប់ដីរានធ្វើចម្ការដាំបន្លែ។ ក្រោយពីកាប់ដី ដាំបន្លែហើយ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមចងប្រជាជនភូមិភាគបូព៌ាទាំងខ្សែៗយកទៅសម្លាប់ចោល។ បន្តមកទៀតខ្មែរក្រហមចាប់សមាជិកក្នុងក្រុមរបស់ខ្ញុំយកទៅសម្លាប់ចោលពីបទមិនស្តាប់ការណែនាំ ដោយលួចបេះផ្លែឈើអង្គការដាក់ក្នុងសាក់កាដូទាហាន។ ខ្ញុំរស់នៅខេត្តបាត់ដំបងរយៈពេលកន្លះខែ ទើបកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានវាយរំដោះទីក្រុងភ្នំពេញ ហើយថ្ងៃនេះបានក្លាយជាថ្ងៃប្រវត្តិសាស្ត្រនៃការរំដោះជាតិ។ រណសិរ្សនេះ បានបង្កើតរបបថ្មីឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ បន្ទាប់មកខ្ញុំបានសម្រេចចិត្តមិនបន្តដំណើរជាមួយកងទ័ពខ្មែរក្រហមទៀតឡើយ រួចក៏លួចរត់ត្រឡប់មកស្រុកកំណើតវិញ។


កងពល ៣១០ វរៈសេនាតូចៈ 3/3
វរៈសេនាធំៈ អនុសេនាធំ ៈ 81

ប្រវត្តិរូបសង្ខេប
មហាជន នៅ លីវ

របស់ មិត្ត ៈ រ៉េន
ឈ្មោះដើម ៈ ឌីន-ឆៃវ៉ិន
អាយុ ៈ 19
ឋានី ៈ យុទ្ធនារី
ចូលបដិវត្ត ថ្ងៃៈ 23-12-74
វណ្ណៈភាព ៈ កណ្ដាលថ្នាក់កណ្ដាល

ជីវប្រវត្តិរបស់ ឌីន ឆៃវ៉ិន ហៅ រ៉េន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្អួយ សៀង៖ បាត់បងប្រុស ក្អួយ សឿន លេខាស្រុកត្រពាំងរូង

**មីន សាណាស់**

«ឱ្យតែបងខ្ញុំមកវិញ ខ្ញុំធ្វើបុណ្យបីយប់បីថ្ងៃ» មូលហេតុគឺ «ទីមួយគឺខ្ញុំអត់មានឪពុកម្តាយ, ទីពីរខ្ញុំព្រាត់បងប្រុសខ្ញុំជាយូរមកហើយ និងទីបីគឺចង់ជួបជុំគ្នា ឱ្យតែអ្នកស្គាល់ខ្ញុំសូមអញ្ជើញទាំងអស់ ដើម្បីឱ្យគ្រប់គ្នាស្គាល់ថាខ្ញុំក៏នៅមានបងប្រុស»។ នេះជាសំដីរបស់ ក្អួយ សៀង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយរូប ដែលបានបាត់បង់សមាជិកគ្រួសារទាំងអស់ចំនួន៧ នាក់ ក្នុងរបបខ្មែរក្រហម។ កម្មាភិបាលខ្មែរក្រហមបានចោទប្រកាន់ថា ក្រុមគ្រួសាររបស់ សៀង ជាប់និន្នាការនយោបាយ ដែលត្រូវចាប់យកទៅកម្ទេច និងមួយចំនួនទៀតបានបាត់ខ្លួនដោយមិនដឹងមូលហេតុ និងមិនបានទទួលដំណឹងអ្វីសោះរហូតមកដល់ពេលបច្ចុប្បន្ន។ ខាងក្រោមនេះ គឺជាការរៀបរាប់រឿងរ៉ាវបទពិសោធន៍ឆ្លងកាត់ក្នុងរបបខ្មែរក្រហមរបស់ សៀង និងការបាត់ខ្លួនរបស់បងប្រុសឈ្មោះ ក្អួយ សឿន៖

ក្អួយ សៀង អាយុ៥១ឆ្នាំ (២០០៥) ត្រូវជាប្អូនប្រុស ក្អួយ សឿន មានតួនាទីជាលេខាស្រុកត្រពាំងរូងនៃរបបខ្មែរក្រហម។ សៀង កើតនៅភូមិក្រាំងប្រេស ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នរស់នៅភូមិព្រៃក្បៀង ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សៀង មានឪពុកឈ្មោះ ប៉ោ ក្អួយ និងម្តាយឈ្មោះ ញ៉ែម យ៉ែម។ សៀង មានបងប្អូនចំនួន៦នាក់ ក្នុងនោះមានប្អូនស្រីពៅម្នាក់។ សៀង គឺជាកូនទី៥ ក្នុងគ្រួសារ។ បងរបស់សៀងពីរនាក់ (ស៊ឹម និងសឿន) បានបាត់ខ្លួន និងបីនាក់ទៀត (គីម, កៅ និង យ៉េង) ត្រូវបានអង្គការចាប់យកទៅកម្ទេចចោលក្នុងរបបខ្មែរក្រហម។ សៀង មានប្រពន្ធឈ្មោះ ស៊ាយ កួន អាយុ៤៩ឆ្នាំ (២០០៥) និងមានកូនចំនួន៦នាក់ ក្នុងនោះមានកូនស្រីចំនួន៣នាក់។ ចំពោះ សៀង ផ្ទាល់ក៏ធ្លាប់ត្រូវអង្គការចាប់យកទៅវាយសម្លាប់ក្នុងដើមឆ្នាំ១៩៧៧ ប៉ុន្តែដោយភ័ព្វសំណាងល្អទើបអាចនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។ មកដល់ពេលនេះទើប សៀង យល់ឃើញថា បងប្អូនរបស់គាត់ចាញ់បោកការឃោសនារបស់អង្គការបដិវត្តន៍ ម្នាក់ៗខំប្រឹងវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ដើម្បីតែខំកសាងខ្លួនឱ្យបានប្រវត្តិរូបល្អជូនអង្គការ។ ប៉ុន្តែក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះ បងប្អូនគាត់ត្រូវអង្គការចាប់យកទៅសម្លាប់គ្មានសល់។

រំឭកអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម សៀង នៅតែមានអារម្មណ៍សោកស្តាយចំពោះការស្លាប់ និងការបាត់ខ្លួនបងប្អូនរបស់គាត់ ជាពិសេសបងប្រុសឈ្មោះ ក្អួយ សឿន ដែលជាអ្នកមានចំណេះដឹងម្នាក់ក្នុងគ្រួសារ ធ្លាប់បួសរៀនសូត្រជាមួយព្រះសង្ឃក្នុងវត្តគគីរតនារាម បានចំនួនបួនវស្សា។ នៅឆ្នាំ១៩៦៨ សឿនបានលាចាកសិក្ខាបទរួចត្រឡប់មកនៅផ្ទះបងប្រុសឈ្មោះ គីម (បងប្រុសទី១) វិញ និងបន្តធ្វើស្រែចម្ការសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ បងប្អូនរបស់ សៀង ទាំងអស់ត្រូវរស់នៅជាមួយ គីម ក្រោយពីឪពុកម្តាយបានស្លាប់ទៅ។

នៅឆ្នាំ១៩៧០ ក្រោយពីព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ សឿន ក៏បានស្ម័គ្រចិត្តចូលក្នុងចលនាបដិវត្តន៍ក្នុងភូមិក្រាំងប្រេស តាមការឃោសនារបស់កងទ័ពរំដោះ ដើម្បីទាមទារឱ្យសម្តេចឪយាងចូលមកប្រទេសវិញ។ បន្ទាប់មកទៀតអង្គការក៏បញ្ជូនសឿនឱ្យទៅធ្វើជាឃោធាស្រុក៥១ ដែលមានប្រធាន

ឈ្មោះ តាម៉ែ។ ធ្វើយោធាស្រុក៥១រយៈពេលមួយឆ្នាំ ព្រមទាំងធ្លាប់វាយជាមួយទាហាន លន់ នល់ បាន មួយរយៈ អង្គការក៏បញ្ជូន សឿន ឱ្យឡើងមកធ្វើជា យោធាតំបន់៣៣ ដោយអង្គភាពដំឡើងតួនាទីជា ប្រធានអនុសេនាតូចរយៈពេលមួយឆ្នាំទៀត។ ប្រធាន កងទ័ពតំបន់៣៣ កាលនោះឈ្មោះ តាទីន។ តាមពិត បងប្រុសទាំងប្អូនរបស់ សៀង រួមទាំង សៀង សុទ្ធតែ ចូលរួមក្នុងចលនាបដិវត្តន៍ និងជាកងទ័ពខ្មែរក្រហម ដ៏ស្មោះត្រង់។

នៅឆ្នាំ១៩៧៣ សឿនបានមកលេងបងប្អូននៅ ស្រុកកំណើត ហើយប្រាប់ថាអង្គការគ្រោងបញ្ជូនខ្លួន ទៅក្នុងកងទ័ពភូមិភាគនិរតី ស្ថិតក្រោមការគ្រប់គ្រង របស់ តាម៉ុក ហើយត្រូវឡើងទៅវាយប្រយុទ្ធគ្នា ជាមួយទាហាន លន់ នល់ ស្ថិតនៅផ្លូវជាតិលេខ៤ ក្នុង ពេលឆាប់ៗនេះ។ នៅពេលដែល សឿន ឡើងទៅ ធ្វើកងទ័ពនៅភូមិភាគ បងប្អូននៅឯស្រុកកំណើតមិន សូវបានទទួលដំណឹងច្រើនដូចមុនទៀតឡើយ។ ពេល ស៊ើបសួរដំណឹងម្តងៗ តែងតែទទួលបានមកវិញថា គឺម្តងថាស្លាប់ និង ម្តងថារស់។ ដល់មកឆ្នាំ១៩៧៤ ទើបគាត់ត្រឡប់មកលេងផ្ទះម្តងទៀត មុននឹងធ្វើ ដំណើរទៅសមរភូមិមុខ។

នៅឆ្នាំ១៩៧៥ ក្រោយពីរបបខ្មែរក្រហមឡើង កាន់អំណាចពេញលេញ សឿន បានមកលេងផ្ទះ ម្តងទៀតរយៈពេលមួយសប្តាហ៍។ ប៉ុន្តែអង្គការតម្រូវ ឱ្យ សឿន ស្នាក់នៅទីតាំងគណៈស្រុក (បច្ចុប្បន្ននៅឃុំ ព្រៃក្មេង)។ មកម្តងនេះគឺ សឿនជិះរថយន្តម៉ាកហ្ស៊ីប អាឌីមួយគ្រឿង ព្រមទាំងកងកម្លាំងការពារ មានម៉ូតូ មួយអមដំណើរ និងរថយន្តមួយគ្រឿងទៀតសម្រាប់ នីរសារចំនួន៥នាក់មកជាមួយ។ កាលនោះ សឿន បានប្រាប់បងប្អូនថា គាត់ធ្វើការនៅត្រពាំងរូងអណ្តូង ទឹក ខាងខេត្តកោះកុង។ សៀង ដោយសារតែឃើញ បងមកផ្ទះលើកទី៣ មាន ឡានហ្ស៊ីបអាឌីជិះធ្វើការ មានកងកម្លាំងការពារច្រើន ទើបមិនហ៊ានសួរនាំច្រើន ពីឋានៈ និង តួនាទីរបស់បងឱ្យបានច្បាស់លាស់។ សៀង នៅតែចាំសំដីរបស់ សឿន ដែលបានណែនាំ មកកាន់ប្អូនថា «ឱ្យខំកសាងខ្លួន»។ កាលដែល សឿន និយាយមកកាន់ សៀងឱ្យខំកសាងខ្លួនមានន័យថា កុំឱ្យខូចស្រីញី កុំខឹងច្រើន ត្រូវស្តាប់វិន័យអង្គការ និងកុំលួចរបស់របរក្នុងសហករណ៍។

បន្ទាប់ពីសឿនត្រឡប់ទៅវិញសៀងក៏បានទទួល ដំណឹងថាបងប្រុសត្រូវផ្លាស់ទៅធ្វើគណៈស្រុកត្រពាំង រូងអណ្តូងទឹក។ មិនបានប៉ុន្មានពីដំណឹងផ្លាស់តួនាទី របស់សឿន, សៀង ក៏ទទួលដំណឹងថាបងប្រុសត្រូវ អង្គការចាប់ខ្លួនយកទៅដាក់នៅមន្ទីរស-២១ ប៉ុន្តែ ដំណឹងមួយទៀតគឺថាគាត់បានរត់ចូលទៅរស់នៅឯ ប្រទេសថៃ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្ត វៀតណាម បានវាយរំដោះប្រទេសកម្ពុជាពីទិសខាង កើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ នៅថ្ងៃ ទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជាបានវាយរំដោះទីក្រុងភ្នំពេញ ហើយថ្ងៃនេះបានក្លាយជាថ្ងៃប្រវត្តិសាស្ត្រនៃការរំដោះ ជាតិ។ រណសិរ្សនេះ បានបង្កើតរបបថ្មីឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ ប៉ុន្តែ សៀង នៅ តែរង់ចាំមើលផ្លូវបងរហូតមកដល់សព្វថ្ងៃ ព្រមទាំង ក្តីសង្ឃឹមថាបងបានរត់ទៅរស់នៅទឹកដីបរទេស ឬ ក៏កន្លែងណាមួយពិតជាមិនខាន។


I10112 (8)

# អតីតអ្នកធ្លាប់ជាប់ឃុំឃាំងក្នុងគុកពពកវិល បង្ហាញការសោកស្តាយចំពោះទីតាំងគុកមិនត្រូវបានថែរក្សាជាភស្តុតាង

អេង សុខម៉េង



*ទីតាំងរណ្ដៅសាកសពទួលពពកវិល ស្ថិតនៅក្នុងភូមិរោងដំរី ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ក្នុងរបបខ្មែរក្រហម ដែលសព្វថ្ងៃប្រែក្លាយទៅជាវាលស្រែរបស់ប្រជាជន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទីតាំងគុកពពកវិលកាលពីរបបខ្មែរក្រហម នាពេលបច្ចុប្បន្នត្រូវបានប្រជាជនកាន់កាប់ និងរស់នៅជុំវិញ។ ក្មេងជំនាន់ក្រោយមិនបានដឹងថា ទីតាំងនេះធ្លាប់ជាកន្លែងធ្វើទារុណកម្ម និង សម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃក្នុងរបបខ្មែរក្រហមទេ។ អ្នកធ្លាប់ជាប់គុកពពកវិលម្នាក់ដែលរួចផុតជីវិតពីការឃុំខ្លួន បង្ហាញការសោកស្តាយចំពោះការបាត់បង់ភស្តុតាងឧក្រិដ្ឋមួយដែលបញ្ជាក់ពីទង្វើឃោរឃៅដែលខ្មែរក្រហមធ្លាប់ប្រព្រឹត្តមកលើប្រជាជនខ្លួនឯងអំឡុងពេលកាន់អំណាច។

គោលនយោបាយមួយក្នុងចំណោមគោលនយោបាយ ទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពាររបដិវត្តន៍សង្គមនិយមគឺការលត់ដំនូវ «សមាសភាពមិនល្អ» និងការសម្លាប់ «ខ្មាំង» ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចបានបំផ្លាញរចនាសម្ព័ន្ធច្បាប់ និងតុលាការដែលមានស្រាប់។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ជំនួស

រចនាសម្ព័ន្ធទាំងនេះដោយបណ្ដាញមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនៅតាមតំបន់ដែលខ្លួនបានកាន់កាប់ដើម្បីឃុំខ្លួន និងលត់ដំ ឬសម្លាប់អ្នកទាំងឡាយដែលត្រូវបានសង្ស័យថា ជាប់ពាក់ព័ន្ធក្នុងសកម្មភាពប្រឆាំងនឹងរដ្ឋ។ ក្នុងអំឡុងរបបខ្មែរក្រហមគ្រប់គ្រងប្រទេស មន្ទីរសន្តិសុខប្រហែល២០០កន្លែង និងកន្លែងសម្លាប់មនុស្សយ៉ាងច្រើនរាប់មិនអស់ត្រូវបានបង្កើតឡើង ដែលប្រទះឃើញនៅគ្រប់ភូមិភាគទូទាំងប្រទេសកម្ពុជា និងនៅគ្រប់ថ្នាក់ទាំងអស់នៃរចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជារួមទាំងនៅកម្រិតមជ្ឈិមបក្ស។

គុកពពកវិល មានទីតាំងនៅក្នុងឃុំចេក ស្រុកសំរោង (បច្ចុប្បន្នស្រុករំដួល) ខេត្តស្វាយរៀង ស្ថិតនៅក្នុងចំណោមគុកជាច្រើននៅទូទាំងប្រទេសដែលត្រូវបានប្រើប្រាស់ដើម្បីឃុំឃាំងកម្មាភិបាលខ្មែរក្រហមក្បត់ និងប្រជាជនទូទៅដែលប្រព្រឹត្តខុសសីលធម៌ ឬបានលួចចំណីអាហាររបស់អង្គការ។ ពពកវិលជាគុកទី២ សម្រាប់ឃុំឃាំងអ្នកទោស បន្ទាប់ពីគុកកំពង់អំពិល ដែលស្ថិតនៅឃុំកំពង់អំពិល ស្រុកសំរោង ខេត្តស្វាយរៀង បន្ទាប់ពីដាក់អ្នកទោសពេញ។ អ្នកធ្លាប់ជាប់គុកនេះបានរៀបរាប់ថាគុកពពកវិលមានអ្នកទោសជាកម្មាភិបាលខ្មែរក្រហម និងប្រជាជនស្លូតត្រង់ប្រមាណ ៣០០នាក់ អ្នកទោសទាំងអស់បានស្លាប់ដោយសារការធ្វើទារុណកម្មពេលសួរចម្លើយ និងមួយចំនួនត្រូវបាននាំយកទៅសម្លាប់។ អ្នកធ្លាប់ជាប់គុកចំនួនតែ២នាក់ប៉ុណ្ណោះដែលនៅមានជីវិតបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ គឺប្រធានកងឈ្លបកំពង់អំពិល (បានស្លាប់ពេលក្រោយមក) និង ពាម សន ប្រធានសហករណ៍ទួលសាលាក្នុងរបបខ្មែរក្រហម។

ខាងក្រោមនេះគឺជាការរៀបរាប់របស់ ពាម សន ពីដំណើរជីវិតរបស់គាត់ដែលបានចូលរួមក្នុងបដិវត្តន៍ខ្មែរក្រហមរហូតក្លាយជាប្រធានសហករណ៍ និងក្រោយមកត្រូវបានចាប់មកឃុំខ្លួនក្នុងគុកនេះប្រមាណជាង៣ខែ មុនពេលដែលរបបខ្មែរក្រហមត្រូវបានផ្ដួលរំលំដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ពាម សន ភេទប្រុស អាយុ៨០ឆ្នាំ មានស្រុកកំណើត និងបច្ចុប្បន្នរស់នៅភូមិទួលសាលា ឃុំជ្រុងពពេល ស្រុករំដួល ខេត្តស្វាយរៀង។ ប្រពន្ធឈ្មោះ អ៊ុក យ៉ន។ គាត់មានកូន១១នាក់ ស្រី៣នាក់ ប្រុស៨នាក់ (ស្លាប់២នាក់)។ ឪពុកឈ្មោះ ស្រី យ៉ង ម្ដាយឈ្មោះ ហែម ធីម គាត់ទាំងពីរបានស្លាប់ក្នុងរបបខ្មែរក្រហម។ សនជាកូនទី៣ក្នុងគ្រួសារដែលមានបងប្អូន៧នាក់។ សនរៀនបានត្រឹមថ្នាក់ទី១០ ក្នុងរបបសង្គមរាស្ត្រនិយម នៅសាលាបឋមសិក្សាទួលសាលា។

មុនឆ្នាំ១៩៧០ សន បានរៀបការប្រពន្ធនៅស្រុកកំណើត។ បន្ទាប់ពីរៀបការរួចគាត់បានទៅរកស៊ីរត់ពន្ធទំនិញពីប្រទេសវៀតណាមយកទៅលក់នៅឃុំសួង ខេត្តកំពង់ចាម (បច្ចុប្បន្នក្រុងសួង ខេត្តត្បូងឃ្មុំ)។ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពេលមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ សន កំពុងតែជិះកង់ដឹកទំនិញលក់នៅឃុំសួង គាត់បានឃើញប្រជាជននាំគ្នាធ្វើបាតុកម្មដោយលើកបដាផ្សេងៗ និងប្រជាជនមួយចំនួនទៀតបានលើកទង់ជាតិអបអរសាទរជ័យជម្នះរបស់របប លន់ នល់។ ពេលនោះ សនបានធ្វើដំណើរត្រឡប់ទៅភូមិកំណើតឯភូមិទួលសាលាដើម្បីជួបជុំជាមួយក្រុមគ្រួសារវិញ ព្រោះប្រទេសជាតិជួបប្រទះភាពច្របូកច្របល់ មានការប្រទាញប្រទង់គ្នារវាងប្រជាជនដែលគាំទ្ររបប លន់នល់ និងគាំទ្រសម្ដេចព្រះ នរោត្តម សីហនុ។ ពេលទៅដល់ភូមិ សន ឃើញមានអំពើអសន្តិសុខផ្សេងៗបានកើតឡើងដោយសារតែមានកម្លាំងចលនាខ្មែរក្រហម និងទាហាន លន់ នល់ វាយប្រយុទ្ធគ្នា។ យុវជនយុវនារីជាច្រើនបានចូលរួមក្នុងកម្លាំងចលនាខ្មែរក្រហមដើម្បីបណ្ដេញទាហាន លន់ នល់ ចេញពីភូមិ។ រីឯ យន្តហោះសហរដ្ឋអាមេរិកដែលគាំទ្ររបប លន់នល់ បានមកទម្លាក់គ្រាប់បែកច្រើនឡើងៗ ពិសេសនៅពេលយប់។ សន បានឃើញប្រជាជនផ្លាស់ប្ដូរកន្លែងរស់នៅទៅក្នុងព្រៃ និងតាមវាលស្រែ ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែកទាំងនោះ។ បន្ទាប់មកទៀត ក្នុងភូមិដែល សនរស់នៅ គឺឃើញ

វត្តមានកងទ័ពធៀវគីគាំទ្ររបប លន់ នល់ និងកងទ័ពវៀតកុងគាំទ្រកម្លាំងចលនាខ្មែរក្រហម។ សន បានរៀបរាប់ថា កងទ័ពធីវគី ដែលទទួលការគាំទ្រពីទាហាន លន់ នល់ បានបង្កើតក្រុមឆ្មាខ្មៅដើម្បីបង្កភាពអសន្តិសុខនៅពេលយប់ ដោយបានលួចប្លន់ទ្រព្យសម្បត្តិប្រជាជន និងបានចាប់ខ្លួនមនុស្សតាមតែអំពើចិត្ត។

នៅឆ្នាំ១៩៧២ ដោយសារក្តីស្រឡាញ់របបសង្គមរាស្ត្រនិយម និងស្អប់របប លន់ នល់ សន បានសម្រេចចិត្តចូលរួមចលនាបដិវត្តន៍ និងរត់ចូលព្រៃម៉ាគីដើម្បីតស៊ូជាមួយចលនាខ្មែរក្រហម។ សន មានគោលបំណងចង់នាំប្រទេសជាតិ និងប្រជាជនចេញពីសង្គ្រាម និងការទម្លាក់គ្រាប់បែក។ ស្ថិតក្នុងព្រៃម៉ាគី សន បានស្គាល់ជាមួយ ប៉ូ លីវ៉ាន់ ជាគណៈស្រុកសំរោង (បច្ចុប្បន្នស្រុករំដួល) សៅ សារ៉េត ជាសមាជិកស្រុកសំរោង និង សុខ សាម៉ន គណៈឃុំជ្រុងពពេល។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលរបបខ្មែរក្រហមឡើងកាន់អំណាច សន ត្រូវបានអង្គការចាត់តាំងឱ្យគាត់ធ្វើជាប្រធានសហករណ៍ទួលសាលា ឃុំជ្រុងពពេល ស្រុកសំរោង ខេត្តស្វាយរៀង។ សន បានឃើញខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំរាប់រយគ្រួសារពីទីក្រុងភ្នំពេញ និងទីរួមខេត្តស្វាយរៀង មករស់នៅសហករណ៍ដែលគាត់គ្រប់គ្រង។ ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានានៅទូទាំងប្រទេសក្នុងរបបខ្មែរក្រហម គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាតាមរយៈគោលនយោបាយ «មហាលោតផ្លោះ» និងការពារបក្សកុម្មុយនីស្តប្រឆាំងនឹង «សត្រូវផ្ទៃក្នុងនិងសត្រូវខាងក្រៅ»។ វិធីសាស្ត្រដ៏ចម្បងមួយក្នុងការសម្រេចបានគោលបំណងនេះគឺការផ្លាស់ទីប្រជាជនពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទមួយកន្លែងទៅកាន់ទីជនបទមួយកន្លែងទៀត ម្តងហើយម្តងទៀត។ សន បានឃើញប្រជាជនថ្មីទាំងនោះរស់នៅក្នុងសាលា និងវត្តទួលសាលា។ ប្រជាជនចាស់ជាអ្នកផ្គត់ផ្គង់ស្បៀងអាហារ និងកន្លែងស្នាក់នៅ។ ប្រជាជនថ្មីទាំងអស់ត្រូវបានខ្មែរក្រហមរើសអើង និងត្រូវធ្វើប្រវត្តិរូបជារឿយៗ។ ប្រជាជនថ្មីដែលមានប្រវត្តិធ្លាប់ធ្វើការក្នុងរបប លន់ នល់ ដូចជាមន្ត្រីរដ្ឋការ គ្រូបង្រៀន និងគ្រួសារប៉ូលិស ទាហាន ត្រូវរស់នៅផ្សេងពីប្រជាជនមូលដ្ឋាន និងមួយចំនួនត្រូវបាននាំទៅសម្លាប់នៅគុកកំពង់អំពិល។

ទោះបីជាខ្មែរក្រហមបានអះអាងថា ខ្លួនកំពុងតែកសាងប្រទេសមួយប្រកបដោយភាពស្មើគ្នា និងលុបបំបាត់ចោលវណ្ណៈសង្គមយ៉ាងណាក៏ដោយ ប៉ុន្តែធាតុពិតខ្មែរក្រហមបានបង្កើតឡើងនូវការបែងចែកវណ្ណៈថ្មីពីរនៅក្នុងប្រទេសគឺ «ប្រជាជនមូលដ្ឋាន» និង «ប្រជាជនថ្មី»។ ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ ជាប្រជាជនពេញសិទ្ធិអាចក្លាយជាប្រធានសហករណ៍ មេភូមិ និងប្រធានកងជាដើម។ ចំណែកប្រជាជនថ្មី គឺជាជន «បញ្ញើក្អែក» គ្មានសិទ្ធិអ្វីទាំងអស់ ហើយប្រជាជនថ្មីទទួលរងទុក្ខបុកម្នេញខ្លាំងជាងប្រជាជនចាស់។ ប៉ុន្តែទំហំនៃអំពើឃោរឃៅមានកម្រិតខុសគ្នាពីតំបន់មួយទៅមួយតំបន់មួយទៀត។

សន ដែលជាប្រធានសហករណ៍បានឃើញទុក្ខលំបាករបស់ប្រជាជនក្នុងមូលដ្ឋានដែលគាត់គ្រប់គ្រងរួមមាន៖ របបអាហារមិនគ្រប់គ្រាន់ ការងារច្រើនហួសកម្លាំង និងមានប្រជាជនស្លូតត្រង់ជាច្រើនត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងអំពើក្បត់អង្គការជាដើម។ សន និយាយថាដោយសារតែអង្ករដែលអង្គការបើកឱ្យសហករណ៍មានចំនួនតិច អ្នកជម្លៀសថ្មីមកច្រើនធ្វើឱ្យការផ្គត់ផ្គង់របបអាហារមានការថយចុះ ជាហេតុនាំឱ្យប្រជាជនត្រូវទទួលបានបបររាវៗជំនួសរបបបាយដែលធ្លាប់ទទួលបាននាពេលកន្លងមក។ សន ធ្លាប់បានរាយការណ៍ពីការកង្វះខាតអង្ករនៅសហករណ៍ទៅឃុំ និងបន្តទៅស្រុក ប៉ុន្តែថ្នាក់លើបានចោទប្រកាន់គាត់ថា បានលួចអង្កររបស់អង្គការឱ្យទៅសមាជិកគ្រួសារហូប ទើបធ្វើឱ្យអង្ករនៅសហករណ៍ខ្វះខាតឬហូបមិនគ្រប់ថ្ងៃដែលកំណត់។

ធ្វើជាប្រធានសហករណ៍ទួលសាលាបានប្រហែល ២ឆ្នាំ សន ត្រូវបានយោធាខ្មែរក្រហមចាប់គាត់ដាក់គុកពពកវិលដោយចោទប្រកាន់ថាគាត់ក្បត់



អតីតទីតាំងមន្ទីរសន្តិសុខនៅភូមិទួលពពកវិល ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ក្នុងរបបខ្មែរក្រហមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នឹងអង្គការ និងបានលួចអង្ករឱ្យសមាជិកគ្រួសារខ្លួនហូបទើបធ្វើឱ្យប្រជាជនហូបមិនគ្រប់គ្រាន់ៗ ប៉ុន្តែតាមការអង្កេតរបស់ សន ផ្ទាល់ឃើញថាអ្នកដែលត្រូវបានអង្គការចាប់ខ្លួន រួមទាំងគាត់ ភាគច្រើនត្រូវបានកម្មាភិបាលខ្មែរក្រហមគ្នាឯងរាយការណ៍មួលបង្កាច់ ដោយសារការស្អប់ ច្រណែន និងដើម្បីយកមុខយកមាត់ៗ សនបានរៀបរាប់ពីព្រឹត្តិការណ៍នៃការចាប់ខ្លួនរបស់គាត់ថា « ពេលនោះខ្ញុំកំពុងធ្វើការនៅសហករណ៍ដូចរាល់ថ្ងៃ មានឈ្លបឃុំ២នាក់បានស្រែកហៅខ្ញុំឱ្យទៅប្រជុំៗ ពេលខ្ញុំចេញពីរោងសហករណ៍មកឈ្លបនោះបានចាប់ដៃខ្ញុំចងដោយមានម្នាក់ចាំផ្ចង់កាំភ្លើងៗ ខ្ញុំត្រូវបានឈ្លបទាំងពីរនាក់នាំទៅកាន់គុកពពកវិល ដោយសារគុកកំពង់អំពិលដាក់អ្នកទោសពេញៗ ប្រពន្ធកូនខ្ញុំដែលធ្វើការនៅសហករណ៍មិនបានដឹងពីការចាប់ខ្លួនខ្ញុំទេ»ៗ

គុកពពកវិលស្ថិតនៅលើដីដួលមួយដែលមានព្រៃ និងផ្ទះចាស់ៗ ផ្ទះមួយចំនួនបានខូចខាតដោយអន្ទើៗដោយសារតែយន្តហោះទម្លាក់គ្រាប់បែកៗ ពេលទៅដល់គុកមានឆ្មាំក្មេងៗ៣នាក់ មានធាងត្នោត និងដើមឫស្សីនឹងដៃមកវាយគាត់ទាំងមិនបានសួរនាំអ្វីទាំងអស់ៗ បន្ទាប់ពីវាយអស់ចិត្ត ទើបមានឆ្មាំគុកមួយក្រុមទៀតនាំ សន ចូលទៅក្នុងគុកៗ នៅក្នុងគុក សន បានឃើញអ្នកទោសប្រហែល៣០០នាក់ កំពុងតែជាប់ឃុំដោយជើងមានជាប់ខ្នោះៗ អ្នកជាប់ឃុំចែកចេញជាពីរប្រភេទគឺអ្នកទោសកម្រិតធ្ងន់ និងអ្នកទោសអប់រំៗ អ្នកទោសកម្រិតធ្ងន់ គឺជាប់ក្នុងគុកងងឹតមានដាក់ខ្នោះជើងទាំងថ្ងៃទាំងយប់ រីឯទោសអប់រំវិញមានដាក់ខ្នោះជើងនៅពេលយប់ ប៉ុន្តែពេលថ្ងៃអាចចេញទៅធ្វើការខាងក្រៅបានៗ សន ពេលចូលដល់គុកដំបូងត្រូវជាប់ទោសកម្រិតធ្ងន់ស្ថិតនៅកន្លែងងងឹតទាំងថ្ងៃទាំងយប់ដោយជើងមានជាប់ខ្នោះជាប្រចាំៗ សន ត្រូវបានឆ្មាំនាំទៅសួរចម្លើយបីថ្ងៃ

ជាប់ៗគ្នាដោយសួរ១ថ្ងៃ២ដង គឺពេលព្រឹក និងពេលល្ងាចៗ ឆ្មាំសួរចម្លើយមានគ្នាបីនាក់ គឺឈ្មោះ កន, លុត ភី និងបេណាំ ហាយ ដែលជា ឆ្មាំសួរ ឆ្មាំកត់ និងឆ្មាំវាយៗ សន ត្រូវឆ្មាំវាយពេលដែលចម្លើយមិនត្រូវតាមចិត្តរបស់ឆ្មាំសួរៗ សំណួរដែលឆ្មាំសួរចម្លើយ សន មានដូចជា ១-តើមិត្តចូលដៃជាមួយយួនឬ? ២-តើមិត្តមានបានលួចអង្ករអង្គការឱ្យប្រពន្ធកូនទេ? និង ៣-ហេតុអីបានជាសហករណ៍ខ្វះខាតអង្ករ? សន ត្រូវឆ្លើយនូវចម្លើយដែលឆ្មាំសួរចង់បាន ប្រសិនបើមិនឆ្លើយទេគឺឆ្មាំគុកវាយ ទាល់តែឆ្លើយទទួលស្គាល់កំហុសថាបានចូលដៃជាមួយយួន និងធ្លាប់បានលួចអង្ករអង្គការទើបឆ្មាំឈប់សួរ និងឈប់វាយៗ ឧបករណ៍សម្រាប់វាយគឺគល់ឫស្សី ឬស្វាយកាំភ្លើងៗ

បទបញ្ជាសម្រាប់ឆ្មាំគុកបានហាមមិនឱ្យមានអំពើមនុស្សធម៌ឡើយៗ គោលចំហរ និងសតិអារម្មណ៍ខ្ពស់ត្រូវតែមានដាច់ខាតចំពោះអ្នកដែលទទួលខុសត្រូវនៅក្នុងក្រុមសួរចម្លើយៗ សន ក៏បាននិយាយដែរថាភាគច្រើនឆ្មាំគុកនៅ ទីនោះគឺគាត់ធ្លាប់ស្គាល់ពីមុន ប៉ុន្តែឆ្មាំទាំងនោះមិនហ៊ាននិយាយថាធ្លាប់ស្គាល់គាត់ទេៗ ពេលសួរចម្លើយចប់ សន ត្រូវបានបញ្ជូនមកកន្លែងអ្នកទោសអប់រំវិញៗ នៅពេលថ្ងៃ សន អាចចេញធ្វើស្រែ និងលើកពូនរងអំពៅបានប៉ុន្តែត្រូវស្ថិតក្រោមការឃ្លាំមើលពីឆ្មាំគុកៗ នៅគុកពពកវិល សន ធ្លាប់ឃើញអ្នកទោសត្រូវបានគេវាយសួរចម្លើយរហូតដល់ស្លាប់ ហើយឆ្មាំគុកបានប្រើអ្នកទោសដូចគ្នាសែងសាកសពយកទៅកប់នៅបរិវេណជុំវិញៗ

សន ជាប់ឃុំនៅគុកពពកវិលប្រមាណជាង៣ខែៗ អ្នកជាប់នៅ ទីនោះទាំងអស់ត្រូវបានស្លាប់ដោយសារការសួរចម្លើយ និងសម្លាប់ មានតែ សន និងប្រធានឈ្លបឃុំអំពិល ប៉ុណ្ណោះដែលនៅមានជីវិតរស់ ជាអកុសលប្រធានឈ្លបឃុំអំពិលបានស្លាប់នាពេលក្រោយមកៗ

ចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលខេត្តស្វាយរៀងដោយមានទាំងកងទ័ពថ្មើរជើង និងកងទ័ពរថក្រោះ បានបាញ់ផ្លោងគ្រាប់តូច ធំ ពីតំបន់ផ្សារបក សំដៅទៅគុកពពកវិល ហើយឆ្មាំយាមគុកក៏បាននាំគ្នារត់ចេញៗ សន ក៏មានឱកាសអាចរត់ចេញពីគុកៗ ដោយសារនៅពេលនោះក្នុងភូមិនៅសេសសល់យោធាខ្មែរក្រហម សនមិនទាន់អាចត្រឡប់ចូលស្រុកកំណើតបានក៏ភៀសខ្លួនទៅប្រទេសវៀតណាមមួយរយៈ និងបានត្រឡប់មករស់នៅជួបជុំប្រពន្ធកូនវិញក្រោយថ្ងៃរំដោះ ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ៗ

នៅស្រុកកំណើតពេលរំដោះពីរបបខ្មែរក្រហមភ្លាមៗ សន ឃើញការកាប់សម្លាប់មកលើកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋានដែលធ្លាប់ប្រព្រឹត្តអំពើមិនល្អទៅលើប្រជាជនអស់ជាច្រើននាក់ និងមួយចំនួនទៀតបានរត់គេចខ្លួនពីភូមិៗ ចំណែក សនដែលធ្លាប់ធ្វើជាប្រធានសហករណ៍ដែរ ប៉ុន្តែគាត់មិនបានធ្វើបាបប្រជាជន ដូច្នោះ សន មិនទទួលរងការសងសឹកពីប្រជាជនរងគ្រោះដូចកម្មាភិបាលខ្មែរក្រហមដទៃទៀតនោះទេៗ

ក្រោយពីរបបខ្មែរក្រហមដួលរលំ សន ធ្លាប់បានទៅដល់គុកពពកវិលម្តង ប៉ុន្តែទីតាំងនោះមិនត្រូវបានថែរក្សាទុកទេ គឺមានប្រជាជនមករស់នៅ និងកាន់កាប់ៗ ពេលដែលរំឭកពីរបបខ្មែរក្រហម សននៅតែមានអារម្មណ៍ដិតដាម និងឈឺចាប់ៗ សន មានការសោកស្តាយចំពោះការបាត់បង់ភស្តុតាងគុកដែលបញ្ជាក់ពីការឈឺចាប់របស់ប្រជាជនខ្មែរ និងធ្លាប់ប្រើជាកន្លែងសម្រាប់សម្លាប់មនុស្សយ៉ាងសាហាវៗ សនបានស្នើទៅអាជ្ញាធរពាក់ព័ន្ធឱ្យមានការអភិរក្សអតីតទីតាំងគុកពពលវិល ដើម្បីរក្សាទុកជាភស្តុតាងប្រវត្តិសាស្ត្រៗ គាត់ក៏បានផ្តាំផ្ញើឱ្យក្មេងជំនាន់ក្រោយត្រូវឈ្វេងយល់ពីទុក្ខលំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានជួបប្រទះដើម្បីចូលរួមទប់ស្កាត់របបប្រល័យពូជសាសន៍កុំឱ្យកើតមានឡើងនៅលើទឹកដីកម្ពុជានាពេលអនាគតៗ

# ហោម សាមិត្តៈ អតីតអ្នកធ្វើការនៅមន្ទីរក-៧

*សុភ័ក្ត្រ ភាណា*



ពេទ្យកំពុងពិនិត្យមើលដបថ្នាំនៅក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហោម សាមិត្ត ហៅ ទូច មានឈ្មោះបដិវត្តន៍ ប្រាប មិត្ត មានអាយុ៤១ឆ្នាំ (ឆ្នាំ២០០៤) កើតនៅភូមិតារាជ ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត។ ឪពុកខ្ញុំឈ្មោះ ប្រាប ហោម និងម្ដាយឈ្មោះ សយ មុំ។ ឪពុកខ្ញុំបានស្លាប់នៅអំឡុងពេលរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ នៅពេលដែលគាត់ត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំជាកូនទី២ ក្នុងចំនោមបងប្អូន ទាំងអស់១០នាក់។ បងប្អូនខ្ញុំប្រាំនាក់បានស្លាប់ដោយសារជំងឺក្នុងអំឡុងរបបខ្មែរក្រហម និងដោយសារជាន់មីននៅពេលធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីខ្មែរក្រហមដួលរលំ។ ប្អូនៗខ្ញុំបានជាន់មីនស្លាប់ ក្នុងឃុំតាអ៊ិន ត្រង់ចំណុចក្បែរគុម្ពឫស្សីដែលខ្មែរក្រហមធ្លាប់ពង្រាយពីមុនៗ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរៀបការ និងមានកូនស្រីម្នាក់។ ប៉ុន្តែពេលនេះប្ដីខ្ញុំបានស្លាប់បាត់ទៅហើយ ទើបខ្ញុំដូរមករស់នៅជាមួយកូនស្រី។

រំឭកកាលពីកុមារ ខ្ញុំបានរៀនសូត្របន្តិចបន្តួច ត្រឹមថ្នាក់ទី២។ ខ្ញុំឈប់រៀននៅពេលដែលខ្មែរក្រហម

ចូលមកក្នុងភូមិខ្ញុំ។ ពេលនោះ ខ្ញុំទើបមានអាយុ១២ ទៅ១៣ឆ្នាំ។ ពេលខ្មែរក្រហមចូលមកដល់នៅឆ្នាំ ១៩៧៥ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការនៅ ទំនប់ម្ទេចរហូតទៅដល់កោះស្លា បានរយៈពេលប្រហែលពីរខែ។ ពេលនោះ ខ្ញុំធ្វើការទាំងឈឺផង ចាញ់ផង។ ការលើកទំនប់មិនបានប្រព្រឹត្តទៅសមស្របទេ គឺយើងចេះតែរែក និងលើកដីតាមអង្គការបញ្ជា។ ខ្ញុំចាំបានថា នៅពេលមួយនោះ មានទឹកជន់មក លិចស្លាប់មនុស្សអស់ ២ទៅ៣កង ហូរអណ្តែតតាមទឹកអស់។ ក្រោយមក ខ្មែរក្រហមបានផ្លាស់ខ្ញុំឱ្យមកធ្វើការនៅក្នុងភូមិវិញ ដោយជើងខ្ញុំសុទ្ធតែដំបៅងារ ដែលធ្វើឱ្យខ្ញុំសឹងតែស្លាប់ម្តងៗ។

ក្រោយមក អង្គការជ្រើសរើសខ្ញុំទៅរៀនវិជ្ជាពេទ្យ។ តាមខ្ញុំដឹងគឺអង្គការចេះតែរើសមនុស្សយកទៅ។ នៅពេលនោះ ខ្ញុំមានអាយុ១៥ឆ្នាំ គឺនៅឆ្នាំ ១៩៧៧។ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅតាខ្មៅជាមួយអ្នកភូមិពីរនាក់ផ្សេងទៀត។ ខ្ញុំ និងគ្នីគ្នាបានជិះឡានចេញពីកោះស្លាទៅឈូក ដោយស្នាក់នៅឈូកមួយយប់មួយថ្ងៃដើម្បីរង់ចាំឡើងឡានបន្តទៅគោលដៅ។ មុនត្រូវបញ្ជូនទៅតាខ្មៅ យើងត្រូវប្រមូលផ្តុំជាមួយអ្នកដទៃទៀត ដែលមកពីកន្លែងផ្សេងៗ នៅស្តាត (អូឡាំពិក) នៅភ្នំពេញ។ ខ្ញុំចាំថា មួយឡានៗ មានមនុស្សច្រើន ប្រហែលអង្គការយកមនុស្សទៅមួយស្រុកឈូក ក៏ថាបាន។ យើងស្នាក់នៅស្តាតអូឡាំពិកពីរទៅបីថ្ងៃ ទើបខ្មែរក្រហមបែងចែកមនុស្សទៅតាមទីតាំងផ្សេងៗ។ គ្នាខ្ញុំទាំងបីនាក់ដែលមកពីភូមិតែមួយត្រូវបញ្ជូនទៅនៅតាខ្មៅ ឱ្យនៅបម្រើអ្នកពិការ ដែលសុទ្ធតែទាហានរបួស បញ្ជូនមកពីពេទ្យ៧មករា ព្រោះនៅពេទ្យ៧មករាចង្អៀតពេក។ នៅតាខ្មៅ ខ្ញុំធ្វើការក្នុងអគារពេទ្យដែលសព្វថ្ងៃជាមន្ទីរពេទ្យក្រុងតាខ្មៅ។ ដំបូងឡើយ អ្នកគ្រប់គ្រងនៅទីនេះ ឈ្មោះតាសឿន និងបន្ទាប់មកផ្លាស់មកឈ្មោះ បុរិន វិញ។

ខ្ញុំនៅតាខ្មៅបានមួយខែ ខ្មែរក្រហមធ្វើការបែងចែកមនុស្សជាថ្មី។ ខ្ញុំត្រូវផ្លាស់ទៅនៅម្តុំក្រោយវាំងនៅភ្នំពេញ ចំណែកឯអ្នកភូមិរបស់ខ្ញុំពីរនាក់ទៀត ត្រូវផ្លាស់ទៅនៅក្បាលជ្រោយទល់មុខវាំង (ជ្រោយចង្វារ)។ ខ្ញុំនៅផ្ទះជិតសាលារចនា ស្ថិតនៅតាមផ្លូវស្របមាត់ទន្លេ ដែលទីនេះមានសមាជិក ស្រី និងប្រុស ចំនួនប្រមាណ៣០នាក់។ ខ្ញុំចាំបានថា មានកម្លាំងនៅយាមវាំងយ៉ាងតឹងរឹង និងមិនអនុញ្ញាតឱ្យមនុស្សចេញចូលទេ ប៉ុន្តែខ្ញុំមិនដឹងថាមាននរណានៅក្នុងវាំងនោះឡើយ។ បើតាមការនិយាយតៗគ្នា សម្តេចព្រះនរោត្តម សីហនុ ត្រូវដាក់ឃុំនៅកន្លែងភស្តុភារ។

នៅកន្លែងដែលខ្ញុំធ្វើការ ខ្មែរក្រហម ចាត់តាំងឱ្យខ្ញុំបោសសម្អាតផ្លូវ និងធ្វើការដាំបាយ ទទួលភ្ញៀវចិនមកទស្សនកិច្ច។ ខ្ញុំចាំបានថា ភ្ញៀវចិនមកហូបបាយល្ងាចតែមួយពេលរួចគេត្រឡប់ទៅវិញ។ ក្នុងរបបខ្មែរក្រហម ខ្ញុំឃើញភ្ញៀវចិនមកបីដង។ ភ្ញៀវទាំងនោះដើរតាមផ្លូវ និងធ្វើទស្សនកិច្ចវាំងជាដើម។ ខ្ញុំឃើញមានតែភ្ញៀវពីរនាក់ក្នុងមួយលើក ធ្វើទស្សនកិច្ចជុំវិញវាំង ប៉ុន្តែនៅពេលហូបបាយល្ងាច ភ្ញៀវចិនមកគ្នាច្រើនពេញរោងបាយ។ រោងបាយដែលខ្ញុំទៅធ្វើការស្ថិតនៅជិតវាំងក្បែរកន្លែងខ្ញុំស្នាក់ម្តុំសាលារចនាដែរ។ នៅទីនេះ មានប្រធានប្រុសឈ្មោះ ពូលី មានវ័យខ្ពង់ ២៧ឆ្នាំ និងប្រធានស្រីម្នាក់ទៀត ឈ្មោះបង់រ៉ាន។ ខ្ញុំពុមេក្រុមខ្ញុំឈ្មោះ យ៉ាត់ ហៅកន្លែងនេះថា មន្ទីរក-៧។ គាត់បានប្រាប់ខ្ញុំ និងអ្នកធ្វើការជាមួយគ្នាឱ្យ «ធ្វើការស្រួលបួល ប្រយ័ត្នបាត់ខ្លួន»។ ខ្ញុំចាំថាមានមនុស្សក្នុងក្រុមខ្ញុំប្រហែលជាង១០នាក់បានបាត់ដំណឹង។

ក្រៅពីដាំបាយឱ្យភ្ញៀវចិន និងបោសសម្អាតផ្លូវ ខ្មែរក្រហមឱ្យយើងរៀនអក្សរខ្មែរ ជាមួយគ្រូបានប្រហែល១០ថ្ងៃដែរ។ ជិនាន់នោះ ខ្ញុំបានទៅមើលសិល្បៈ និងសៀកនៅស្តាតអូឡាំពិកបានចំនួន៣ដង ដោយខ្មែរក្រហមជាអ្នកចាត់ចែងឱ្យយើងទៅ គឺយើងមិនអាចទៅខ្លួនឯងបានទេ។ យើងទៅមើលសិល្បៈដោយជិះកូនឡាន ដែលក្នុងមួយឡានមានមនុស្សច្រើនគួរសម។ ខ្ញុំចាំថាសៀកហ្នឹង និយាយអំពីបណ្តាំមាតា បណ្តាំឪ មានតួឈ្មោះយាយលោត។ តាមខ្ញុំចាំ សៀកនោះមានចំណងជើងថា «ពលិកម្មម៉ែយើង» ដែលរៀបរាប់ថា ពីដើមមកម្តាយនោះក្រ ត្រូវទៅរក

ទំពាំងមកចិញ្ចឹមកូន ក្រោយមកប្តីស្លាប់ ទើបគាត់ចូលគស៊ិរ ហូតស្លាប់ដែរ។ កាលនោះ មានតែកម្មករក្នុងក្រុមទេទៅមើល ខ្ញុំពុំដែលឃើញអ្នកធំមកទេ ។

បន្ថែមលើការងារដែលខ្ញុំរៀបរាប់ខាងលើ ខ្ញុំត្រូវទទួលបន្ទុកដឹករបស់របរដូចជា បាយ, ត្រី, កន្សែង និងក្រមាជាដើម ទៅច្បារអំពៅ ទៅឱ្យប្រជាជនកម្ពុជាក្រោមដែលត្រូវកែនមកពីស្រុកក្រោម។ កម្ពុជាក្រោមទាំងនោះ និយាយខ្មែរដូចយើងដែរ មានស្រីប្រុស មានក្មេង ចាស់ ពេលនោះ គឺប្រហែលជានៅឆ្នាំ ១៩៧៨។ ក្រោយមក ខ្ញុំត្រូវចាត់ទៅដឹកដីយកមកចាក់ថ្នល់ នៅហួសស្ទឹងមានជ័យ គឺនៅកណ្តាលស្ទឹងម្តុំស្ទឹងកន្ទួតខេត្តកណ្តាល។ នៅទីនោះ មានខ្សាច់ច្រើនណាស់ យើងកើបដីពីក្នុងស្ទឹងយកមកចាក់នៅរាំង ដើម្បីធ្វើថ្នល់ឡើងវិញ ព្រោះផ្លូវថ្នល់ម្តុំនេះ បានបាក់បែកជិនាន់សង្គ្រាម។ ចំពោះការហូបចុក នៅកន្លែងខ្ញុំគ្មានការពិបាកទេ។ យើងហូបគ្រប់គ្រាន់ តែយើងត្រូវគេហៅទៅធ្វើប្រវត្តិរូបច្រើនដង។ ខ្ញុំធ្លាប់សុំមកលេងស្រុក ប៉ុន្តែអង្គការពុំអនុញ្ញាតឡើយ។

ខ្ញុំបន្តធ្វើការនៅទីនេះ រហូតដល់វៀតណាមចូលមកដល់។ នៅពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំរត់ទៅដល់ពោធិ៍សាត់ គឺរត់ទៅទាំងអស់គ្នាមួយកងតែម្តង។ ក្រោយមក ខ្ញុំបានលួចរត់មកស្រុកវិញ តែម្នាក់ឯង និងជួបបងប្អូននៅតាមផ្លូវ។ នៅពេលដែលមកដល់ផ្ទះវិញ ខ្ញុំបានដឹងថាប្អូនតូចជាងគេរបស់ខ្ញុំម្នាក់ បានឈឺស្លាប់នៅក្នុងរបបខ្មែរក្រហម។



ក្រុមគ្រូពេទ្យផលិតថ្នាំបុរាណក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យូ សារ៉េនៈ អតីតគ្រូពេទ្យ នៅតំបន់៣២ ខេត្តកោះកុង

**មឿន ស្រីណុច**



យូ សារ៉េន ភេទស្រី អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យូ សារ៉េន ភេទស្រី អាយុ៧០ឆ្នាំ កើតនៅក្នុងភូមិស្លែង ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នរស់នៅក្នុងភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ សារ៉េន មានឪពុកឈ្មោះ យូ គ្រីប (ស្លាប់ដោយសារមានជំងឺក្នុងឆ្នាំ១៩៧៧) និងម្ដាយឈ្មោះ ង៉ែត រុន (ស្លាប់)។ សារ៉េនមានបងប្អូនបង្កើតចំនួន៧ នាក់ ក្នុងនោះមានស្រីចំនួន៣នាក់។ សារ៉េនបានរៀបការប្ដីឈ្មោះ នួ ណា អាយុ៧០ឆ្នាំ។ ក្រោយរៀបការ សារ៉េនមានកូនស្រីម្នាក់ឈ្មោះ ធីតា អាយុ២៧ឆ្នាំ។ នៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ សារ៉េនបានធ្វើជាគ្រូពេទ្យផ្នែកវះកាត់ប្រចាំនៅមន្ទីរពេទ្យតំបន់៣២ ក្នុងខេត្តកោះកុង។

នៅឆ្នាំ១៩៦៦ សារ៉េន ត្រូវបានឪពុកម្ដាយបញ្ជូនឱ្យទៅរៀនជាមួយគ្រូៗនៅសាលាក្នុងវត្តត្នោតជុំ ស្ថិតនៅឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ។ សារ៉េន រៀនបានត្រឹមថ្នាក់ទី៩ នៅសម័យសង្គមរាស្ត្រនិយម ក៏ឈប់រៀន ព្រោះប្រទេសធ្លាក់ក្នុងសភាពចលាចល ដោយសារលោក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ ចេញពីតំណែង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

ក្រោយពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ កងទ័ពខ្មែរក្រហមចាប់ផ្ដើមចូលមកក្នុងឃុំត្រពាំងធំ។ បន្ទាប់ពីនោះ កងទ័ពខ្មែរក្រហមបានប្រកាសឱ្យបុរសៗនៅតាមភូមិនីមួយៗចូលស្ម័គ្រចិត្តបម្រើកងទ័ពបដិវត្តន៍ ដើម្បីធ្វើការប្រឆាំងទប់ទល់ជាមួយទាហាន លន់ នល់ ក្នុងការទាមទារសិទ្ធិអំណាចជូនសម្ដេចព្រះ នរោត្ដម សីហនុវិញ។ គ្រូៗបង្រៀនក្នុងវត្តត្នោតជុំ និងយុវជនមួយចំនួនដែលមានវ័យចំណាស់ជាង សារ៉េនបាននាំគ្នាស្ម័គ្រចិត្តចូលរួមជាមួយកងទ័ពខ្មែរក្រហម។

នៅឆ្នាំ១៩៧១ ទាហាន លន់ នល់ បានបើកយន្តហោះមកទម្លាក់គ្រាប់បែ៥២ យ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងភូមិស្លែង។ ការទម្លាក់គ្រាប់បែក បានធ្វើឱ្យខូចខាតផ្ទះសម្បែងរបស់ប្រជាពលរដ្ឋមួយ

ចំនួន ថែម ទាំងបានទម្លាក់គ្រូវមន្ទីរពេទ្យបណ្ដាលឱ្យគ្រូពេទ្យម្នាក់បានស្លាប់ រួមទាំងអ្នកជំងឺក្នុងមន្ទីរពេទ្យបានរងរបួស ជាច្រើននាក់ទៀត។

នៅឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហម ចូលមកប្រកាសផ្សព្វផ្សាយនៅក្នុងភូមិស្លែង ដើម្បីឱ្យយុវជន និងយុវនារី ចូលទៅព្រៃដើម្បីហ្វឹកហាត់ក្បួនកងទ័ព ចេញតស៊ូ ជាមួយទាហានរបស់ លន់ នល់។ បន្ទាប់ពីបានឮការប្រកាស សារ៉ែន និងបងប្អូនចំនួនបីនាក់ទៀតបានលួចចូលចលនាតស៊ូជាមួយខ្មែរក្រហម ដោយមិនឱ្យឪពុកម្ដាយដឹង។ បន្ទាប់មកទៀត សារ៉ែន ត្រូវបានខ្មែរក្រហមចាត់ឱ្យចូលធ្វើជាគ្រូពេទ្យនៅភូមិភាគនិរតី។ ភូមិភាគនិរតី (ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក។ ចំណែក ប្រធានមន្ទីរពេទ្យនៅភូមិភាគនិរតីឈ្មោះ តាកង និងមានប្រពន្ធឈ្មោះ សំ ជាជនជាតិវៀតណាម មកពីទីក្រុងហាណូយ ប្រទេសវៀតណាម ។ សារ៉ែន ធ្វើជាគ្រូពេទ្យរួមជាមួយកូនស្រីបង្កើតរបស់តាម៉ុក ឈ្មោះ ព្រាក ហ៊ាញ ។ ចំណែកបងប្អូនដែលរត់មកជាមួយគ្នានោះ ចូលធ្វើជាកងទ័ព និងត្រូវទៅប្រយុទ្ធជាមួយទាហាន លន់ នល់ នៅសមរភូមិ ។ នៅសមរភូមិគឺមានកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់ ជាច្រើននាក់ត្រូវបានស្លាប់ និងរងរបួសក្នុងពេលសង្គ្រាមនៅចន្លោះឆ្នាំ១៩៧២ ដល់ចុងឆ្នាំ១៩៧៤ ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ សារ៉ែន ត្រូវបានបញ្ជូនទៅធ្វើពេទ្យប្រចាំនៅខេត្តកោះកុង។ ប្រធានគ្រប់គ្រងរួមមន្ទីរពេទ្យធំ កងពល២៥០ តំបន់៣២ ឈ្មោះ តាកន។ ចំណែកប្រធានមន្ទីរពេទ្យឈ្មោះ សឹង ជាដុកទ័រផ្នែកវះកាត់តាំងពីសម័យសាធារណរដ្ឋខ្មែរ រហូតមកដល់សម័យខ្មែរក្រហម ប៉ុន្តែក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សឹង និងគ្រូពេទ្យដែលមានជំនាញព្យាបាលជំងឺ និងវះកាត់ក្នុងមន្ទីរពេទ្យជាច្រើនរូប ត្រូវបានអង្គការចាប់ខ្លួនទាំងយប់ និងបាត់ខ្លួនទាំងគ្មានមូលហេតុ។ បន្ទាប់ពី សឹង ត្រូវបានចាប់ខ្លួន សារ៉ែន និងគ្រូពេទ្យមួយចំនួននៅក្នុងមន្ទីរពេទ្យមានភាពភ័យខ្លាចខ្លាំងណាស់ ព្រោះខ្លាចអង្គការចាប់ខ្លួនគ្រូពេទ្យជាបន្តបន្ទាប់ទៀត។ មិនយូរប៉ុន្មាន អង្គការបានតែងតាំងប្រធានមន្ទីរពេទ្យថ្មីឈ្មោះ ភួង ។ ជារៀងរាល់ថ្ងៃ សារ៉ែន និងគ្រូពេទ្យទាំងអស់ ត្រូវមើលថែព្យាបាលជំងឺទាំងប្រជាជនទូទៅ និងកងទ័ព ប៉ុន្តែមិនសូវមានប្រជាជនចូលមកសម្រាកព្យាបាលច្រើននោះទេ។ សារ៉ែនបានរៀបរាប់ថា ប្រជាជនដែលចូលមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យភាគច្រើនបានកើតជំងឺគ្រុនចាញ់ ខ្វះជីវជាតិ មានសភាពហើមលើរាងកាយ កើតទាចទឹក និងមានជំងឺជាច្រើនប្រភេទទៀត ព្រោះការបរិភោគមិនគ្រប់គ្រាន់។ សារ៉ែន បានសង្កេតឃើញថា បញ្ហាសុខភាពរបស់ប្រជាជនភាគច្រើនមានសភាពស្គមស្គាំង ខ្វះជីវជាតិអាហារគ្រប់មុខ និងមានសភាពធ្ងន់ធ្ងររួចទៅហើយ ទើបអង្គការបញ្ជូនមកមន្ទីរពេទ្យ។ ទោះបី សារ៉ែន និងគ្រូពេទ្យដទៃទៀតខំប្រឹងព្យាបាលអស់ពីសមត្ថភាពយ៉ាងណាក៏ដោយ ប្រជាជននៅតែស្លាប់ក្នុងមន្ទីរពេទ្យអស់ជាច្រើននាក់ ព្រោះការព្យាបាលមិនទាន់ពេលវេលា។ ។ ចំពោះបញ្ហារបស់កងទ័ពខ្មែរក្រហម គឺភាគច្រើនកើតជំងឺគ្រុនចាញ់។ ក្នុងរបបខ្មែរក្រហម គ្រូពេទ្យទាំងអស់ប្រចាំក្នុងខេត្តកោះកុង មានអាហារហូបចុកគ្រប់គ្រាន់មិនជួបការលំបាកឡើយ។ សារ៉ែន ដឹងថាថ្នាំពេទ្យទាំងអស់នៅក្នុងមន្ទីរពេទ្យទទួលបានមកពីប្រទេសចិន និងសុទ្ធតែជាថ្នាំល្អៗ។

នៅឆ្នាំ១៩៧៦ សារ៉ែន ប្រចាំការណ៍នៅក្នុងមន្ទីរពេទ្យដដែល។ អង្គការមិនបានជម្លៀស សារ៉ែន ចេញទៅតាមប្រជាជនឡើយ។ នៅពេលនោះ គណៈភូមិភាគបស្ចិមមានឈ្មោះ តាស៊ើង។ រីឯគណៈតំបន់នៅក្នុងខេត្តកោះកុង ឈ្មោះ វ៉ន ជាអ្នកស្រុកកំណើតនៅភូមិដំណាក់ស្នួល ស្រុកឈូក ខេត្តកំពត ហើយត្រូវជាឪពុកមារបស់ សារ៉ែន។ ថ្ងៃមួយ វ៉ន បានបញ្ជាឱ្យនារីៗដែលជាគ្រូពេទ្យទាំងអស់រៀបចំតុបតែងខ្លួនដើម្បីត្រៀមចូលរៀបការជាមួយនឹងកងទ័ពខ្មែរក្រហម។ សារ៉ែនបានប្រកែកមិនព្រមរៀបការ ព្រោះអាងថា វ៉ន ជាឪពុកមា និងមិនហ៊ានបង្ខំខ្លួនជាក្មួយ។ អង្គការបានរៀបចំពិធីប្តេជ្ញាឱ្យយុវជនពី៨ទៅ១០គូឡើងចាប់ដៃគ្នា ដោយមិនមានឪពុកម្ដាយមកចូល

រួម គឺអង្គការធ្វើជាសាក្សី។ រ៉ែន ធ្វើជាគណៈតំបន់បានមួយរយៈពេលខ្លីប៉ុណ្ណោះ ក៏ត្រូវអង្គការប្តូរចេញពីខេត្តកោះកុង។ សារ៉ែនបានបែកចេញពីស្រុកកំណើតអស់រយៈពេលជាច្រើនឆ្នាំ ហើយតែងតែសុំប្រធានមន្ទីរពេទ្យឈ្មោះ ភួង ដើម្បីទៅលេងឪពុកម្តាយនៅស្រុកកំណើត ប៉ុន្តែអង្គការមិនអនុញ្ញាតឡើយ។

ចន្លោះឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ មន្ទីរពេទ្យកោះកុង ត្រូវបានបែងចែកជាបីផ្នែក មានខាងផ្នែកជំងឺទូទៅ ផ្នែកព្យាបាលវះកាត់ និងផ្នែកផលិតថ្នាំចាក់។ គ្រូពេទ្យសរុបប្រហែលជាង៣០០នាក់។ សារ៉ែន បានរៀនវិជ្ជាជីវផ្នែកវះកាត់ជាមួយដុកទ័រជនជាតិចិន និង វេជ្ជបណ្ឌិតជួន ជឿន ចុះមកបង្រៀនប្រហែលចំនួន៣ទៅ៤ដង។ ក្រោយពីរៀនរួច សារ៉ែនមានតួនាទីជាជំនួយការទី១ នៅផ្នែកវះកាត់ និងចូលរួមវះកាត់ភ្នែក និងវះប្តុកាត់ជើងកងទ័ពខ្មែរក្រហមដែលរងរបួសដោយសារត្រូវគ្រាប់កាំភ្លើង និងគ្រាប់បែក។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមករំដោះប្រទេសកម្ពុជា។ សារ៉ែនបានរត់តាមកងទ័ពខ្មែរក្រហមទៅកាន់ប្រទេសថៃ។ ក្នុងពេលជាមួយគ្នា មានប្រជាជនជាច្រើនបានរត់ភៀសខ្លួនចូលទៅនៅក្នុងប្រទេសថៃ។ សារ៉ែន រត់ភៀសខ្លួនទៅដល់ថៃបានរយៈពេលប្រហែល១ម៉ោង បានឃើញ ខៀវ សំផន រួមទាំងកម្មាភិបាលខ្មែរក្រហម ២ទៅ៣នាក់ទៀត (មិនស្គាល់អត្តសញ្ញាណ) ជិះកន្ទុំរុយ (ឧទ្ធម្ភាគចក្រ) មកចុះចតកន្លែងប្រជាជនកំពុងរត់ចូលតំបន់ឃ្លងយ៉ែ។ នៅពេលនោះ ខៀវ សំផន បាននិយាយថា« ស្អែកនឹងឱ្យថៃទៅដឹកដាក់នៅឡែមកំរៀង»។ លុះស្អែកឡើង ថៃបានបញ្ជូនឡានធំៗមកដឹក សារ៉ែន និងប្រជាជនផ្សេងទៀតទៅដាក់នៅឡែម។ សារ៉ែន រស់នៅឡែមអស់រយៈពេល១ឆ្នាំ រួចផ្លាស់មករស់នៅចក្រី (ភូមិសាស្តា) នៅមន្ទីរពេទ្យ៨១ ជិតកន្លែងមន្ទីររបស់ តាកន។ មកនៅទីតាំងថ្មី សារ៉ែន នៅតែបន្តធ្វើជាគ្រូពេទ្យ ផ្នែកវះកាត់បន្តទៀត។



ក្រុមគ្រូពេទ្យខ្មែរក្រហមចុះសួរសុខទុក្ខអ្នកជំងឺនៅតាមផ្ទះៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គ្រូបង្រៀននៅស្រុកមេសាង ខេត្តព្រៃវែង រំឭកព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

**ផេង ពង្សរ៉ាស៊ី**

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥ ជាថ្ងៃគម្រប់ខួបទី៥០ឆ្នាំ នៃការចូលកាន់កាប់អំណាចរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ កាលពី៥០ឆ្នាំមុន ថ្ងៃនេះជាថ្ងៃជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយ លន់ នល់ និងជាថ្ងៃដែលប្រជាជនកម្ពុជាមួយចំនួនអបអរសាទរ សប្បាយរីករាយ និងមានសង្ឃឹមក្នុងចិត្តចំពោះការវិលត្រឡប់របស់សម្តេចព្រះ នរោត្តម សីហនុ មកគ្រប់គ្រងប្រទេសកម្ពុជាដូចពេលមុន និងមានជំនឿថា ប្រជាជនកម្ពុជាទាំងអស់នឹងចៀសផុតពីការគាបសង្កត់ កេងប្រវ័ញ្ច ជិះជាន់ និងអំពើពុករលួយពាលាអាវ៉ាសែ។ ប៉ុន្តែបន្តិចក្រោយមកក្នុងថ្ងៃដដែល ប្រជាជនកម្ពុជាបានធ្លាក់ចូលក្នុងរបត់នយោបាយដែលធ្វើឱ្យមានការបំផ្លិចបំផ្លាញជីវិតមនុស្សរាប់លាននាក់ ដោយសារតែមេដឹកនាំនៃរបបថ្មីនេះបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មកលើប្រជាជនទូទាំងប្រទេស។ ប្រជាជនកម្ពុជាទាំងអស់បានស្គាល់បទពិសោធន៍ជីវិតដ៏ជូរចត់ លំបាកវេទនា និងបែកបាក់ក្រុមគ្រួសារដែលពុំធ្លាប់មានពីមុនមក។

ឥឡូវនេះ បទពិសោធន៍ទាំងអម្បាលម៉ាន បានក្លាយជាមេរៀនប្រវត្តិសាស្ត្រសម្រាប់ក្មេងៗជំនាន់ក្រោយរៀនសូត្រដើម្បីការចងចាំ អភិវឌ្ឍន៍គំនិត និងរារាំងការកកើតឡើងវិញចំពោះព្រឹត្តិការណ៍ប្រំដែលរបៀបនេះ។ ថ្វីត្បិតតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរាប់សែននាក់បានបាត់បង់ជីវិតជារៀងរាល់ថ្ងៃដោយសារជំងឺ ជរាភាព និងហេតុការណ៍ផ្សេងៗក៏ដោយ ក៏នៅមានអ្នករស់រានមានជីវិតរាប់លាននាក់ទៀតកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួនដល់ក្មេងៗជំនាន់ក្រោយ ដើម្បីចងក្រងប្រវត្តិសាស្ត្រ និងចូលរួមការពារការវិលត្រឡប់អំពើប្រល័យពូជសាសន៍ជាថ្មីម្តងទៀត។

អត្ថបទនេះ មានគោលបំណងបង្ហាញពីការចែករំលែកបទពិសោធន៍ឆ្លងកាត់ព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងឃុំជីផុច និងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង ពីអ្នករស់រានមានជីវិតចំនួន ៦នាក់ ដែលបច្ចុប្បន្នគឺជាគ្រូបង្រៀននៅកម្រិតសាលាបឋមសិក្សា និងវិទ្យាល័យក្នុងស្រុកមេសាង។

ប្រជាជនគ្រប់ភូមិបានចូលរួមអបអរសាទរនឹងជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ ដែលបានប្រព្រឹត្តទៅនៅតាមទីកន្លែងដែលបានរៀបចំទុកដោយគណៈឃុំ និងគណៈស្រុក ដូចជានៅតាមភូមិ និងនៅក្នុងបរិវេណវត្តអារាមជាដើម។ ប្រជាជននៅក្នុងភូមិជាច្រើននាក់បានរួតរះធ្វើដំណើរទៅចូលរួមអបអរសាទរ និងស្វាគមន៍ចំពោះថ្ងៃជ័យជម្នះ១៧ មេសា តាមការប្រកាសពីអាជ្ញាធរឃុំ និងស្រុក នៅតាមទីកន្លែងប្រារព្ធពិធីនីមួយៗ ប្រជាជនសប្បាយរីករាយ សើចក្អាកក្អាយ រាំ ច្រៀង និងលេងតន្ត្រីសម័យ ហើយនៅកន្លែងខ្លះទៀត មានប្រគុំតន្ត្រីបុរាណខ្មែរដូចជា ទ្រ ស្គរដៃ ឆៃយ៉ាំ និងចាប៉ី។

ជា សម័យ បច្ចុប្បន្នជាគ្រូបង្រៀននៅសាលាបឋមសិក្សាជីផុច បានរៀបរាប់ថា «**កាលហ្នឹង! ខ្ញុំមិនដឹងអីទេ ព្រោះខ្ញុំនៅក្មេង តែខ្ញុំក៏សប្បាយចំពោះថ្ងៃ**

**ជ័យជម្នះ១៧ មេសា ជាមួយគេដែរ**»។ បើតាមគ្រូបង្រៀនពីរនាក់ទៀតបង្រៀននៅវិទ្យាល័យ អង្គរស បានឱ្យដឹងថា ពិធីអបអរសាទរ និងស្វាគមន៍ចំពោះថ្ងៃជ័យជម្នះនេះ គឺមិនត្រឹមតែបានធ្វើឡើងនៅតាមទីកន្លែងដែលបានកំណត់នោះទេ ប៉ុន្តែថែមទាំងបានហែក្បួនពីភូមិមួយទៅភូមិមួយទៀត អមជាមួយការរាំច្រៀងយ៉ាងសប្បាយក្រៃលែង។ លោកគ្រូ ជុំ សុផល អាយុ៥៩ឆ្នាំ រស់នៅភូមិអង្គរស បាននិយាយនិងសម្តែងទឹកមុខញញឹមញញែមថា «**បែក១៧ មេសាភ្លាម យើងផ្អាកលើកប្រឡាយម៉ា (មួយ)ថ្ងៃពីរសិន រួចនាំគ្នាទៅទទួលជ័យជម្នះ១៧ មេសា និងបានចូលរួមដង្ហែក្បួនទៅកាន់វត្តពន្លៃទៀត។ អូយ! មានរាំ មានច្រៀងទៀតណា៎។ ខ្ញុំសប្បាយនឹងការទទួលបានជ័យជម្នះនេះណាស់**»។ អ្នកគ្រូ ប៉ែន សុគុណ សព្វថ្ងៃជានាយិកាវិទ្យាល័យអង្គរស បានបន្ថែមថា «**អ្នកភូមិបានចូលរួមអបអរសាទរថ្ងៃជ័យជម្នះនៅវត្តអង្គរស រួចដង្ហែបន្តទៅកាន់វត្តពន្លៃទៀត។ មានទាំងឆៃយ៉ាំ មានទាំងស្គរដង្ហែទៅដែរ**»។ អ៊ំប្រុស ជា ប៉ាក់ ជាអ្នករស់រានមានជីវិតម្នាក់រស់នៅភូមិស្រះតាអឹម ឃុំអង្គរស និងជាអតីតគ្រូបង្រៀនលោកនៅវត្តស្រះតាអឹម បានមានប្រសាសន៍ថា ភូមិស្រះតាអឹមក៏មានរៀបចំពិធីអបអរសាទរ និងទទួលស្វាគមន៍ថ្ងៃជ័យជម្នះនេះដែរ។ មានទាំងឆៃយ៉ាំ ស្គររាំច្រៀង និងហូបអាហារជុំគ្នាយ៉ាងសប្បាយទៀតផង។ ដូចគ្នានឹងឃុំជីផុចដែរ អ្នកភូមិចូលរួមអបអរសាទរយ៉ាងសប្បាយអឹងកងចំពោះថ្ងៃជ័យជម្នះនេះ ព្រោះយល់ឃើញថា ជាថ្ងៃដែលខ្លួនបានរួចផុតពីការគ្រប់គ្រងរបស់ លន់ នល់។ លោកគ្រូ ហំ គា ជាគ្រូបង្រៀននៅសាលាបឋមសិក្សា ជីផុច បានឱ្យដឹងថា គាត់បានឃើញអ្នកភូមិសប្បាយខ្លាំងណាស់ ហើយសភាពការណ៍ក្នុងភូមិ ក៏ពោរពេញទៅដោយភាពអ៊ូអរ រាំច្រៀង និងស្រែកជ័យយោស។ «**ខ្ញុំសប្បាយនឹងគេដែរ គឺសប្បាយមែន។ សប្បាយគ្រប់កន្លែងទាំងអស់។ រាំច្រៀង វ៉ៃស្គរ វ៉ៃប៉ោត មានទាំងទ្រ អឺ ហ្វ៊ឹងសប្បាយណាស់**»។ លោកគ្រូចូលនិវត្តន៍ ឈ្មោះ ហាស់ ឆឹម អាយុ៨០ឆ្នាំ រស់នៅឃុំអង្គរស មានប្រសាសន៍ថា «**គណៈឃុំបានអនុញ្ញាតឱ្យពួកយើងកាប់ជ្រូកមាន់ទា និងរៀបចំអន្សមហូប ដើម្បីទទួលថ្ងៃមហាជ័យជម្នះ។ ពួកយើងក្នុងភូមិសប្បាយគ្រប់ៗគ្នា**»។

ក្នុងថ្ងៃដដែល ក្បួនហែរ អង្គមីទិញ ការរាំច្រៀង និងភ្លេងតន្ត្រីនានា ត្រូវផ្អាក និងបញ្ឈប់យ៉ាងតក់ក្រហល់បំផុត។ ស្គរ ចាប៉ី ទ្រ និងឆៃយ៉ាំ ត្រូវបានបំផ្លាញចោលគ្មានសល់។ អ្នកចូលរួមអបអរសាទរទាំងប៉ុន្មាន ត្រូវបានប្រាប់ឱ្យវិលត្រឡប់ទៅកាន់ផ្ទះសម្បែងរៀងៗខ្លួនវិញ និងចាប់ផ្តើមរៀបចំខ្លួនដើម្បីទទួលភារកិច្ចថ្មីៗ។ ព្រឹត្តិការណ៍នេះ បានកើតឡើងដូចៗគ្នានៅតាមឃុំនីមួយៗក្នុងស្រុកមេសាង។ នៅក្នុងឃុំជីផុច លោកគ្រូ ហំ គា បានមានប្រសាសន៍ប្រាប់ថា «**សប្បាយ! អាហ្នឹងសប្បាយម៉ាពេល។ តែមិនយូរទេ ខ្ញុំឃើញអត់យូរអញ្ចោះ មិនយូរយ៉ាងម៉េច? រយៈពេលក្រោយមក ស្រាប់តែក្រុមហ្នឹងដដែល ក្រុមរាំច្រៀងហ្នឹង ដូចថារាំច្រៀងលេងតែរយៈពេលប្រហែលជាម៉ា (មួយ)ម៉ោង ឬម៉ាម៉ោងកន្លះទៅ២ម៉ោងអញ្ចឹង! ស្រាប់តែទម្លាក់ទ្រ ទម្លាក់ស្គរ រាំជាន់បាក់ខ្ទេចអស់។ កម្ទេចចោល ទាំងអស់តែម្តង ហើយក៏មិនដឹងដែរថា វាជាគោលការណ៍គេឱ្យកម្ទេចចោល ទាំងអស់ឬយ៉ាងណាទេ ហើយខ្ញុំក៏មិនដឹងធ្វើម៉េចដែរ ដូចថាភ្លើងឆេះឈុលអញ្ចឹងទៅ ក៏ពន្លត់ទៅវិញភឹបតែម្តង។ ដូចថាចាប់ពីពេលហ្នឹងមក វាដូចថាប្លែកៗរហូតមក**»។ នៅឃុំអង្គរសនោះវិញ លោកគ្រូ ជុំ សុផល, អ្នកគ្រូ ប៉ែន សុគុណ, អ៊ំប្រុស ជា ប៉ាក់, លោកគ្រូ ហាស់ ឆឹម និង លោកគ្រូ ជិន ថន បានមានប្រសាសន៍ដូចគ្នាថា ឧបករណ៍ភ្លេងទាំងឡាយ ត្រូវបានកម្ទេចចោលគ្មានសល់ ហើយអ្នកចូលរួមក្នុងពិធីទាំងប៉ុន្មាន បានវិលត្រឡប់មកកាន់ផ្ទះសម្បែងរៀងៗខ្លួនវិញ ជាមួយនឹងចម្ងល់ក្នុងចិត្តពីទង្វើដែលបានកើតមាន។ «**កំពុងតែសប្បាយជុំគ្នាទទួលជ័យជម្នះនេះ ស្រាប់តែឃើញអ្នករាំច្រៀង អ្នកកាន់ស្គរ អ្នកកាន់ចាប៉ី ឆៃយ៉ាំ គេនាំគ្នាទម្លាក់ និងបោះចោលឧបករណ៍ទាំងនោះ រួចនាំគ្នារាំជាន់កម្ទេចចោល ហើយស្រែកថា លះបង់ឱ្យអស់! កម្ទេលស័ក្តិភូមិនាយទុន។ ម្នាក់ៗនាំគ្នាស្រងាកចិត្តគ្រប់ៗគ្នា តែមិនហ៊ាននិយាយ រួចនាំគ្នាវិលត្រឡប់មកផ្ទះវិញ**»។

លោកគ្រូ ជិន ថន, លោកគ្រូ ជា ប៉ាក់, លោកគ្រូ

ម៉ាត់ កូយ និងគ្រូបង្រៀនមួយចំនួនទៀត បានរំពឹកពីថ្ងៃដែលប្រជាជននាំគ្នាទៅចូលរួមអបអរសាទរនេះថា គឺក្នុងគោលបំណងទទួលស្វាគមន៍ចំពោះការយាងនិវត្តន៍របស់សម្តេចឪចូលក្នុងប្រទេសវិញ តាមការសន្យាពីក្រុមខ្មែររំដោះដែលបានសន្យាក្នុងរយៈពេលកន្លងមកៗ ម្នាក់ៗមានចម្លល់គ្រប់ៗគ្នាថា ហេតុអ្វីបានជាពិធីអបអរសាទរមិនបានរំពឹកដល់ឈ្មោះរបស់សម្តេចឪទាល់តែសោះ។ លោកគ្រូ ជិន ថន ជាគ្រូបង្រៀនចូលនិវត្តន៍ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស បាននិយាយដូច្នេះថា **«គោលការណ៍ខ្ញុំ គឺទៅចូលរួមដើម្បីទទួលការវិលត្រឡប់របស់សម្តេចឪ ព្រោះគេបានប្រាប់ថា ពេលជ័យជម្នះទាំងស្រុងហើយ គេនាំសម្តេចឪចូលស្រុកវិញ។ ដល់ទៅ មានណា! គេអត់មានស្រែកជយោ សម្តេចឪផង។ គេស្រែកតែជយោ ប៉ុល ពត សោះ។ ខ្ញុំខកចិត្ត។ អ្នកចូលរួមផ្សេងទៀតក៏ខកចិត្តដែរ»**។ ចំណែកឯលោកគ្រូ ម៉ាត់ កូយ ជាគ្រូចូលនិវត្តន៍ រស់នៅក្នុងភូមិអង្គ្រង ឃុំអង្គរស បានប្រាប់ថា គាត់មានការសោកស្តាយចំពោះពេលវេលារបស់គាត់ក្នុងការគាំទ្រចលនាខ្មែររំដោះ ព្រោះគាត់បានគិតថា នៅពេលដែលទទួលបានជ័យជម្នះលើរបប លន់ នល់ រួចហើយ ប្រទេសជាតិពិតជាទទួលបានសុខសន្តិភាពក្រោមការដឹកនាំរបស់សម្តេចឪដូចពេលមុនទៀត។ **«ពេលទទួលបានជ័យជម្នះ ១៧ មេសា ហើយ យើងស្មានតែបានសេរីភាពពេញបរិបូរណ៍ហើយ។ តាមពិតវាផ្ទុយស្រឡះពីការប៉ាន់ស្មានរបស់យើង»**។

ការអធិប្បាយខាងលើ ជាការចងក្រងពីរឿងរ៉ាវពិតស្តីពីហេតុការណ៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅក្នុងឃុំពីរនៃស្រុកមេសាង គឺឃុំជីផុច និងឃុំអង្គរស។ ការលើកយកព្រឹត្តិការណ៍នេះមកអធិប្បាយ គឺដើម្បីបង្ហាញពីរឿងរ៉ាវពិតមួយដែលបានកើតឡើងនៅក្នុងទឹកដីនៃតំបន់រំដោះខ្មែរក្រហមក្នុងខេត្តព្រៃវែង។ នៅតាមកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជា គឺប្រាកដជាមានរឿងរ៉ាវដូចគ្នា ឬស្រដៀងគ្នា ឬខុសគ្នាខ្លះៗ អាស្រ័យលើពេលវេលា ទីកន្លែង និងបរិយាកាសសង្គម សេដ្ឋកិច្ច និងនយោបាយ។

## សម្រង់សម្តីអ្នករស់រានមានជីវិត៦នាក់នៅឃុំជីផុច និងឃុំអង្គរស ពីហេតុការណ៍ថ្ងៃ១៧ មេសា ១៩៧៥

ខាងក្រោមនេះ ជាការដកស្រង់សម្តីខ្លីក្នុងពេលធ្វើបទសម្ភាសន៍កាលពីដើមឆ្នាំ ២០២១ ទាក់ទងនឹងការឆ្លងកាត់ និងឃើញហេតុការណ៍ផ្ទាល់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥៖

### ជា សម័យ ហៅ ម៉ៃ អាយុ៥៩ឆ្នាំគ្រូបង្រៀននៅសាលាបឋមសិក្សា ជីផុច៖



«...កាលនោះខ្ញុំនៅក្មេងនៅឡើយ ហើយខ្ញុំដឹងតែពីសប្បាយៗ ប៉ុន្តែខ្ញុំដឹងថា នៅថ្ងៃនោះ (១៧ មេសា ១៩៧៥) មានភាពច្របូកច្របល់កើតឡើងដែរ។ មានមនុស្សស្លាប់នៅលើផ្លូវដោយគ្មាននរណាដឹង និងមានភាពរញ៉េរញ៉ៃរត់ឈូឆរដើម្បីយករបស់របរគេ!។ ប៉ុន្តែនៅក្នុងភូមិទាំងមូលវិញ គឺមានការធ្វើពិធីអបអរសាទរចំពោះថ្ងៃជ័យជម្នះនេះដែរ។ ប្រជាជនក្នុងភូមិបានចូលរួមក្នុងពិធីនេះគ្រប់ៗគ្នា។ បន្តិចក្រោយមក ស្រាប់តែស្ងាត់ទៅវិញ ហើយខ្ញុំសង្កេតឃើញមានមនុស្សចម្លែកៗចូលមកក្នុងភូមិខ្ញុំច្រើននាក់»។

## ហំ គា អាយុ៥៣ឆ្នាំ គ្រូបង្រៀននៅសាលាបឋមសិក្សា ជីផុច៖



«ថ្ងៃទី១៧ មេសា ហ្នឹង ខ្ញុំសប្បាយម៉ាពេល ហ្នឹងៗ សប្បាយ ហ្នឹងសប្បាយមែន! សប្បាយគ្រប់កន្លែងគ្រប់កា ឡូកកាលៀត ទាំងអស់!ៗ យើងរាំច្រៀង វ៉ៃស្គរប៉ោត និងកូតទ្រ ៗ ប៉ុន្តែការសប្បាយរាំរែកច្រៀងអី ហ្នឹង មិនបានយូរទេៗ រយៈពេលក្រោយមក ស្រាប់តែក្រុម ហ្នឹងដដែល ដែលរាំច្រៀងវ៉ៃស្គរអី ហ្នឹង បោះបោ លស្គរ ទ្រចាប៉ីអស់រលីង បន្ទាប់ពីច្រៀង រាំរយៈពេលប្រហែលជា១ម៉ោង ឬ ២ម៉ោងរួចៗ ពួកគេ ហ្នឹងនាំគ្នា ទម្លាក់ទ្រ ទម្លាក់ស្គរ ហើយរាំជាន់បាក់ខ្ទេចអស់! កម្ទេចបោ ល ទាំងអស់តែម្តង ហើយក៏មិនដឹងដែរថា ជាគោ លការណ៍យ៉ាងម៉េចទេ ដែល នាំគ្នាជាន់កម្ទេចបោ ល ទាំងអស់អ៊ីចឹង ហើយ ខ្ញុំក៏មិនដឹងធ្វើម៉េចដែរ កាលនោះនៅក្មេងនៅ ឡើយៗ ដូចថាចាប់ពីពេល ហ្នឹងមកវា ដូចថាប្លែកៗ រហូតមកៗ រហូតមកដល់សម័យ ប៉ុលពត គឺធ្ងន់ធ្ងរតែម្តង គឺចាប់ផ្តើមមនុស្សលែងទុកចិត្តគ្នាហើយៗ គ្រូឯងតាមដានខ្ញុំៗ ខ្ញុំតាមដានគ្រូឯងវិញៗ លោកគ្រូឯនេះ តាមដានឯនោះអញ្ចឹងគ្រប់គ្នាទៅណា»ៗ

## ឌុំ សុផល អាយុ ៥៩ឆ្នាំ គ្រូបង្រៀននៅ វិទ្យាល័យហ៊ុន សែន អង្គរសរ៖



«... គ្រាន់តែបែកថ្ងៃ១៧ មេសាភ្លាម គេឱ្យយើងផ្អាកលើកប្រឡាយម៉ាថ្ងៃពីរថ្ងៃសិន ព្រោះគេឱ្យយើងនាំគ្នាទៅ ទទួលជ័យជម្នះ១៧ មេសា នៅវត្តពន្លៃៗ ប្រជាជននាំគ្នាដង្ហែគ្នាពីផ្ទះទៅវត្តៗ អូយ! មានរាំ! មានច្រៀង! សប្បាយណាស់ ព្រោះយើងបានជ័យជម្នះហើយៗ អ្នកមានស្គរគេយកស្គរទៅជាមួយ! គេគោះស្គរផង រាំច្រៀងដង្ហែតាមផ្លូវផង! មើលទៅសប្បាយណាស់ៗ ដល់ចប់ពីអា១៧ មេសា ហ្នឹង! គេនាំគ្នាត្រឡប់មកផ្ទះវិញ តាមផ្លូវគេនាំគ្នាបោកស្គរបោ លអស់ អត់មានឱ្យលេងទេៗ គេលែងឱ្យមានអារក្សអ្នកតាអីទៀតហើយ! គេវ៉ៃស្គរបែកខ្ទេចខ្ទីអស់! ហើយគេបំផុសឱ្យយើងមកជីកប្រឡាយ ហ្នឹងបង្ហើយ ព្រោះប្រឡាយ ហ្នឹង យើងជីកមកយូរហើយៗ ខ្ញុំឈប់សប្បាយនឹងជ័យជម្នះ បែរមករែកដីវិញៗ ពេលរែកដីបន្ទាប់ពីថ្ងៃជ័យជម្នះមក ខ្ញុំស្តាប់ពុទ្ធបំរៀង១៧ មេសារាល់ថ្ងៃៗ ពិរោះណាស់! ស្តាប់ម្តងៗ ខ្ញុំមានអារម្មណ៍ល្អណាស់ ហើយខ្ញុំធ្វើការមិនខ្ជាចហត់នឿយ ឡើយ»ៗ

## ជា ប៉ាក អាយុ៧៨ឆ្នាំ ជាគ្រូបង្រៀន និងអាចារ្យវត្តស្រះតាអីម៖



«នៅថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ប្រជាជនគ្រប់ភូមិ ទាំងអស់ក្នុងឃុំអង្គរស បានចូលរួមប្រារព្ធពិធីអបអរសាទរចំពោះមហាជ័យជម្នះរបស់ខ្មែរក្រហម នៅក្នុងបរិវេណវត្តស្រះតាអីមៗ គណៈឃុំ ចឹង សាក់ និងគណៈស្រុក ពុត ជ្រង បានថ្លែងសុន្ទរកថានៅក្នុង

ពិធីនេះ។ ខ្ញុំមិនបានចាំថា អ្នកទាំងពីរបានថ្លែងអ្វីខ្លះទេ ប៉ុន្តែគ្រាន់តែដឹងថា បន្ទាប់ពីថ្លែងសុន្ទរកថារួច ក្រុមឆៃយ៉ាំបានចាប់ផ្តើមសម្តែងរហូតដល់ចប់ពិធី។ គេនាំគ្នារាំច្រៀងពេញទីធ្លាវត្ត។ នៅពេលខ្ញុំវិលត្រឡប់មកដល់ផ្ទះវិញបានបន្តិច ស្រាប់តែឮថា គេឱ្យផ្អាករាំច្រៀង ហើយនាំគ្នាចុះទៅធ្វើការលើកទំនប់ និងធ្វើស្រែវិញ។ កិច្ចការងារលើកទំនប់ ជីកប្រឡាយ ដកស្ទូង ច្រូតកាត់ និងដាំដំណាំកសិកម្ម គឺជាកិច្ចការងារស្នូលសម្រាប់ប្រជាជនក្នុងឃុំអង្គរសេ។ ប្រជាជនភាគច្រើន ត្រូវចាត់ចូលទៅក្នុងកងចល័តដែលតម្រូវឱ្យធ្វើការនៅតាមទីកន្លែងឆ្ងាយៗពីផ្ទះសម្បែង និងសម្រាកនៅក្បែរៗការដ្ឋានការងារ។ ប្រជាជនខ្លះទៀតដែលធ្វើការនៅក្នុងភូមិ ឬក្បែរៗភូមិ អាចមកសម្រាកជាមួយសមាជិកគ្រួសារនៅតាមផ្ទះរៀងខ្លួន»។

## ឌិន ផន  អាយុ៧៦ឆ្នាំ ជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សា ស្រះតាអឹម៖



«គេឱ្យខ្ញុំចូលរួមអបអរសាទរថ្ងៃជ័យជម្នះទី១៧ មេសា ១៩៧៥ហ្នឹងដែរ។ ខ្ញុំខំស្រែកជ័យយោសថា ជយោ! សម្តេចឪៗ។ អ្នកផ្សេងទៀត ក៏ស្រែកដូចខ្ញុំដែរ។ ប៉ុន្តែតាមការពិត មិនមានវត្តមានសម្តេចឪឯណា។ គណៈឃុំគេថ្លែងសុន្ទរកថានិយាយតែពីឈ្មោះ ប៉ុល ពត សោះ។ ខ្ញុំខកចិត្តជាខ្លាំងនៅថ្ងៃនោះ។ ប៉ុន្តែខ្ញុំមិនហ៊ានសួរ ឬតវ៉ា ឬនិយាយស្តីអ្វីទេ។ បន្ទាប់មក ប្រជាជនខ្លះត្រូវបង្ខំឱ្យធ្វើការស្រែចម្ការ និងទាហាន ហើយខ្ញុំនៅធ្វើស្រែក្នុងភូមិរហូតដល់បែកឆ្នាំ១៩៧៩»។

## ហាស់ ទឹម ភេទប្រុស អាយុ៨០ឆ្នាំ៖



«ក្នុងថ្ងៃ១៧ មេសា ១៩៧៥ ប្រធានលេខាឃុំគេជប់លៀងកាប់គោ ជ្រូក មាន់ទា ដើម្បីអបអរសាទរជ័យជម្នះ។ គេបើករបបឱ្យយើង។ គេហៅថារបបដែលទទួលបានដើម្បីអបអរសាទរថ្ងៃជ័យជម្នះ។ ឧបមាថាផ្ទះបាយអញ្ចឹង ទៅ គេអនុញ្ញាតឱ្យធ្វើជ្រូកមួយអញ្ចឹង។ ផ្ទះបាយនោះគេឱ្យធ្វើមាន់ ឬគោអ៊ីចឹងទៅ។ អាហ្នឹងគេហៅថាបើកកម្មវិធីអញ្ចឹង ដែលគេអនុញ្ញាតឱ្យយើងទទួលជ័យជម្នះ។ បើធ្វើ ( សម្លាប់) ជ្រូក គេចែកក្រុមនេះ ក្រុមនោះបន្តិចៗសួរចែកគ្នាហូប ប៉ុន្តែជ្រូក គោ និងមាន់ទា ជារបស់យើងទេ តែគេអនុញ្ញាតឱ្យយើងធ្វើហូបនៅថ្ងៃនោះ។ គេក៏អនុញ្ញាតឱ្យធ្វើនំអន្សមចែកគ្នាហូបដែរ។ ឧបមាថាយើងកូនប្រាំនាក់ ទាំងឪទាំងកូន៧ នាក់ចឹង គេចែកឱ្យបាន៧ ដែរ»។

# ថ្ងៃជម្លៀស១៧ ខែមេសា ឆ្នាំ១៩៧៥

## តាមការរៀបរាប់របស់ កៀក វ៉ាន អាយុ៧៦ឆ្នាំ រស់នៅក្នុងក្រុងភ្នំពេញ មុនពេលរបបខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសកម្ពុជា

**សោម ប៊ុនថន**

នៅពេលរបប លន់ នល់ ជិតដួលរលំ កងទ័ពរំដោះខ្មែរក្រហមបានផ្លោងគ្រាប់ចូលទីក្រុងភ្នំពេញស្ទើររាល់ថ្ងៃ។ ពេលនោះ ខ្ញុំរស់នៅជិតផ្សារដើមគរក្នុងទីក្រុងភ្នំពេញជាមួយប្ដីរបស់ខ្ញុំដែលធ្វើការនៅក្រុមហ៊ុនសាងសង់ផ្ទះរបស់ជប៉ុន។ ខ្ញុំចាំថា ខ្មែរក្រហមបានផ្លោងគ្រាប់ធ្លាក់នៅម្ដុំផ្សារអូរឫស្សី ដូច្នេះ ខ្ញុំមិនហ៊ានស្នាក់នៅផ្ទះជាន់ខាងលើដូចសព្វដងទេ ព្រោះខ្លាចគ្រាប់ផ្លោងធ្លាក់ចំ។ ថ្ងៃមួយ គ្រាប់ផ្លោងបានហោះរំលងលើផ្សារអូរឡាំពិក ទៅធ្លាក់នៅផ្សារដើមគរ បណ្ដាលឱ្យអ្នកលក់បន្លែ អាជីវករលក់ដូរក្នុងផ្សារព្រមទាំងប្រជាជនរងរបួស និងស្លាប់រណ្ដូករណែលនៅនឹងកន្លែងតែម្ដង។ នៅក្នុងហេតុការណ៍ផ្ទុះគ្រាប់ផ្លោងនោះ ខ្ញុំ និងប្ដីបានគេចខ្លួនទៅរស់នៅម្ដុំស្ទឹងមានជ័យ ហើយចាប់តាំងពីពេលនោះមកទីក្រុងភ្នំពេញមិនមានសុវត្ថិភាពទៀតទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ។ ភ្លាមៗ ខ្មែរក្រហមបានបញ្ជាខ្ញុំនិងប្ដីឱ្យចាកចេញពីផ្ទះដោយចោទគ្រួសារខ្ញុំថា ពួកមូលធន។ ខ្ញុំប្រមែប្រមូលអីវ៉ាន់ដាក់លើកញ្ជើដើម្បីទូល ហើយដៃម្ខាងពរកូនប្រុស និងដៃម្ខាងទៀតដឹកដៃកូន ចំណែកប្ដីរបស់ខ្ញុំបានរែករបស់របរដើរកាត់មកក្បាលថ្នល់ និងស្ពានព្រះមុនីវង្ស ដើម្បីឆ្លងទៅផ្លូវជាតិលេខ១សំដៅទៅស្រុកកំណើតនៅខេត្តស្វាយរៀង។ ខ្ញុំនឹកអាណោចអាធ័មខ្លាំងណាស់ពេលឃើញគំនរសាកសពដែលខ្មែរក្រហមប្រមូលពីទីក្រុងភ្នំពេញយកមកគរចោលនៅចម្ការអំពៅមួយកន្លែងនៅក្បាលថ្នល់។ ក្នុងចំណោមសាកសពទាំងនោះគឺមួយចំនួនកងទ័ពរំដោះខ្មែរក្រហមបាញ់សម្លាប់ចោលតែម្ដង។



កៀក វ៉ាន អាយុ៧៦ឆ្នាំ រស់នៅក្នុងភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនិងប្ដីដើររយៈពេលមួយសប្ដាហ៍ទើបមកដល់វត្តស្វាយជ្រំ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ កម្មាភិបាលខ្មែរក្រហមនៅទីនោះ បានរឹបអូសយករបស់របរ លុយកាក់ មាសប្រាក់ដែលខ្ញុំសន្សំទុក និងបានឃាត់ខ្លួនប្ដីរបស់ខ្ញុំ ព្រោះប្ដីរបស់ខ្ញុំគឺជាអតីត

សិស្សពូកែទទួលអាហារូបករណ៍ទៅរៀននៅប្រទេសជប៉ុននៅក្នុងរបបសង្គមរាស្ត្រនិយម។ ពេលរៀនចប់ប្តីរបស់ខ្ញុំបានត្រឡប់មកស្រុកខ្មែរវិញ និងធ្វើការជាមួយជនជាតិជប៉ុនរហូតមក។ ខ្ញុំដឹងថា នៅថ្ងៃនោះខ្មែរក្រហមបានអូសប្តីរបស់ខ្ញុំទៅវាយសម្លាប់ចោលនឹងគល់ឫស្សីនៅជិតកន្លែងឃាត់ខ្លួននោះតែម្តង។ ខ្ញុំអាឡោះអាល័យ និងអាណិតប្តីខ្ញុំខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនអាចជួយជីវិតគាត់បាន។ ខ្ញុំវិលវល់ក្នុងចិត្តពេលបាត់ប្តី ព្រោះខ្ញុំនៅសល់កូនតូចតែពីរនាក់តែប៉ុណ្ណោះ។ ខណៈនោះមានប្រជាជន១៧ មេសា ដែលជម្លៀសមកពីទីក្រុងភ្នំពេញជាមួយគ្នា អាណិតអាសូរខ្ញុំបានជួយរែករបស់របរដែលនៅសេសសល់បន្តមកដល់ទីរួមខេត្តស្វាយរៀង។ ឪពុករបស់ខ្ញុំបានមកទទួលខ្ញុំ និងបានសួររកប្តីរបស់ខ្ញុំ ហើយខ្ញុំបានប្រាប់គាត់ថា ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនហើយ។ ឪពុកខ្ញុំបាននាំខ្ញុំនិងចៅៗមករស់នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ និងខិតខំលាក់បាំងប្រវត្តិគ្រួសារខ្ញុំមិនឱ្យនរណាដឹងឡើយ។ កម្មាភិបាលខ្មែរក្រហមនៅមូលដ្ឋានបានចាត់តាំងខ្ញុំឱ្យធ្វើការនៅកងបុកស្រូវ ដោយសារឃើញខ្ញុំគឺជាស្ត្រីមេម៉ាយ។ ខ្ញុំបុកស្រូវក្នុងមួយថ្ងៃ៥តៅ ដើម្បីរែងយកអង្ករយកទៅដាក់នៅឃ្លាំងក្នុងភូមិ។

ខ្ញុំធ្វើការនៅក្នុងកងបុកស្រូវមិនយូរប៉ុន្មានទេ ព្រោះមានអ្នកមូលដ្ឋានដែលស្អប់និងគុំគួនខ្ញុំបានរាយការណ៍ទៅកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិថា គ្រួសារខ្ញុំធ្វើការនៅទីក្រុងភ្នំពេញ និងបានរៀនសូត្រដែលជាគោលដៅរបស់ខ្មែរក្រហម។ មួយរយៈខ្លីក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីភូមិមកទីក្រុងភ្នំពេញ ដើម្បីជិះរថភ្លើងបន្តឆ្ពោះទៅកាន់ខេត្តបាត់ដំបង ដែលជាកន្លែងសម្លាប់ និងលត់ដំធ្ងន់ធ្ងរបំផុត។ ខ្ញុំជិះរថភ្លើងជាមួយកូនពីរនាក់តាំងពីព្រឹករហូតដល់យប់ដោយមិនមានអាហារហូបឡើយ។ ខ្ញុំឈប់នៅចំណតរថភ្លើងខេត្តបាត់ដំបង ហើយខ្មែរក្រហមនៅមូលដ្ឋានបាននាំខ្ញុំទៅនៅសហករណ៍កំពង់ហៅ។ ខ្ញុំវេទនាខ្លាំងណាស់ ព្រោះប្រធានសហករណ៍ចាត់តាំង



កងទ័ពបដិវត្តន៍បានជម្លៀសប្រជាជនចេញពីផ្ទះសម្បែង បន្ទាប់ពីឡើងគ្រប់គ្រងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឱ្យគាស់រំលើងគល់ឈើធំៗនៅក្នុងព្រៃដោយដៃ។ បន្ទាប់មកទើបផ្លាស់ខ្ញុំទៅធ្វើការនៅកងកិនអង្ករ ដោយមានឈ្លបខ្មែរក្រហមចាំឃ្លាំមើលខ្ញុំជាប្រចាំ។ ចំណែកកូនរបស់ខ្ញុំដែលនៅកុមារនៅឡើយ ត្រូវបានប្រធានកងចាត់តាំងឱ្យទៅជីករណ្តៅកប់សាកសពប្រជាជនថ្មី ដែលឈ្លបខ្មែរក្រហមសម្លាប់នៅទួលអន្ទេប ហើយកូនរបស់ខ្ញុំដែលនៅតូចម្នាក់ទៀតប្រធានកងយកទៅទុកឱ្យយាយៗមើលថែនៅទួលដុប។ រយៈពេលពីរសប្តាហ៍ទើបខ្ញុំស្នើសុំប្រធានកងរបស់ខ្ញុំទៅមើលកូនតូចម្តង។ ប្រធានកងបានអនុញ្ញាត ប៉ុន្តែបានលីកាំបិតផ្គាក់ដើរតាមពីក្រោយខ្ញុំ។ ខ្ញុំឃើញកូនរបស់ខ្ញុំស្រេកឃ្លានខ្លាំងណាស់ ព្រោះមិនមានអាហារហូប។ ខ្ញុំបានជួបកូនខ្ញុំមួយភ្លែតតែប៉ុណ្ណោះ ក៏ប្រធានកងហៅខ្ញុំត្រឡប់មកជំរំវិញ។ នៅវេលាម៉ោង៣ទៀបភ្លឺ ប្រធានកងដាស់ខ្ញុំឱ្យក្រោកទៅជីកប្រឡាយ និងរែកដីបន្ត។ ទោះបីខ្ញុំធ្វើការហត់នឿយយ៉ាងណា ក៏ខ្ញុំមិនដែលបានអាហារហូបឆ្អែតដែរ។ នៅតំបន់ខ្ញុំរស់នៅ ប្រសិនបើនរណាហ៊ានលួចអាហារហូប ហើយឈ្លបតាមទាន់ នឹងមិនមានជីវិតរស់នៅឡើយ។ ជាក់ស្តែង ប្រពន្ធរបស់ពូយុនបានលួចពោតចំនួន៥ផ្លែលាក់នៅក្នុងថ្នក់សំពត់យកមកដុតហូបនៅជំរំ, ឈ្មោះ យ៉េន និងប្រពន្ធដែលកំពុងពរពោះ បានយកកូនជ្រូកងាប់របស់សហករណ៍ទៅធ្វើម្ហូបហូប ត្រូវឈ្លបយកទៅសម្លាប់ចោលទាំងអស់។

ក្រោយមក ប្រធានកងបានចាត់តាំងខ្ញុំឱ្យទៅប្រូតស្បូវភ្លាំងនៅពេលថ្ងៃ ដើម្បីយកមកក្រងប្រក់ជំរំនៅពេលយប់។ អំឡុងពេលខ្ញុំដើរទៅប្រូតស្បូវភ្លាំង ខ្ញុំឃើញសាកសពដែលឈ្លបខ្មែរក្រហមសម្លាប់ដោយជាប់ចំណងដៃទៅក្រោយ និងមិនទាន់កប់នៅពាសពេញវាល។ ខ្ញុំស្គាល់សាកសពចំនួនពីរនៅស្រុកកំណើតជាមួយខ្ញុំគឺឈ្មោះ តាម៉ង់ និងឈ្មោះ ឈុំ។ តាម៉ង មិនព្រមឱ្យផ្តិលដងទឹកដឹកទៅកូនកម្មាភិបាលខ្មែរក្រហមមូលដ្ឋាន ពេលកូនកម្មាភិបាលខ្មែរក្រហមមកខ្ចីផ្តិលនោះ និងឈ្មោះ ឈុំ គឺអ្នកធ្វើត្បាលកិនស្រូវឱ្យខ្មែរក្រហម ប៉ុន្តែកិនស្រូវមិនចេញ។ ឈ្លបខ្មែរក្រហមបានសម្លាប់ប្រជាជនថ្មីដែលជម្លៀសមកពីខេត្តស្វាយរៀងកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ខ្ញុំរស់នៅជាមួយសេចក្តីភ័យខ្លាចនិងទុក្ខព្រួយនៅសហករណ៍ក្នុងខេត្តបាត់ដំបង រហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមក នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំនាំកូនត្រឡប់មករស់នៅស្រុកកំណើតនៅខេត្តស្វាយរៀងវិញ។

ទោះបីរបបខ្មែរក្រហមបានកន្លងផុតយូរឆ្នាំមកហើយក៏ដោយ ក៏រឿងរ៉ាវដែលបានកើតឡើងក្នុងរបបនេះនៅតែដិតជាមអារម្មណ៍របស់ខ្ញុំ ទោះបីខ្ញុំខំព្យាយាមបំភ្លេចក៏ដោយ។ ខ្ញុំនៅតែចងចាំរឿងរ៉ាវជូរចត់របស់ខ្ញុំ ដែលខ្មែរក្រហមប្រើឱ្យធ្វើការងារធ្ងន់ធ្ងរ មិនឱ្យអាហារហូបឆ្អែត បំបែកខ្ញុំពីកូន និងយកប្តីរបស់ខ្ញុំទៅសម្លាប់។ ខ្ញុំចង់ឱ្យក្មេងៗជំនាន់ក្រោយយល់ដឹងពីរបបខ្មែរក្រហម និងបញ្ចៀសកុំឱ្យរបបនេះកើតឡើងម្តងទៀត។



កងទ័ពបដិវត្តន៍បានជម្លៀសប្រជាជនចេញពីផ្ទះសម្បែង បន្ទាប់ពីឡើងគ្រប់គ្រងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជនកម្ពុជាវិលត្រឡប់មករស់នៅស្រុកកំណើតវិញបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មុី អ៊ិន រំឭករឿងរ៉ាវដែលបានកើតឡើងក្នុងឃុំគគីរ

សោម ប៊ុនថន



មុី អ៊ិន អាយុ៩០ឆ្នាំ រស់នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីជាមានវ័យចំណាស់ និងសុខភាពមិនសូវរឹងមាំ ប៉ុន្តែ មុី អ៊ិន បានចងចាំរឿងរ៉ាវដែលបានកើតឡើងនៅក្នុងភូមិកំណើតរបស់គាត់តាំងពីគាត់នៅវ័យក្មេង រហូតដល់ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិឃុំរបស់គាត់។

មុីអ៊ិនមានអាយុ៩០ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង បានរៀបរាប់ថា៖ នៅពេលកងទ័ពជប៉ុនចូលមកប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ ខ្ញុំធំដឹងក្តីហើយ។ សម័យនោះប្រជាជននៅក្នុងភូមិមានការខ្វះខាតខ្លាំងណាស់ សូម្បីតែខោអាវក៏គ្មានស្លៀកពាក់សមរម្យដែរ។ ប្រជាជនមួយចំនួនបានយកបាវបុស្តិ៍កឈើមកបិទបាំងរាងកាយ។ ផ្ទះរបស់ខ្ញុំស្ថិតនៅជិតវត្តគគីរ និងមានផ្ទះយាយអុំ ផ្ទះតាសុក និងផ្ទះតាទក នៅក្បែរនោះដែរ។ ប្រជាជននៅក្នុងភូមិដែលមានជីវភាពក្រីក្រលំបាក គ្មានអំបិល ប្រហុក ហូបចុក និងគ្មានសម្លៀកបំពាក់ បាននាំគ្នាមកស្នើសុំសំបុត្របញ្ជាក់ (បុប៉ុង) ពីឪពុករបស់ខ្ញុំឈ្មោះ ប៉ាក់ គឺជាមេភូមិដែលសម័យនោះប្រជាជនបានហៅឆ្មាររបស់គាត់ថា ជិទប់ ប៉ុចៅក្រម។ បន្ទាប់មក ប្រជាជនក្នុងភូមិបាន

កាន់សំបុត្របញ្ជាក់ទាំងនោះទៅទិញអាហារ របស់របរប្រើប្រាស់ សម្លៀកបំពាក់ក្នុងតម្លៃថោកៗ ជាមួយក្រដាសប្រាក់មួយកាក់ និងពីរកាក់ៗ ប៉ុន្តែការលក់ដូរគឺមានការកំណត់ ដូច្នេះប្រជាជនទិញសម្រាប់តែហូបចុក និងប្រើប្រាស់តែប៉ុណ្ណោះៗ នៅថ្ងៃមួយ មានយន្តហោះចម្បាំងជប៉ុនចំនួន៣គ្រឿង បានហោះពីទិសខាងកើតឆ្ពោះទៅទិសខាងលិច ដើម្បីធ្វើសង្គ្រាមជាមួយកងទ័ពបារាំងៗ ខ្ញុំនិងចាស់ទុំក្នុងភូមិបាននាំគ្នាអង្គុយមើលហេតុការណ៍វាយប្រយុទ្ធគ្នានោះនៅលើភ្លឺស្រែ និងឃើញយន្តហោះចម្បាំងមួយគ្រឿងត្រូវគ្រាប់ហើយយន្តហោះចម្បាំងពីរផ្សេងទៀតហោះមកអមៗ នៅពេលកងទ័ពជប៉ុនចេញទៅអស់ ខ្ញុំឃើញចលនាឥស្សរកើតឡើងក្នុងឃុំគគីរ ចំណែករាជការអាណាព្យាបាលបារាំងនៅធ្វើការនៅទីប្រជុំជនក្នុងឃុំកំពង់ត្រាច ស្រុករមាសហែក ហើយតែងតែជិះសេះដើរត្រួតពិនិត្យ និងទារពន្ធពីប្រជាជននៅតាមភូមិៗ ក្រុមឥស្សរបានចូលមកកេណ្ឌប្រជាជននៅក្នុងភូមិរបស់ខ្ញុំ និងភូមិនៅក្បែរៗវត្តគគីរៗ រីឯខ្ញុំនិងក្រុមគ្រួសារត្រូវសែប (មន្ត្រីយោធាបម្រើឱ្យរាជការអាណាព្យាបាលបារាំង) ដែលស្គាល់ឪពុករបស់ខ្ញុំបានមកយកក្រុមគ្រួសាររបស់ខ្ញុំទៅរស់នៅភូមិបាតត្រាស់ក្បែរប៉ុស្តិ៍យាមរបស់ទាហានបារាំង ស្ថិតនៅក្នុងឃុំដូងៗ ទន្ទឹមនោះ ប្រជាជនក្នុងភូមិត្រពាំងស្គន់មួយចំនួនទៀតត្រូវបារាំងកេណ្ឌទៅរស់នៅឃុំកំពង់ត្រាចៗ ក្រុមឥស្សរបានកេណ្ឌមនុស្សពេញវ័យ និងកម្លោះៗទៅកាប់ផ្តាច់ផ្លូវ និងរើស្ពានមិនឱ្យមន្ត្រីបារាំងជិះសេះចូលក្នុងភូមិឡើយៗ

រហូតដល់ក្រុមឥស្សរចេញអស់ទើបខ្ញុំនិងគ្រួសារត្រឡប់មករស់នៅភូមិត្រពាំងស្គន់វិញៗ ខ្ញុំរៀបការប្តីនៅពេលខ្ញុំអាយុបាន២០ឆ្នាំៗ ប្តីរបស់ខ្ញុំឈ្មោះ សូត្ររស់នៅក្នុងឃុំគគីរជាមួយខ្ញុំដែរៗ អំឡុងពេលនោះស្រាប់តែខ្ញុំឃើញកងទ័ពវៀតកុង (វៀតណាមខាងជើង) បានចូលមករស់នៅក្នុងភូមិ និងបណ្តោយមាត់ទន្លេក្នុងឃុំគគីរ ហើយសង្គ្រាមក៏ចាប់ផ្តើមផ្ទុះឡើងៗ ខ្ញុំនិងឪពុកម្តាយបាននាំគ្នារត់ទៅលាក់ខ្លួននៅប្រឡាយប្រឡាយប្រឡាយ

បរបរទេះនៅវាលឈើទាល និងនៅតាមបណ្តោយមាត់ទន្លេក្នុងឃុំគគីរៗ នៅពេលថ្ងៃឪពុករបស់ខ្ញុំបានដើរទៅផ្ទះនៅក្នុងភូមិស្គន់ដើម្បីប្រមូលចាន ឆ្នាំង ត្បាល់ និងអង្រែ យកមកបុកស្រូវដើម្បីដាំបាយ ហូបនៅវាលស្រែៗ ពេលយប់យន្តហោះចម្បាំងបានហោះភ្លៃលនៅលើឃុំគគីរ និងបាញ់ភ្លើងហ្វា ដើម្បីតាមរកកងទ័ពវៀតកុងដែលលាក់ខ្លួននៅក្នុងភូមិៗ បន្ទាប់មក យន្តហោះចម្បាំងផ្សេងទៀតបានហោះមកទម្លាក់គ្រាប់បែកបេ៥២ ធ្វើឱ្យប្រជាជនភិតភ័យយ៉ាងខ្លាំងៗ ឪពុករបស់ខ្ញុំនិងប្រជាជនបាននាំគ្នាជីកត្រង់សេ ឬលេណដ្ឋានដើម្បីលាក់ខ្លួនៗ ខ្ញុំជួបការលំបាកខ្លាំងណាស់ពេលរត់គេចពីការទម្លាក់គ្រាប់បែកម្តងៗព្រោះកូនរបស់ខ្ញុំនៅតូចៗៗ

នៅពេលខ្មែរក្រហមចូលគ្រប់គ្រងឃុំគគីរ ខ្មែរក្រហមមិនបានជម្លៀសខ្ញុំទៅកន្លែងផ្សេងទេៗ ខ្មែរក្រហមបានបញ្ចូលខ្ញុំក្នុងក្រុមប្រវាស់ដៃ និងបានជ្រើសរើសខ្ញុំឱ្យធ្វើជាប្រធានក្រុមៗ ក្នុងមួយក្រុមប្រវាស់ដៃមាននារីចំនួន១២នាក់ៗ ខ្ញុំដឹកនាំក្រុមនារីកាប់ដីចម្ការដាំដំណាំៗ នៅពេលសម្រាកខ្ញុំត្រូវដឹកនាំក្រុមនារីប្រជុំណែនាំឱ្យចេះស្រឡាញ់រាប់អានគ្នា សាមគ្គីគ្នា និងជួយគ្នាទៅវិញទៅមកមុនពេលត្រឡប់ទៅសម្រាកនៅតាមផ្ទះរៀងៗខ្លួនវិញៗ ចំណែករបបអាហារគឺសមាជិកក្រុមប្រវាស់ដៃធ្វើហូបនៅតាមផ្ទះរៀងៗខ្លួន ហើយអាចបេះបន្លែបង្ការ បេកត្រឡាច យកមកធ្វើម្ហូបបានៗ

ក្រោយមក ខ្មែរក្រហមបានប្រមូលស្រូវអង្ករ ជ្រូក មាន់ ទា គោ ក្របី និងទ្រព្យសម្បត្តិមកដាក់រួមៗ កម្មាភិបាលខ្មែរក្រហមបានដើរពិនិត្យ និងសួរប្រជាជននៅតាមផ្ទះអំពីចំនួនអង្ករ ហើយប្រសិនបើនរណាម្នាក់កុហកកម្មាភិបាលខ្មែរក្រហមនឹងចោទអ្នកនោះថាលួចលាក់ទុកឱ្យខ្លាំង និងយកទៅសម្លាប់ចោលតែម្តងៗ ពេលដល់ម៉ោងបើករបបអាហារ ប្រធានកងបានគោះជួងជាសញ្ញាឱ្យកងចល័តទាំងអស់ទៅបើករបបពីចុងភៅនៅរោងបាយរួមៗ ក្នុងមួយថ្ងៃខ្ញុំទទួលបានរបបពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាចៗ ប៉ុន្តែរបបអាហារទាំងនោះមិនអាចឱ្យខ្ញុំ និងប្រជាជនហូបគ្រប់គ្រាន់ទេៗ

មួយរយៈក្រោយមក ខ្មែរក្រហមក៏ឱ្យខ្ញុំនៅកង

បុកស្រូវនៅក្នុងភូមិ ដោយសារខ្ញុំមានកូនច្រើនរហូតដល់ទៅចំនួន៨នាក់, ប្តីរបស់ខ្ញុំនៅរោងបាយរួម ហើយកូនៗរបស់ខ្ញុំខ្លះនៅកងចល័ត និងខ្លះទៀតចូលបម្រើកងទ័ពខ្មែរក្រហម។ ពេលខ្ញុំធ្វើការនៅកងបុកស្រូវ ខ្ញុំប្រាប់សមាជិកក្នុងកងឱ្យវែងយកកន្ទក់ហូត់ទុកលាយជាមួយត្នោតទុំដើម្បីស្ងោរចែកគ្នាហូប និងមួយចំណែកទៀតយកទៅឱ្យឈ្លបខ្មែរក្រហមដែលយាមនៅក្នុងភូមិ។

បន្ទាប់មកខ្មែរក្រហមបានផ្លាស់ខ្ញុំពីកងបុកស្រូវទៅនៅកងស្ទូងស្រូវ លើកភ្លឺស្រែ និងជីកប្រឡាយ នៅព្រៃគុយ និងនៅព្រៃក្តី។ ខ្ញុំត្រូវជីកដីជម្រៅត្រឹមជង្គង់ និងប្រវែង៥ម៉ែត្រ។ ខ្ញុំធ្វើការងារនៅក្នុងស្រុករមាសហែករហូតដល់ឆ្នាំ១៩៧៨ ទើបខ្មែរក្រហមជម្លៀសខ្ញុំទៅរស់នៅ និងធ្វើការនៅខាងកើតស្រុកបាភ្នំ ខេត្តព្រៃវែង។ ខ្ញុំរស់នៅទីនោះបានមួយរយៈ ស្រាប់តែឮសំឡេងផ្ទុះឃ្លាំងគ្រាប់របស់ខ្មែរក្រហមនៅអ្នកលឿង និងឃើញផ្កាភ្លើងពាសពេញផ្ទៃអាកាស ធ្វើឱ្យប្រជាជនជម្លៀសច្របូលច្របល់។ ខណៈនោះមានបុរសចំណាស់ម្នាក់ស្រែកប្រាប់ខ្ញុំថា បងប្អូនមកពីស្រុកណាសូមអញ្ជើញត្រឡប់ទៅរស់នៅស្រុកនោះវិញចុះ ព្រោះប្រទេសជាតិត្រូវបានរំដោះហើយ។ ចំណែកកម្មាភិបាលខ្មែរក្រហមហាមមិនឱ្យប្រជាជនវិលត្រឡប់មកស្រុកកំណើតទេ ដោយឃោសនាប្រាប់ថា កងទ័ពវៀតណាមនឹងវះពោះញាត់ស្មៅ។ ប្រជាជនជម្លៀសមួយចំនួនបានជឿ និងរត់គេចខ្លួនទៅតាមខ្មែរក្រហម ទាំងនោះហើយខ្លះបានស្លាប់ពេលឆ្លងទន្លេអ្នកលឿង។ ចំណែកខ្ញុំបានវិលត្រឡប់មកស្រុកកំណើត និងបានជួបជុំឪពុកម្តាយ បងប្អូន និងកូនៗវិញ។ សព្វថ្ងៃនេះ ខ្ញុំគឺជាស្ត្រីមេម៉ាយព្រោះប្តីរបស់ខ្ញុំស្លាប់កាលពី៩ឆ្នាំមុនដោយសារជំងឺ។ បន្ទាប់ពីប្តីខ្ញុំស្លាប់ទៅ ខ្ញុំរស់នៅជាមួយកូនស្រីដែលកំពុងមានជំងឺប្រចាំកាយ។



ផ្ទះរបស់ មុី អ៊ិន នៅភូមិត្រពាំងស្គន់ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុខ ជិន ៖ បានរស់ជីវិតដោយសារកុហកថា អ្នកឡើងត្នោត

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ សុខ ជិន កើតនៅឆ្នាំ១៩៥១ នៅភូមិរាជមន្ទីរ ឃុំរាជមន្ទីរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ កាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្រួសារខ្ញុំមានជីវភាពខ្វះខាត។ ខ្ញុំនៅជួយធ្វើស្រែឪពុកម្ដាយនៅផ្ទះ។ ខ្ញុំចាំថាភូមិរបស់ខ្ញុំចាប់ផ្ដើមច្របូកច្របល់នៅពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ រីឯសម្ដេចព្រះ នរោត្តម សីហនុ ក៏បានអំពាវនាវពីទីក្រុងប៉េកាំង ប្រទេសចិនឱ្យកូនចៅដែលគាំទ្រព្រះអង្គចូលព្រៃម៉ាកគីដើម្បីតស៊ូប្រឆាំងនឹង លន់ នល់ វិញ។ ចាប់តាំងពីពេលនោះមក នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្ដើមរងគ្រោះដោយសារការវាយប្រយុទ្ធគ្នានៅក្នុងប្រទេស និងសង្គ្រាមរវាងកងទ័ពវៀតកុង (វៀតណាមខាងជើង) ដែលគាំទ្រខ្មែរក្រហម និងកងទ័ពធីវគីប្កកងទ័ពរដ្ឋការ (វៀតណាមខាងត្បូង) ដែលគាំទ្ររបប លន់ នល់។ កងទ័ពធីវគី បានបាញ់ផ្លោង និងទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់សំដៅលើកងទ័ពវៀតកុងនៅក្នុងទឹកខ្មែរ។ ប៉ុន្តែគ្រាប់បែក និងគ្រាប់ផ្លោងទាំងនោះបានធ្វើឱ្យខូចខាតផ្ទះសម្បែងប្រជាជនក្នុងភូមិ ងាប់គោក្របី ជ្រូក មាន់ទា រងរបួស និងស្លាប់ប្រជាជនកម្ពុជាជាច្រើននាក់។ ភ្លាមៗនោះ ឪពុកម្ដាយរបស់ខ្ញុំ បាននាំខ្ញុំរត់គេចខ្លួនចេញពីផ្ទះសម្បែងព្រោះភ័យខ្លាចជួបគ្រោះថ្នាក់។

ក្រោយមក ខ្ញុំបានសម្រេចចិត្តចូលរួមតស៊ូជាមួយកងទ័ពវៀតកុងនៅក្នុងភូមិរបស់ខ្ញុំដើម្បីវាយតទល់នឹងរបប លន់ នល់ ទាមទារយកសម្ដេចព្រះនរោត្តម សីហនុ មកដឹកនាំប្រទេសជាតិវិញ។ ខ្ញុំបានរស់នៅក្នុងព្រៃនៅជាយៗភូមិ និងឡើងទៅវាយប្រយុទ្ធនៅសមរភូមិជាញឹកញាប់។ ខ្ញុំធ្វើការជាមួយកងទ័ពវៀតកុងបានរយៈពេលមួយឆ្នាំ ក៏ត្រូវកងទ័ពធីវគីចាប់ខ្លួនខ្ញុំបានរួចហើយបញ្ជូនខ្ញុំទៅឱ្យកងទ័ព លន់ នល់ នៅក្រុងស្វាយរៀង។ ខ្ញុំបានជាប់ឃុំឃាំងរយៈពេលកន្លះខែ ស្រាប់តែរដ្ឋាភិបាល លន់ នល់ កំពុងខ្វះខាតទ័ពបានប្រកាសជ្រើសរើសកងទ័ពមកបំពេញបន្ថែម និងមានកងទ័ព លន់ នល់ ម្នាក់បានមកប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំស្ម័គ្រចិត្តចូលបម្រើនៅក្នុងអង្គភាពទ័ព លន់ នល់ មេបញ្ជាការខេត្តស្វាយរៀងនឹងដោះលែងខ្ញុំឱ្យមានសេរីភាពវិញ។ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ព លន់ នល់ ព្រោះខ្ញុំមិនចង់រងការលំបាកតទៅមុខទៀត ចំណែកអ្នកដែលមិនព្រមចូលកងទ័ព គឺនៅជាប់ឃុំឃាំងក្នុងគុកដដែល។ បន្ទាប់មក មេបញ្ជាការកងទ័ព លន់ នល់ នៅខេត្តស្វាយរៀងបានបញ្ជូនខ្ញុំទៅ



សុខ ជិន សព្វថ្ងៃរស់នៅភូមិកណ្ដាល សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ៊ឹកហាត់ក្បួនយុទ្ធសាស្ត្រកងទ័ព នៅបន្ទាយកងទ័ពព្រៃសជិតក្រុងភ្នំពេញ។ ពេលខ្ញុំហ៊ឹកហាត់ចប់ មេបញ្ជាកងទ័ព លន់ នល់ នៅភ្នំពេញបានបញ្ជូនខ្ញុំឡើងទៅវាយតទល់ជាមួយខ្មែរក្រហម និងកងទ័ពវៀតកុងនៅសមរភូមិខេត្តតាកែវ ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងសមរភូមិមួយចំនួនទៀត។

នៅឆ្នាំ១៩៧១ ខ្ញុំបានរៀបការជាមួយប្រពន្ធនៅភ្នំបាសិទ្ធ ស្ថិតនៅក្នុងភូមិតាពេជ្រ ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល។ បន្ទាប់ពីរៀបការរួច ខ្ញុំនៅបម្រើអង្គភាពទ័ព លន់ នល់ រហូតដល់កងទ័ពខ្មែរក្រហមបាញ់សម្រុកចូលបន្ទាយរបស់ខ្ញុំនៅព្រៃស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្ញុំផ្លាស់ប្តូរសម្លៀកបំពាក់មកស៊ីវិល រួចហើយភៀសខ្លួនចេញពីបន្ទាយមកអូរបែកក្អម។ ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមដែលកំពុងឡោមព័ទ្ធទីក្រុងភ្នំពេញ និងឈរជើងនៅអូរបែកក្អម ភ្ជង់កាំភ្លើង និងសួរខ្ញុំថា តើធ្វើការងារអ្វី? ដំបូងខ្ញុំបានកុហកកងទ័ពខ្មែរក្រហមថា ខ្ញុំគឺជាសិស្សសាលា ទើបកងទ័ពខ្មែរក្រហមមិនចាប់ខ្លួនខ្ញុំ។ ខ្ញុំបានធ្វើដំណើរមកខេត្តតាកែវ តាមការជម្លៀសរបស់កងទ័ពខ្មែរក្រហម បន្ទាប់មកទើបខ្ញុំដើរកាត់តាមព្រែកតូចក្នុងស្រុកស្អាងខេត្តកណ្តាល សំដៅទៅខេត្តស្វាយរៀងវិញ។ ខ្ញុំបានបែកពីប្រពន្ធកូនចាប់តាំងពីពេលនោះមក។ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំបានធ្វើដំណើរមកដល់ស្រុកកំណើតនៅភូមិរាជមន្ទីរវិញ ប៉ុន្តែខ្ញុំមិនបានជួបឪពុកម្តាយនិងបងប្អូនទេ។ ទោះបីយ៉ាងណា ខ្ញុំមិនហ៊ានស្នាក់នៅក្នុងភូមិកំណើតទេ ព្រោះខ្លាចខ្មែរក្រហមស្រាវជ្រាវដឹងថាខ្ញុំធ្លាប់ធ្វើទាហាន លន់ នល់។ ខ្ញុំបានគេចខ្លួនមកដល់ភូមិធ្នល់ សង្កាត់ចេក ក្រុងស្វាយរៀងវិញ។ នៅទីនោះ មានបុរសចំណាស់ម្នាក់បានហៅខ្ញុំឱ្យស្នាក់នៅជាមួយ។ រយៈពេល៣ថ្ងៃក្រោយមក ខ្មែរក្រហមបានបណ្តេញខ្ញុំចេញពីក្រុងស្វាយរៀងម្តងទៀតដោយប្រាប់ថា បើខ្ញុំរស់នៅស្រុកណាត្រូវត្រឡប់ទៅរស់នៅក្នុងស្រុករបស់ខ្លួនវិញ។ ដំបូងខ្ញុំមិនដឹងថាតើត្រូវទៅរស់នៅទីកន្លែងណាឡើយ។ មួយសន្ទុះក្រោយមកទើបខ្ញុំបានទទួលដំណឹងថា មានបងប្អូនរបស់ខ្ញុំរស់នៅភូមិគ្គីស្លា ឃុំស្វាយយា ស្រុកស្វាយជ្រំ ទើបខ្ញុំសុំខ្មែរក្រហមធ្វើដំណើរទៅរកបងប្អូនរបស់ខ្ញុំនៅទីនោះ។ ម្យ៉ាងទៀត ខ្ញុំគិតថានៅភូមិគ្គីស្លាស្ថិតនៅឆ្ងាយពីស្រុកកំណើតខ្ញុំ ដូច្នេះខ្មែរក្រហមមិនដឹងថាខ្ញុំធ្វើទាហាន លន់ នល់ ឡើយ។

ពេលខ្ញុំទៅដល់សហករណ៍គ្គីស្លា ប្រធានសហករណ៍បានសួរខ្ញុំថា «មិត្តឯងធ្វើការងារអ្វីកាលពីជំនាន់ លន់ នល់»? ពេលនោះខ្ញុំកុហកប្រធានសហករណ៍ខ្មែរក្រហមជាលើកទី២ ដោយប្រាប់ថា ខ្ញុំគឺជាអ្នកឡើងត្នោត។ ប្រធានសហករណ៍បានសំឡឹងមើលខ្ញុំលើក្រោមមិនដាក់ភ្នែក និងសួរបញ្ជាក់តើមិត្តនិយាយពិតឬទេ? ប្រសិនបើមិត្តនិយាយមិនពិត ហើយយើងស៊ើបដឹងថ្ងៃក្រោយ មិត្តត្រូវទទួលទោស គឺវាយដប់គល់ឬស្សីរាប់មួយ។ ទន្ទឹមនោះ ក៏មានបងប្អូនរបស់ខ្ញុំជួយស្នើសុំប្រធានសហករណ៍នោះឱ្យខ្ញុំបានរស់នៅក្នុងសហករណ៍គ្គីស្លាដែរ។ ដំបូងប្រធានសហករណ៍ប្រាប់ខ្ញុំថាអង្គការឱ្យមិត្តទៅរៀនសូត្រ ភ្លាមនោះខ្ញុំតបថាមិនមានប៊ិចសៀវភៅសម្រាប់សរសេរ និងកត់ត្រាទេបង។ ប្រធានសហករណ៍តបថា នៅទីនោះមានទាំងអស់។ នៅពេលប្រធានសហករណ៍ប្រមូលមនុស្សបានច្រើន ហើយក៏ប្រាប់ថា មិត្តត្រូវទៅយកប៊ិចសៀវភៅ ស្រាប់តែពេលនោះខ្ញុំឃើញខ្មែរក្រហមបោះបង្គីពីលើរថយន្តដោយប្រាប់ខ្ញុំថានេះគឺសៀវភៅ ចំណែកចបគឺជាប៊ិច។ នៅព្រឹកបន្ទាប់ ប្រធានកងខ្មែរក្រហមវាស់ដី និងចាត់តាំងខ្ញុំឱ្យជីកប្រឡាយនៅព្រះទន្លេ នៅស្វាយផ្អែម និងនៅរបោះព្រីង។ ខ្ញុំចូលធ្វើការពីព្រឹកព្រលឹម ដល់ម៉ោង១១ទើបឈប់សម្រាកហូបបាយ ហើយចូលធ្វើការវិញនៅម៉ោង១រសៀល ដល់ម៉ោង៥ល្ងាច។ ចំណែករបបអាហារមានតែបបរពីរពេលប៉ុណ្ណោះ គឺពេលថ្ងៃត្រង់ និងពេលល្ងាចហូបជាមួយសម្ល។ ខ្ញុំដើរទៅធ្វើការស្ទើរមិនរួច ដោយសារខ្ញុំមិនមានអាហារហូបគ្រប់គ្រាន់។ ទោះបីខ្ញុំធ្វើការហត់នឿយយ៉ាងណាក៏មិនហ៊ានឈប់សម្រាកដែរ ព្រោះខ្មែរក្រហមនៅចាំឃ្លាំមើលជាប្រចាំ។ ប្រសិនបើខ្មែរក្រហមឃើញនរណាម្នាក់នៅក្នុងកងឈរលេងមិនធ្វើការ ខ្មែរក្រហមនឹងវាយអ្នកនោះ រួចហើយយកទៅអប់រំកែប្រែ ប៉ុន្តែតាមពិតខ្មែរក្រហមយកទៅសម្លាប់ចោលនៅព្រៃក្បែរកន្លែងខ្ញុំធ្វើការ និងកប់នៅកន្លែងនោះតែម្តង។ ខ្ញុំបានដឹងរឿងនេះដោយសារឈ្លបខ្មែរក្រហមយកខោអាវអ្នកស្លាប់មកចែកឱ្យប្រជាជនក្នុងភូមិស្លៀកពាក់ ហើយខ្ញុំក៏ស្គាល់ខោអាវទាំងនោះដែរ។ ថ្ងៃមួយ

ខ្ញុំបានធ្លាក់ខ្លួនឈឺគ្រុន និងរាកមួលធ្ងន់ធ្ងរ ដូច្នេះប្រធានកងប៉ានអនុញ្ញាតឱ្យខ្ញុំទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យអង្គបុស្ស ក្នុងភូមិរបោះព្រីង ឃុំស្វាយយា។ ពេទ្យបានផ្តល់ថ្នាំអាចម៌ទន្សាយឱ្យខ្ញុំលេប និងផ្តល់របបអាហារឱ្យខ្ញុំហូប។ ខ្ញុំដេកពេទ្យរយៈពេលបួនថ្ងៃក៏ត្រឡប់មកអង្គភាពវិញ។

បន្ទាប់ពីខ្ញុំជីកប្រឡាយរយៈពេល៣ខែនិងចប់តាមផែនការ ខ្មែរក្រហមបានជ្រើសរើសអ្នកបេះឡើងត្នោត ហើយខ្ញុំក៏ស្នើសុំខ្មែរក្រហមចូលធ្វើការនៅអង្គភាពផលិតស្ករត្នោតនៅសហករណ៍ក្តីស្លា។ ពេលនោះ ការរស់នៅរបស់ខ្ញុំបានប្រសើរជាងមុនដោយសារខ្ញុំអាចផឹកទឹកត្នោត និងហូបស្ករត្នោតដែលកងរបស់ខ្ញុំផលិតបាន។ ថ្ងៃមួយពេលខ្ញុំឡើងយកទឹកត្នោត ខ្ញុំបានឃើញឈ្លបខ្មែរក្រហមបណ្តើរអ្នកទោសជាច្រើននាក់តាមភ្លឺស្រែដោយមានឈ្លបម្នាក់ដើរពីមុខ និងម្នាក់ទៀតដើរពីក្រោយអ្នកទោស។ ខ្ញុំឃើញអ្នកទោសខ្លះដើរស្ទើរតែមិនរួច ដោយសារតែហត់ហេវ និងគ្មានកម្លាំង។ អំឡុងពេលនោះ ខ្ញុំឃើញអ្នកទោសម្នាក់ដែលស្រេកឃ្លានខ្លាំងពេក បានបូតស្រូវទុំដែលដុះនៅប្របភ្លឺស្រែហូប ស្រាប់តែឈ្លបខ្មែរក្រហមក្រឡេកឃើញក៏វាយអ្នកទោសនោះ និងបាញ់សម្លាប់ចោលតែម្តង។ ខ្ញុំសំងំនៅលើចុងត្នោត និងរង់ចាំរហូតឈ្លបខ្មែរក្រហមបណ្តើរអ្នកទោសដែលនៅរស់ទៅអស់ ទើបខ្ញុំចុះពីលើចុងត្នោត។ ចំពោះស្ករត្នោតដែលអង្គភាពរបស់ខ្ញុំផលិតបាន ខ្មែរក្រហមយកទៅទុកនៅរោងបាយសហករណ៍។ រយៈពេលមួយពីរខែ ទើបចុងភៅនៅសហករណ៍កាប់ជ្រូកធ្វើម្ហូប និងដាំបាយឱ្យប្រជាជនហូបឆ្អែតម្តង។ ប្រជាជនមួយចំនួនបានហូបបាយរហូតដល់ហល់ ដោយសារតែស្រេកឃ្លានខ្លាំងពេក និងមិនដែលបានហូបឆ្អាញ់។

នៅថ្ងៃមួយមានបុរសម្នាក់ឈ្មោះ វ៉ាត់ មានស្រុកកំណើតនៅឃុំស្វាយរំពារ ស្រុកស្វាយទាប ដែលបានស្គាល់ខ្ញុំពេលធ្វើការនៅកងចល័តជាមួយគ្នា បានរត់គេចចេញពីកងមកដេកជាមួយខ្ញុំ។ ស្រាប់តែពេលក្បាលព្រលប់ ឈ្លបខ្មែរក្រហមចំនួន៤នាក់មកចាប់បុរសនោះទៅវាយសួរចម្លើយ ដោយចោទថាលួចផ្លែដូងរបស់សមូហភាពហូប។ នៅព្រឹកថ្ងៃបន្ទាប់ ឈ្លបខ្មែរក្រហមយក វ៉ាត់ ទៅវាយចោល។ ចំណែកខ្ញុំព្រួយបារម្ភយ៉ាងខ្លាំងព្រោះខ្លាចក្រែង វ៉ាត់ ឆ្លើយដាក់ខ្ញុំ។ រៀងរាល់ក្បាលព្រលប់ ខ្ញុំតែងតែសំឡឹងមើលផ្លូវនៅខាងមុខខ្ទមស្នាក់នៅ ព្រោះខ្លាចក្រែងឈ្លបមកចាប់ខ្លួនខ្ញុំបន្តទៀត។ រយៈពេល៣ថ្ងៃក្រោយមក ទើបខ្ញុំបានរសាយចិត្តវិញ។ រំលងបានមួយខែក្រោយមកទៀត មានប្រជាជននៅមូលដ្ឋានមកប្រាប់ខ្ញុំឱ្យនៅមើលភ្លើងរំងាស់ស្ករត្នោតជាមួយឈ្មោះ ប្រីក បន្ទាប់ពីខ្ញុំឡើងយកទឹកត្នោតនិងវែកមករោងរំងាស់ស្កររបស់សហ-ករណ៍ ព្រោះអ្នកទាំងនោះត្រូវទៅហូបបាយ។ បន្ទាប់ពីប្រជាជនមូលដ្ឋានហូបបាយរួច ស្រាប់តែឃើញឈ្លបយកកាំភ្លើងដែលព្យួរនៅរោងបាយតម្រង់មកចំយើងដែលកំពុងដុតភ្លើងរំងាស់ស្ករ។ ខ្ញុំស្លេកស្លាំងនិងភ័យញ័រទទ្រើកនិយាយមិនចេញ។ ពេលដើរមកកាន់តែកៀក ឈ្លបខ្មែរក្រហមក៏កាច់សោកាំភ្លើង និងស្រែកគំរាមដាក់យើង។ ខ្ញុំបានលើកដៃទាំងពីរឡើងលើ និងរកកល់ងងឹតមុខមើលអ្វីលែងឃើញនៅពេលនោះដែរ។ រំពេចនោះឈ្លបខ្មែរក្រហមស្រែកចំឈ្មោះថា តាប្រីក លើកដៃ! តាប្រីក បានតបថា ហេតុអ្វីបានជាក្មួយធ្វើដូច្នេះ? ព្រោះឈ្លបនោះត្រូវជាក្មួយរបស់ តាប្រីក។ ឈ្លបនៅតែស្រែកគំរាមឱ្យ តាប្រីក លើកដៃ និងលុតជង្គង់ និងចោទ តាប្រីក ថាជាប់សន្ទិសម្ព័ន្ធជាមួយខ្មាំង។ ឈ្លបបានទាត់ តាប្រីក បីជើង និងយកក្រមាចងមុខតាប្រីក រួចហើយ ឱ្យតាប្រីក រត់តាមពីក្រោយកង់ចេញទៅបាត់។ ចំណែកខ្ញុំនៅឈរទ្រឹង និងលើកដៃដដែលដោយសារតែតក់ស្លុតខ្លាំងពេក ព្រោះខ្ញុំគឺជាប្រជាជនថ្មីដែលជាគោលដៅចាប់ខ្លួនរបស់ខ្មែរក្រហម។ ខ្ញុំបានរួចរស់ជីវិត និងធ្វើការនៅសហករណ៍ក្តីស្លារហូតដល់កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមវាយចូលមករំដោះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅអំឡុងពេលច្របូកច្របល់ ប្រធានសហករណ៍ក្តីស្លាត្រូវបានប្អូនថ្លៃកាប់សម្លាប់ ព្រោះសងសឹកនឹងការប្រព្រឹត្តមកលើខ្លួនក្នុងរបបខ្មែរក្រហម។

នៅឆ្នាំ១៩៨០ ខ្ញុំបានជួបជុំប្រពន្ធកូនវិញ។ ខ្ញុំបានមករស់នៅភូមិកណ្តាល សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដោយប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ ទោះបីរបបខ្មែរក្រហមបានកន្លងផុតរយៈពេលជាច្រើនឆ្នាំហើយក៏ដោយ ក៏ខ្ញុំនៅតែចងចាំអំពីការធ្ងន់ធ្ងរ ការអត់ឃ្លាន ការហូបចុកមិនគ្រប់គ្រាន់ និងនៅតែរន្ធត់ពេលខ្មែរក្រហមចាប់អ្នកនៅក្នុងកងជាមួយខ្ញុំយកទៅសម្លាប់ចោល។

# សូ ចំរើន ៖ អ្នកដាំស្លនៅសហករណ៍

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ សូ ចំរើន កើតនៅឆ្នាំ១៩៥១ នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខ្ញុំមានបងប្អូនបង្កើតចំនួនបួននាក់ គឺស្រីបីនាក់ និងប្រុសតែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំគឺជាកូនប្រុសច្បងនៅក្នុងគ្រួសារ។ កាលពីក្មេងខ្ញុំរៀនដល់ថ្នាក់ទី៩ចាស់នៅសាលាក្នុងភូមិ។ ក្រោយមកខ្ញុំបានឈប់រៀន មកជួយធ្វើការងារឪពុកម្ដាយវិញ។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការប្រពន្ធ។ នៅអំឡុងពេលនោះកងទ័ព លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានវាយប្រយុទ្ធគ្នា ហើយភូមិរបស់ខ្ញុំ គឺជាតំបន់ប្រទាញប្រទង់ ដូច្នេះខ្ញុំមិនបានរស់នៅផ្ទះជាប់លាប់ទេ។ ខ្ញុំបានដឹកគោក្របី និងនាំប្រពន្ធឆ្លងស្ទឹងបាសាក់គេចខ្លួនទៅរស់នៅភូមិទាហានក្រោម ក្នុងឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ ខ្ញុំនិងប្រពន្ធបានសង់ខ្ទមនៅក្នុងទីធ្លាវត្តដើម្បីស្នាក់នៅបណ្ដោះអាសន្ន រហូតដល់ការវាយប្រយុទ្ធគ្នាស្ងប់ស្ងាត់ទើបខ្ញុំនាំប្រពន្ធកូនត្រឡប់មករស់ភូមិបាសាក់វិញ។ ក្រោយមកខាងរដ្ឋាភិបាល លន់ នល់ បានជ្រើសរើសខ្ញុំឱ្យចូលធ្វើកងជីវពលយាមការពារភូមិបាសាក់ពីខ្មែរក្រហម។ ខ្ញុំដើរល្បាតនៅក្នុងភូមិបាសាក់បានមួយរយៈ កងទ័ពរំដោះខ្មែរក្រហមបានឆ្មក់ចូលមកក្នុងភូមិ ហើយបានចាប់ខ្លួនខ្ញុំ។ ខ្មែរក្រហមបានចោទខ្ញុំថាបម្រើខ្មាំង និងបានបញ្ជូនខ្ញុំទៅរៀនសូត្រនៅខេត្តកំពង់ចាម។



សូ ចំរើន នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានចូលរៀនអំពីមាគ៌ាដឹកនាំនិងតស៊ូបដិវត្តន៍របស់ខ្មែរក្រហមនៅខេត្តកំពង់ចាមរយៈពេលមួយខែ ទើបខ្មែរក្រហមបញ្ជូនខ្ញុំត្រឡប់មកខេត្តស្វាយរៀងវិញ។ ប៉ុន្តែខ្ញុំមិនទាន់ចូលមករស់នៅផ្ទះភ្លាមទេ ព្រោះភូមិឃុំរបស់ខ្ញុំខាងរដ្ឋាភិបាល លន់ នល់ នៅគ្រប់គ្រងនៅឡើយ។ ដូច្នេះខ្ញុំបានទៅរស់នៅឃុំប្រសូត្រ ក្នុងស្រុកស្វាយទាប។ ខ្ញុំបានឆ្លៀតឱកាសលួចមកលេងប្រពន្ធកូននៅផ្ទះម្ដងម្កាលប៉ុណ្ណោះ ព្រោះខ្ញុំត្រូវចេញទៅធ្វើការងារនៅឃុំជីភូ។ នៅពេលកងទ័ពខ្មែរក្រហមវាយរំដោះបានខេត្តស្វាយរៀង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្ញុំមកស្នាក់នៅផ្ទះជួបជុំប្រពន្ធកូន។ បន្ទាប់មក ខ្មែរក្រហមបានចាត់ខ្ញុំឱ្យនៅដាំស្ល នៅរោងសហករណ៍ភូមិ បោះនៅផ្ទះតាសន និងផ្ទះតាយ៉ែម ក្នុងភូមិបាសាក់សព្វថ្ងៃ ចំណែកប្រពន្ធរបស់ខ្ញុំទៅនៅកងដកស្ទូង។ ដោយសារខ្ញុំនៅខាងចុងភៅ ដូច្នេះខ្ញុំបានហូបឆ្អែត លើកលែងតែប្រពន្ធរបស់ខ្ញុំដែលចេញទៅធ្វើការនៅតាមការដ្ឋានទើបមិន

មានអាហារហូបចុកគ្រប់គ្រាន់។ នៅអំឡុងពេលនោះ ខ្មែរក្រហមបានបញ្ជូនកម្មាភិបាលមកពីឃុំស្វាយធំ ស្រុកស្វាយជ្រំឱ្យមកគ្រប់គ្រងនៅឃុំបាសាក់រួមទាំងរោងបាយសហករណ៍របស់ខ្ញុំ ហើយការគ្រប់គ្រងក៏តឹងតែងដែរ។ ប្រធានរោងបាយបានចាត់តាំងខ្ញុំឱ្យពុះខុស វែកទឹក រកត្រី និងរៀបចានដាក់របបអាហារសម្រាប់ប្រជាជនដែលធ្វើការនៅតាមកងចល័ត។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំនិងគ្រួសារឱ្យទៅរស់នៅភូមិតាប៉ ឃុំតាសួស ស្រុកស្វាយជ្រំ។ នៅទីនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យនៅឃ្វាលក្របីរបស់ខ្ញុំដែលយកមកពីផ្ទះ។ រយៈពេលបីខែក្រោយមក ទើបខ្មែរក្រហមជម្លៀសខ្ញុំទៅអ្នកលឿងដើម្បីជិះស្រឡាងបន្តមកឈប់នៅច្បារអំពៅក្នុងក្រុងភ្នំពេញ។ នៅពេលជម្លៀសនោះ ខ្ញុំមិនបានយករទេះនិងក្របីមកជាមួយទេ គឺខ្ញុំទុកនៅសហករណ៍តាប៉ ឃុំតាសួសទាំងអស់។ ខ្ញុំដេកនៅច្បារអំពៅមួយយប់ ហើយនៅទីនោះខ្មែរក្រហមបានចែកបាយក្រអូបឱ្យខ្ញុំហូប និងចែកសារ៉ុង, សំពត់ខ្មៅ, ភួយ, ក្រមាពណ៌ខៀវ ឱ្យខ្ញុំនិងប្រពន្ធរបស់ខ្ញុំម្នាក់មួយសម្រាប់ទៀត។ នៅព្រឹកបន្ទាប់ខ្មែរក្រហមបានយករថយន្តមកដឹកខ្ញុំ និងគ្រួសារទៅដាក់នៅស្ថានីយរថភ្លើងក្រុងភ្នំពេញ។ ខ្ញុំបានជិះរថភ្លើងទៅឈប់នៅស្ថានីយរថភ្លើងព្រៃស្វាយ ស្ថិតនៅក្នុងឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ។

បន្ទាប់មក ខ្មែរក្រហមនៅមូលដ្ឋានបានបររទេះមកដឹកក្រុមគ្រួសារខ្ញុំទៅនៅសហករណ៍បឹងទុំលែង ក្នុងស្រុកមោងឫស្សី។ នៅទីនោះ ខ្មែរក្រហមបានបំបែកសមាជិកគ្រួសាររបស់ខ្ញុំឱ្យទៅធ្វើការនៅតាមកងរៀងៗខ្លួន គឺខ្ញុំទៅរែកដីនៅអាងទុំលែង ប្រពន្ធរបស់ខ្ញុំទៅច្រូតស្រូវ ហើយកូនដែលតូចត្រូវរស់នៅជាមួយប្រពន្ធរបស់ខ្ញុំ។ ប្រធានកងខ្មែរក្រហមបានដាក់ផែនការឱ្យខ្ញុំរែកដីឱ្យបាន៤ម៉ែត្រគុបក្នុងមួយថ្ងៃ។ ដូច្នេះ ខ្ញុំត្រូវរែកដីរហូតដល់ម៉ោង១០យប់ដើម្បីឱ្យគ្រប់តាមផែនការកំណត់ ទើបខ្ញុំឈប់សម្រាក។ ទោះបីខ្ញុំខំប្រឹងប្រែងធ្វើការយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនបានទទួលរបបអាហារហូបគ្រប់គ្រាន់ដែរ គឺហូបតែបបរលាយដំឡូង។ នៅម៉ោង៣ទៀបភ្លឺ ប្រធានកងបានមកដាស់ខ្ញុំឱ្យក្រោកឡើងទៅធ្វើការទៀត ដូច្នេះខ្ញុំដេកមិនដែលបានឆ្អែតទេ។ ថ្ងៃមួយគណៈស្រុកបានហៅប្រជាជននៅក្នុងមោងឫស្សីទាំងអស់មកប្រជុំ ហើយបន្ទាប់ពីប្រជុំបានមួយរយៈ ប្រធានកងបានផ្លាស់ខ្ញុំពីអាងទុំលែងឱ្យទៅធ្វើការនៅស្តុកប្រវឹក។ នៅទីនោះ ប្រធានកងបានចាត់តាំងខ្ញុំឱ្យទៅកាប់កូនឈើនៅលើភ្នំ។ ជារឿយៗ ខ្ញុំឃើញកងឈ្លបខ្មែរក្រហមបណ្តើរប្រជាជនយកទៅសម្លាប់នៅក្នុងព្រៃស្ថិតនៅក្បែរកន្លែងដែលខ្ញុំធ្វើការ ប៉ុន្តែខ្មែរក្រហមបានហាមខ្ញុំមិនឱ្យចូលទៅទីតាំងសម្លាប់ឡើយ។ ថ្ងៃមួយ ខ្ញុំមានជំងឺគ្រុនចាញ់ ប៉ុន្តែខ្ញុំមិនស្នើសុំប្រធានកងទៅព្យាបាលនៅមន្ទីរពេទ្យឡើយ ព្រោះខ្ញុំខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំបានសម្រាកនៅក្នុងកងរហូតបានធូរស្បើយ។ ខ្ញុំកាប់ឆ្ការព្រៃបានរយៈពេលមួយខែ ស្រាប់តែមានឧទ្ធម្ភាគចក្រហោះមកទម្លាក់ខិតប័ណ្ណសរសេរថាប្រទេសបានរំដោះហើយ។ រំលងបានកន្លះថ្ងៃ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមកដល់សហករណ៍ស្តុកប្រវឹកដែលខ្ញុំរស់នៅ ធ្វើឱ្យកម្មាភិបាល និងឈ្លបខ្មែរក្រហមដែលគ្រប់គ្រងនៅទីនោះបានរត់គេចខ្លួនឡើងលើភ្នំអស់។

ខ្ញុំបានត្រឡប់មកជួបជុំប្រពន្ធ និងកូន ហើយយើងបានដើររកដំឡូងនិងរកត្រីមកហូប ប៉ុន្តែយើងគ្មានស្ករអំបិលឡើយ។ ខ្ញុំនិងប្រពន្ធបានធ្វើដំណើរបន្តទៅដល់សហករណ៍មួយដែលកម្មាភិបាលខ្មែរក្រហមនៅគ្រប់គ្រងនៅឡើយ។ ពេលនោះ ខ្ញុំបានដើរចូលទៅដងទឹកពីស្រះយកមកដាំបាយហូប ក៏មានខ្មែរក្រហមម្នាក់មកលួចខ្សឹបប្រាប់ខ្ញុំឱ្យចាកចេញពីទីនោះឱ្យឆាប់រហ័ស ព្រោះឈ្លបខ្មែរក្រហមរៀបចំផែនការកៀរប្រជាជន។ ឮដូច្នេះ ខ្ញុំប្រញាប់ប្រញាល់នាំប្រពន្ធកូនទៅលាក់ខ្លួននៅក្នុងព្រៃរបោះក្បែរនោះ ដោយមិនហ៊ានទៅដាំបាយឡើយ។ មួយសន្ទុះក្រោយមក ប្រធានឈ្លបខ្មែរក្រហមបានជិះសេះមកតាមរកក្រុមគ្រួសារខ្ញុំ និងប្រជាជនថ្មីដែលធ្វើដំណើរជាមួយគ្រួសារខ្ញុំ។

រហូតដល់យប់ងងឹត ទើបខ្ញុំនិងប្រពន្ធកូនហ៊ានធ្វើដំណើរបន្តទៀត ដោយមានស្ត្រីម្នាក់ជម្លៀសមកពីខេត្តព្រៃវែងហើយស្គាល់ផ្លូវច្បាស់បានដឹកនាំការធ្វើដំណើរនេះ។ ខ្ញុំបានដើរឆ្លងផុតព្រៃមកដល់ផ្លូវបំបែកនៅព្រៃស្វាយនៅពេលព្រឹក ក៏ឃើញរថយន្តបើកបរនៅលើផ្លូវទើបខ្ញុំដឹងច្បាស់ថា ប្រទេសបានរំដោះយូរហើយ។ ខ្ញុំឃើញប្រជាជនជម្លៀសស្នាក់នៅអមសងខាងផ្លូវបំបែកបណ្ដោះអាសន្ន។ ប្រជាជនមួយចំនួនបានដើរសាកសួរដំណឹងអំពីសមាជិកគ្រួសារដែលបែកគ្នា ចំណែកខ្ញុំបានជូនអ្នកភូមិម្នាក់ឈ្មោះ ខូ ដើររកម្ដាយ ដោយទុកប្រពន្ធនិងកូននៅផ្លូវបំបែក។ ខ្ញុំដើរទៅដល់ទីរួមស្រុកមោងឫស្សីក៏បានជួបស្ត្រីឈ្មោះ លូ ដែលរស់នៅភូមិបាសាក់ជាមួយខ្ញុំ ហើយគាត់មានស្រូវច្រើន។ ខ្ញុំបានត្រឡប់មកវិញក្នុងគោលបំណងយកប្រពន្ធ និងកូនខ្ញុំទៅរស់នៅទីរួមស្រុកមោងឫស្សីដែរ។ ប៉ុន្តែពេលខ្ញុំដើរមកដល់ឃុំព្រៃស្វាយក៏បានជួបឈ្មោះ ថាន់ អ្នកភូមិបាសាក់ជាមួយខ្ញុំដែរ។ ថាន់ ប្រមូលស្រូវបានយ៉ាងច្រើន ដូច្នេះខ្ញុំបានសម្រេចចិត្តនៅជួយបុកស្រូវគាត់ដើម្បីវែងយកអង្ករទៅដាំបាយហូប។ បន្ទាប់មក ខ្ញុំនិងគ្រួសារបានដើរពីខេត្តបាត់ដំបងរយៈពេលមួយខែទើបមកដល់ស្រុកកំណើតនៅខេត្តស្វាយរៀង។ ខ្ញុំមិនមានផ្ទះសម្បែងស្នាក់នៅទេ ព្រោះខ្មែរក្រហមបានរុះរើផ្ទះខ្ញុំអស់ហើយ។ ដូច្នេះខ្ញុំបាននាំប្រពន្ធកូនទៅរស់នៅរោងបាយសហករណ៍ដែលបន្សល់ពីរបបខ្មែរក្រហមបណ្ដោះអាសន្ន ទំរាំខ្ញុំដើររកឫស្សីមកសង់ខ្ទមនៅលើដីភូមិរបស់ខ្ញុំដើម្បីស្នាក់នៅ។ ខ្ញុំនៅសេសសល់អង្ករតិចតួចប៉ុណ្ណោះ ដូច្នេះខ្ញុំត្រូវដាំបបរហូបជាមួយត្រកួនដែលដុះជុំវិញផ្ទះដើម្បីពន្យារពេលឱ្យបានយូរ។ បន្ទាប់មកទើបខ្ញុំដើរដឹកកណ្ដូរស្រែមកចៀនលក់យកប្រាក់ទិញអង្ករហូប និងធ្វើស្រែដើម្បីចិញ្ចឹមប្រពន្ធកូនបានរស់រហូតមកដល់សព្វថ្ងៃ។



សូ ចំរើន នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជនជាតិដើមភាគតិចស្ទៀងរស់នៅភូមិក្តុលលើ រៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ ឬបុណ្យភូមិ បន្ទាប់ពីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ

ធ្យូង ជានី



ជនជាតិដើមភាគតិចស្ទៀង រស់នៅភូមិក្តុលលើ រៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចន្លោះពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ ជនជាតិដើមភាគតិចស្ទៀងរស់នៅភូមិក្តុលលើ បាននាំគ្នារៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ ឬបុណ្យភូមិ បន្ទាប់ពីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ។ ពិធីបុណ្យភូមិត្រូវប្រារព្ធឡើងនៅផ្ទះសហគមន៍ជនជាតិដើមភាគតិចស្ទៀង ឬសាលាគរុកណ្ឌស្ទៀង ភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជាទូទៅជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ តែងតែប្រារព្ធពិធីបុណ្យកម្សាន្តភូមិជារៀងរាល់ឆ្នាំ និងមានរយៈពេលបីយប់ បីថ្ងៃ បន្ទាប់ពីពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរបញ្ចប់ទៅរយៈពេលពីរថ្ងៃ។ ប៉ុន្តែឆ្នាំនេះមានការប្រែប្រួលត្រូវពន្យារពេលរយៈពេល១១ថ្ងៃ ទើបចាប់ផ្តើមបុណ្យកម្សាន្តភូមិដែលមានរយៈពេល២យប់ និង២ថ្ងៃប៉ុណ្ណោះ។

ពេលធ្វើកម្មពិធីបុណ្យកម្សាន្តភូមិម្តងៗ ជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ តែងតែធ្វើពិធី

ឡើងអ្នកតា ព្រោះការឡើងអ្នកតាជាទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ ភូមិកោះថ្ម និងភូមិដទៃទៀត នៃឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តាំងពីយូរលង់ណាស់មកហើយ។

ពិធីឡើងអ្នកតារបស់ជនជាតិដើមភាគតិចស្ទៀងដើម្បីសុំសេចក្តីសុខដល់ប្រជាជនរស់នៅក្នុងភូមិ សុំទឹកភ្លៀងសម្រាប់ប្រើប្រាស់តាមតម្រូវការរបស់ជនជាតិដើមភាគតិចស្ទៀង។ ជនជាតិដើមភាគតិចស្ទៀងយកថ្មចំនួនពីរដុំគូរមាត់ ភ្នែក ច្រមុះ ដាក់នៅលើខ្ទមអ្នកតា ជាតំណាងវត្ថុស័ក្តិសិទ្ធិ ឬតំណាងឱ្យអ្នកមានរិទ្ធិអំណាចឬពួកអាទិទេព។ ពេលឡើងអ្នកតា ជនជាតិដើមភាគតិចស្ទៀង នាំគ្នាយកគ្រឿងសំណែនមានដូចជា ស្រាស ស្រាថ្នាំ មាន់ស្ងោរ ក្បាលជ្រូកស្ងោរ បាយស បាយក្រហម នំចំណី អន្សម ជាដើម យកទៅដាក់ក្នុងខ្ទមអ្នកតា។ បន្ទាប់មកជនជាតិដើមភាគតិចស្ទៀងបានអញ្ជើញ អារក្ស អ្នកតា ដែលជាអ្នកថែរក្សា ព្រៃភ្នំ ក្រំថ្ម អ្នកតារក្សាភូមិ ឃុំឱ្យមកទទួលនូវគ្រឿងដង្វាយដែលបានរៀបចំ។ តាំងពីយូរលង់មកមានអ្នកតាចំនួនពីរ គឺអ្នកតាក្រហមក និងអ្នកតាជីទាវម៉ៅ ដែលនៅចាំបីបាច់ថែរក្សានៅភូមិក្តុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

បុណ្យកម្សាន្តភូមិជនជាតិដើមភាគតិចស្ទៀងជាកម្មវិធីបែបប្រពៃណីមួយដែលធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីប្រមូលផ្តុំមនុស្សជួបជុំសាច់ញាតិ បងប្អូន គ្រួសារដែលរស់នៅឆ្ងាយពីភូមិកំណើត និងរំឭកឡើងវិញនូវទម្រង់សិល្បៈ ទំនៀមទម្លាប់ ប្រពៃណី និងពិធីសាសនាជាដើម។

តាមជំនឿជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ ឃុំទន្ទឹង ការធ្វើបុណ្យកម្សាន្តភូមិអាចឧទ្ទិសកុសលជូនអ្នកដែលបានស្លាប់ទៅ ក្នុងនោះក៏រួមមានប្រជាជនកម្ពុជា និងជនជាតិដើមភាគតិចស្ទៀងដែលបានស្លាប់នៅក្នុងអំឡុងពេលសង្គ្រាម និងរបបប្រល័យពូជសាសន៍ ប៉ុល ពត។ នៅខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមឡើងកាន់កាប់អំណាចបានទាំងស្រុង និងចាត់ទុកខែមេសា ជាថ្ងៃចងចាំនៃអំពើប្រល័យពូជសាសន៍ជាសកល។ នៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ ខ្មែរក្រហមបានជម្លៀសជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ ដោយបង្ខំចេញពីភូមិកំណើតឱ្យទៅរស់នៅធ្វើការងារពលកម្មធ្ងន់ធ្ងរ និងមិនមានអាហារហូបចុកគ្រប់គ្រាន់ក្នុងស្រុកស្នួល ស្រុកសំបូរ ខេត្តក្រចេះ។ ខ្មែរក្រហមបានចោទប្រកាន់ជនជាតិដើមភាគតិចស្ទៀង និងប្រជាជនភូមិភាគបូព៌ាថាជាមនុស្សក្បាលយួនខ្លួនខ្មែរ។ ជនជាតិដើមភាគតិចស្ទៀងដែលមានវ័យជំទង់ ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យកាស់រានដីថ្មីសម្រាប់ធ្វើស្រែ លើកប្រព័ន្ធភ្លឺស្រែ ស្ទូងជាដើម។ ចំណែក កុមារត្រូវធ្វើជី ដកស្មៅនៅវាលស្រែ និងរែកជីដាក់ស្រែ។ រីឯមនុស្សចាស់នៅផ្ទះមើលថែក្មេងៗឬត្បាញល្អីកញ្ច្រែងជាដើម។ ជនជាតិដើមភាគតិចស្ទៀង ត្រូវបានខ្មែរក្រហមបំបាត់សិទ្ធិគ្រប់យ៉ាង ដូចជាការនិយាយភាសាស្ទៀង ការគោរពជំនឿផ្សេងៗ។ ជនជាតិភាគតិចស្ទៀងនៅភូមិក្តុលលើ ភូមិកោះថ្ម និងភូមិដទៃទៀតនៃឃុំទន្ទឹង ជាច្រើនបានស្លាប់ដោយអត់អាហារ ឈឺគ្មានថ្នាំព្យាបាល និងត្រូវខ្មែរក្រហមយកទៅសម្លាប់នៅភូមិអាលូច ភូមិម្ទេច ឃុំស្វាយជ្រះ និងភូមិស្រែរនាម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ។ ចំណែកអ្នកស្លាប់នៅឃុំឃ្សឹម និងឃុំស្វាយជ្រះ ស្រុកស្នួល ភាគច្រើនជាមនុស្សចាស់ និងក្មេងៗ។

ចុងឆ្នាំ១៩៧៨ ខ្មែរក្រហមជម្លៀសជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ ភូមិកោះថ្ម និងភូមិដទៃទៀតឱ្យទៅស្នាក់នៅភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ដើម្បីរង់ចាំកាណូតដឹកតាមបណ្តោយដងទន្លេមេគង្គទៅកាន់ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ បន្ទាប់ពីជនជាតិដើមភាគតិចស្ទៀងមកដល់ស្រុកស្ទឹងត្រង់ មានជនជាតិដើមភាគតិចស្ទៀងខ្លះត្រូវបានខ្មែរក្រហមដឹកតាមរថយន្តទៅកាន់ស្រុកចំការលើ ខេត្តកំពង់ចាម និងស្រុកបារាយណ៍ ខេត្តកំពង់ធំ។

ក្រុមគ្រួសារ សាច់ញាតិ ដែលមានបងប្អូនស្លាប់ក្នុងសម័យខ្មែរក្រហម ប៉ុន្តែមិនដឹងថាស្លាប់នៅទីកន្លែងណា ឬមិនស្គាល់ឈ្មោះជនរងគ្រោះពីសម័យ



ជនជាតិដើមភាគតិចស្ទៀង រស់នៅភូមិក្តុលលើ រៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ខ្មែរក្រហម ក៏ត្រូវជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើធ្វើបុណ្យឧទ្ទិសកុសលជូនជារួម។

ជនជាតិដើមភាគតិចស្ទៀងនៅក្នុងភូមិក្តុលលើ បានរៀបរាប់ដូចខាងក្រោម៖

**១) ម៉ែន ញឹម** ភេទប្រុស អាយុ៨៣ឆ្នាំ រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានឱ្យដឹងថា៖ ថ្ងៃទី១ ឬថ្ងៃចូលបុណ្យភូមិ វេលាព្រឹកម៉ោង៧:០០នាទីព្រឹក គណៈកម្មាការភូមិក្តុលលើបានចាក់មេក្រូប្រកាសហៅប្រជាជនក្នុងភូមិក្តុលលើដើម្បីមកជួយរៀបចំទីកន្លែង និងប្រដាប់ប្រដា សម្រាប់ពិធីបុណ្យភូមិ។

បន្ទាប់ពីបានឮសេចក្តីប្រកាស លោកតា លោកយាយ គណៈកម្មការភូមិក្តុលលើ និងប្រជាជន បាននាំគ្នាមកផ្ទះសហគមន៍ជនជាតិដើមភាគតិចស្ទៀង។ យុវជនដែលជាកូនចៅជនជាតិដើមភាគតិចស្ទៀង បានយករោង តុ កៅអី មករៀបចំដំឡើង។ ចំណែកយុវនារី បាននាំគ្នាបោសសម្អាតទីធ្លា។ ឯលោកតា លោកយាយ បានកាប់កូនចេក ២ដើម ស្លឹកចេក និងបេះផ្កាចំប៉ី សម្រាប់យកមកធ្វើបាយសី និងស្លាធម៌ជាគ្រឿងសក្ការៈថ្វាយព្រះ។

វេលាម៉ោង២:០០នាទីរសៀល លោកតា លោកយាយរៀបចំគ្រឿងប្រដាប់ថ្វាយសែនដល់អ្នកតាដែលជាអ្នកថែរក្សាភូមិក្តុលលើ ដើម្បីសុំសេចក្តីសុខសម្រាប់ប្រជាជនរស់នៅក្នុងភូមិ។ ពិធីឡើងអ្នកតាតែងធ្វើឡើងនៅក្រោយពេលបញ្ចប់រដូវច្រូតកាត់ និងត្រៀមរដូវកាលធ្វើស្រែចម្ការក្នុងឆ្នាំថ្មីក្នុងនោះក៏ដើម្បីសុំសេចក្តីសុខចម្រើនដល់ភូមិឋានទាំងមូល ធ្វើស្រែចម្ការទទួលបានភោគផលច្រើន និងចៀសផុតពីជំងឺចង្រៃផ្សេងៗ។ អ្នកភូមិដែលចូលរួមក្នុងពិធីនេះតែងតែនាំយកម្ហូបអាហារ បាយសម្ល ភេសជ្ជៈ ផ្លែឈើជាដើម ដើម្បីធ្វើពិធីសែន និងថ្វាយនៅតាមរោងអ្នកតា ឬខ្ទមអ្នកតា ឬរូបសំណាកដែលអ្នកភូមិគោរព។ អ្វីដែលមិនអាចខ្វះបាននោះគឺស្រាស។ ក្រៅពីនោះក៏មានស្លាធម៌ បាយសី មានគ្រឿងសំណែនទៀនធូប និងក្រណាត់ស។ ប៉ុន្តែ បច្ចុប្បន្នគឺគ្មានភ្លេងអារក្សប្រគំកំដរឡើយ។

វេលាម៉ោង៣:០០នាទីរសៀល មានកម្មវិធីពូនភ្នំខ្សាច់ (យកស្រូវតំណាងឱ្យខ្សាច់) ដើម្បីរំឭកដល់ព្រះពុទ្ធអង្គ និងសុំអធ្យាស្រ័យដល់ពពួកសត្វ និង

មនុស្ស ព្រមទាំងទេវតា ទាំងពួងនៅក្នុងចក្រវាឡទាំងមូលឱ្យលើកលែង និងអហោសកម្មដល់ខ្លួនដែលធ្លាប់ប្រព្រឹត្តនូវអំពើជាអកុសលដល់សត្វលោកទាំងនោះក្នុងអតីតជាតិដោយអចេតនាណាមួយ។ ម្យ៉ាងទៀត យើងក៏អាចប្រាថ្នាសុំនូវសិរីសួស្តីទាំងឡាយឱ្យកើតមានដល់ក្រុមគ្រួសារ និងសហគមន៍ផងដែរ។

វេលាម៉ោង៤:០០នាទីរសៀល យុវជនភូមិក្តុលលើបានរៀបចំកន្លែងរាំ ដោយតុបតែងដាក់ដើមចេកពីដើម និងមានផ្លែឈើដូចជា ផ្លែមានក្រៀវ ដូងទុំ ដូងចាស់ ចេក ខ្នុរ ម្នាស់ ត្នោត និងផ្លែឪឡឹក។

វេលាម៉ោង៥:០០នាទីរសៀល និមន្តព្រះសង្ឃសូត្រមន្ត។ បន្ទាប់ពីព្រះសង្ឃសូត្រចប់ មានកម្មវិធីរាំកម្សាន្ត។

**២) យាន យីន** ភេទស្រី អាយុ៦៩ឆ្នាំ រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានឱ្យដឹងថា៖ ពិធីបុណ្យភូមិជនជាតិដើមភាគតិចស្ទៀង ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំបន្ទាប់ពីចូលឆ្នាំប្រពៃណីជាតិរួច។ ពិធីបុណ្យភូមិនេះ មានតាំងពីយូរលង់ណាស់មកហើយ។ កាលពីសម័យសង្គមរាស្ត្រនិយមក៏មានធ្វើពិធីបុណ្យភូមិដែរ ប៉ុន្តែគ្មានធុងបាសរាំសប្បាយដូចពេលបច្ចុប្បន្ននេះទេ។ អំឡុងសម័យខ្មែរក្រហមពិធីបុណ្យផ្សេងៗត្រូវបានអង្គការខ្មែរក្រហមលុបបំបាត់ និងហាមឃាត់។ លុះក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជននៅក្នុងភូមិក្តុលលើ បានរៀបចំពិធីបុណ្យភូមិឡើងវិញនៅខែមេសា ឆ្នាំ១៩៧៩។ បុណ្យភូមិកាលនោះមានជួលល្ខោនសម្តែងបីយប់ៗជំនាន់នោះសប្បាយណាស់ ហើយពេលខ្លះក៏មានរាំស្គរដី ព្រោះមិនទាន់មានធុងបាសដូចសម័យបច្ចុប្បន្នទេ។ បុណ្យភូមិពីសម័យមុន និងសម័យបច្ចុប្បន្នមិនខុសគ្នាទេ គឺមានការរៀបចំសែនព្រេនដូចគ្នា។ ពិធីបុណ្យភូមិរវល់តែថ្ងៃចូលឬថ្ងៃទី១ ពេលព្រឹក លោកតា លោកយាយរៀបចំបត់ស្លាធម៌ បាយសីសម្រាប់ថ្វាយជាទីសក្ការៈដល់ព្រះពុទ្ធ និងរៀបចំចងផ្កាសាមគ្គី។

វេលាម៉ោង៣:០០នាទីរសៀល ជួបជុំបងប្អូនយាយតានៅក្នុងភូមិក្តុលលើ ដើម្បីប្រារព្ធពិធីឡើងអ្នកតា។ តាំងពីដើមរៀងមក ពេលឡើងអ្នកតា ប្រជាជនទាំងអស់ត្រូវមកជួបជុំគ្នានៅខ្ទមអ្នកតា ដើម្បីគូសមុខមាត់ រួចហើយដើរគោះតាមផ្ទះតាំងពីចុងភូមិរហូតដល់ដើមភូមិ ដើម្បីដេញគ្រោះចង្រៃ។ ពេលនាំគ្នាដើរដេញនោះ ប្រសិនបើចាប់បានមាន់ ទា ជ្រូក ត្រូវតែយកមកធ្វើហូបនៅកន្លែងខ្ទមអ្នកតា។ ពេលសម័យបច្ចុប្បន្នមិនធ្វើដូចមុនទៀតទេ គ្រាន់តែធ្វើបាយសម្ល នំចំណី ស្រាស មាន់ស្ងោរ១ ចេកទុំ១ស្និត ទឹកផ្លែឈើ ទៅដាក់នៅខ្ទមអ្នកតា គ្មានភ្លេងកំដរឡើយ។ នៅខ្ទមអ្នកតាមមានដុំថ្មមួយគួរសម្រាប់គោរពបូជា។ បន្ទាប់មកមានកម្មវិធីដង្ហែរផ្កា ដើម្បីយកទៅទុកនៅលើសាលាបុណ្យជនជាតិដើមភាគតិចស្ទៀង។ រួចមានកម្មវិធីពូនភ្នំខ្សាច់ដែលធ្វើឡើងដើម្បីរំដោះកម្មទាំងឡាយណាដែលធ្វើឡើងដោយអចេតនា។ ជាកិច្ចបញ្ចប់និមន្តព្រះសង្ឃសូត្រមន្ត រួចចាក់ភ្លេងរាំកម្សាន្ត។





# អគារមរតកសន្តមរាស្ត្រនិយមសម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)

## ផ្តល់ទីតាំងសម្រាប់កម្មវិធីពិនិត្យសុខភាពឥតគិតថ្លៃដល់ប្រជាពលរដ្ឋរស់នៅស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង

ស្រេង លីដា



ប្រជាជននៅស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង មកពិនិត្យសុខភាពដោយឥតគិតថ្លៃពីអង្គការគណៈកម្មាធិការសុខភាពកម្ពុជា (Cambodian Health Committee - CHC) សាខាខេត្តស្ទឹងត្រែង នៅអគារមរតកសន្តមរាស្ត្រនិយមសម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាសាខារបស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ អគារមរតកសន្តមរាស្ត្រនិយមសម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាសាខារបស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់កិច្ចសហការដោយផ្តល់ជាទីតាំងសម្រាប់កម្មវិធីពិនិត្យសុខភាពឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋរស់នៅស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ កម្មវិធីពិនិត្យសុខភាពខាងលើមានការរៀបចំដោយ អង្គការគណៈកម្មាធិការសុខភាពកម្ពុជា (Cambodian Health Committee - CHC) សាខាខេត្តស្ទឹងត្រែង។

កម្មវិធីពិនិត្យសុខភាពឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋរស់នៅស្រុកបុរីអូរស្វាយ សែនជ័យ ប្រព្រឹត្តឡើងដោយមានការចូលរួមពីលោកវេជ្ជបណ្ឌិត បេងទូច មកពីមន្ទីរពេទ្យបង្អែក ខេត្តស្ទឹងត្រែង និងអ្នកគ្រូ

ពេទ្យ សេង បូរី មកពីមណ្ឌលសុខភាព ព្រះនរោត្តម សីហនុរាជា និងសម្ដេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ អូរស្វាយ និងប្រជាពលរដ្ឋដែលមានវ័យជរា រស់នៅស្រុកបុរីអូរស្វាយ-សែនជ័យ សរុបចំនួន៥២នាក់។ ការពិនិត្យសុខភាពមានដូចជា៖ វាស់សម្ពាធឈាម, ពិនិត្យជាតិស្ករក្នុងឈាម និងពិនិត្យជំងឺសួត។ ក្នុងចំណោមលោកយាយ លោកតាទាំង ៥២ នាក់ ភាគច្រើនមានជំងឺសម្ពាធឈាមខ្ពស់ ហើយ បន្ទាប់មកគឺជំងឺលើសជាតិស្ករ។ រីឯអ្នកជំងឺចំនួន ២ នាក់ទៀតវិញ មានរោគសញ្ញាក្អកញ៉ឹកញ៉ាប់ ប៉ុន្តែក៏មិនអាចសន្និដ្ឋានថាជំងឺសួតបានជាច្បាស់នៅឡើយទេ ដោយសារតែបច្ចុប្បន្ន លោកគ្រូពេទ្យកំពុងសម្រេចយកសំណាក់ទៅពិនិត្យបន្ថែមមុននឹងបញ្ចប់ការវាយតម្លៃ។

កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ជំនួយមនុស្សធម៌ដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមប្រហែលប្រាំលាននាក់ និងជាពិសេសជួយដល់អ្នករស់រស់មានជីវិតពីរបបខ្មែរក្រហមឱ្យទទួលបានសេវាសុខភាព និងសេវាសង្គមដែលជាតម្រូវការបន្ទាន់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចន្លោះពី៦០ឆ្នាំ និង៨០ឆ្នាំ ប្រឈមនឹងជំងឺប្រចាំកាយ និងជំងឺផ្លូវចិត្ត។ បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែផ្ដោតលើសុខុមាលភាព និងផ្ដល់ការថែទាំដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយធ្វើឱ្យប្រាកដថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅបានយូរ ដូច្នេះគាត់អាចចែករំលែករឿងរ៉ាវរបស់គាត់ទៅអ្នកដទៃ និងចងក្រងទុកជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយ។ ឯកសារ និងការកត់ត្រារឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅពេលនេះ គឺមានសារសំខាន់ជាផ្នែកផ្សេងទៀតនៃប្រវត្តិសាស្ត្រទៅទៀត ពីព្រោះមនុស្សជំនាន់នេះនឹងត្រូវបាត់បង់នៅថ្ងៃណាមួយ ហើយលែងបានចែករំលែករឿងរ៉ាវដែលបានកើតឡើងចំពោះគាត់។ ដូច្នេះ ការចងក្រងឯកសារ និងការកត់ត្រា និងការរក្សាទុកនូវរឿងពីរបបខ្មែរក្រហម តាមរយៈការផ្ដល់ជំនួយមនុស្សធម៌ និងសេវាថែទាំសុខភាពដល់អ្នករស់រមានជីវិតពីរបបខ្មែរក្រហម ដើម្បីឱ្យគាត់មានសុខភាពល្អ និងរស់នៅបានយូរទៅមុខទៀត គឺជារឿងចាំបាច់។

នៅចុងបញ្ចប់នៃកម្មវិធីពិនិត្យសុខភាពឥតគិតថ្លៃ លោកវេជ្ជបណ្ឌិត និងអ្នកគ្រូពេទ្យ ក៏ផ្ដល់ការណែនាំអំពីការថែទាំសុខភាព និងលើកទឹកចិត្តឱ្យអ្នកដែលមានជំងឺបន្តទៅពិនិត្យសុខភាពបន្ថែមនៅមណ្ឌលសុខភាពដែលនៅជិតខ្លួន ដើម្បីទទួលបានថ្នាំព្យាបាលទៅតាមភាពចាំបាច់ ដោយផ្អែកទៅលើស្ថានភាពសុខភាពជាក់ស្ដែងរបស់ខ្លួន។





ប្រជាជននៅស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង មកពិនិត្យសុខភាពដោយឥតគិតថ្លៃពីអង្គការគណៈកម្មាធិការសុខភាពកម្ពុជា (Cambodian Health Committee - CHC) សាខាខេត្តស្ទឹងត្រែង នៅអគារមរតកសង្គមរាស្ត្រនិយមសម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាសាខារបស់ព្រះរាជបណ្ណាល័យហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បណ្ដាញស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន (CGTN) ពិភាក្សាជាមួយយុវជនកម្ពុជាអំពី

## ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីចិន ស៊ី ជីនពីង មកកាន់ប្រទេសកម្ពុជា នៅព្រះរាជបណ្ណាល័យហ្លួងម៉ែ

*សោម ប៊ុនថន*







បណ្ដាញស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន (CGTN) ពិភាក្សាជាមួយយុវជនកម្ពុជាអំពីដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីចិន ស៊ី ជីនពីង មកកាន់ប្រទេសកម្ពុជា នៅព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥ បណ្ដាញស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន (CGTN) បានរៀបចំកិច្ចពិភាក្សាជាមួយយុវជនកម្ពុជាអំពីដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីចិន ស៊ី ជីនពីង មកកាន់ប្រទេសកម្ពុជាក្នុងសប្ដាហ៍នេះ នៅព្រះរាជបណ្ណាល័យហ្លួងម៉ែ។ យុវជនកម្ពុជាដែលចូលរួមកម្មវិធីនេះមកពីវិស័យផ្សេងៗដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រុមហ៊ុនអចលនទ្រព្យ និងសាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា (Cam-Tech) ដែលមានអតីតនិស្សិតបានទៅសិក្សា និងបានធ្វើដំណើរទស្សនកិច្ចនៅប្រទេសចិន។

បន្ថែមលើដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីចិន ស៊ី ជីនពីង មកកាន់ប្រទេសកម្ពុជា កិច្ចពិភាក្សានេះក៏ផ្ដោតលើទស្សនរបស់យុវជនកម្ពុជាទាក់ទងនឹងការផ្លាស់ប្ដូរអន្តរវប្បធម៌ និងការអប់រំកម្ពុជា-ចិន, ទំនាក់ទំនងអន្តរជាតិរវាងកម្ពុជា និងចិន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងពាណិជ្ជកម្មនៅកម្ពុជា ដើម្បីរឹតចំណងមិត្តភាពកម្ពុជា-ចិន ឱ្យកាន់តែរឹងមាំទៅថ្ងៃអនាគត។

# វេទិកាពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ

**ឌីម សុខគា**







*សិស្សានុសិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ ចំនួន១០នាក់ ក្នុងនោះមានស្រី៥នាក់ បានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីចូលរួមវេទិកាអប់រំ និងពិភាក្សាប្រវត្តិសាស្ត្រខ្មែរក្រហម នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ សិស្សានុសិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ ចំនួន១០នាក់ ក្នុងនោះមានស្រី៥នាក់ បានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីចូលរួមវេទិកាអប់រំ និងពិភាក្សាប្រវត្តិសាស្ត្រខ្មែរក្រហម។ វេទិកានេះរៀបចំឡើងក្នុងគោលបំណងផ្តល់ជូនសិស្សានុសិស្សនូវចំណេះដឹង៖ ១) ការបញ្ជ្រាបចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្តោតលើការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ ២) តួនាទីភារកិច្ចរបស់យុវជនក្នុងការចូលរួមលើកកម្ពស់សិទ្ធិមនុស្ស ប្រឆាំងនឹងការរើសអើងក្រោយពេលបញ្ចប់សង្គ្រាម ដើម្បីរក្សាបាននូវសន្តិភាពនាពេលបច្ចុប្បន្ន។ ៣) កត្តាដែលនាំឱ្យកើតមានអំពើប្រល័យពូជសាសន៍ និង៤) វិធីសាស្ត្រសំខាន់ៗ ដែលយុវជនចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍។

ជាកិច្ចដំបូងនៃវេទិកាពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺសិស្សានុសិស្សទាំងអស់ត្រូវចំណាយពេល១៥នាទី ដើម្បីបំពេញកម្រងសំណួរវាស់ស្ទង់

ចំណេះដឹងដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានផ្តល់ឱ្យ។ នៅក្នុងកម្រងសំណួរ បានចែកចេញជាបីផ្នែក គឺផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហម ផ្នែកច្បាប់ ដែលទាក់ទងនឹងនិយមន័យ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រទប់ស្កាត់អំពើហិង្សា។

បន្ទាប់ពីបំពេញកម្រងសំណួររួច បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ឈ្មោះ ជឹម សុខគា បានទុកពេលឱ្យសិស្សានុសិស្សចំនួន១៥នាទីអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជា ដោយលើកយកមេរៀនក្នុងជំពូកទី៣ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ, ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ បន្ទាប់ពីសិស្សអានចប់ សុខគា បានពន្យល់បន្ថែមដោយលើកគោលការណ៍ទាំង៨ចំណុច មកពន្យល់ដល់សិស្ស។ គោលការណ៍ទាំងនោះរួមមាន៖ ទី១) ប្រជាជនចេញពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗ ទី២) លុបបំបាត់ទីផ្សារ ទី៣) លុបបំបាត់រូបិយប័ណ្ណ ៤) ចាប់ផ្សឹកព្រះសង្ឃឱ្យមកធ្វើស្រែចម្ការ ៥) សម្លាប់មេដឹកនាំក្នុងរបប លន់ នល់ ទី៦) បង្កើតសហករណ៍ជាន់ខ្ពស់ ទី៧) បណ្តេញជនជាតិវៀតណាមឱ្យចេញពីប្រទេស និងតាមព្រំដែន និងទី៨) បញ្ជូនកងទ័ពឱ្យទៅយាមល្បាតនៅតាមព្រំដែន។ បន្ថែមទៀត សុខគា បានពន្យល់ពីនិយមន័យនៃពាក្យ «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» និងកត្តាគ្រោះថ្នាក់មួយចំនួនដែលនាំដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

ចុងបញ្ចប់នៃវេទិកាពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សុខគា បានលើកយកប្រធានបទ «តួនាទីរបស់យុវជនក្នុងការចូលរួមលើកកម្ពស់សិទ្ធិមនុស្ស និងទប់ស្កាត់ការរើសអើងក្នុងសង្គម» មកពន្យល់ និងពិភាក្សាជាមួយសិស្ស។ លើសពីនេះ សុខគា ក៏បានបង្ហាញទៅកាន់សិស្សទាំងអស់ថា ដើម្បីចូលរួមលើកកម្ពស់សិទ្ធិមនុស្ស និងទប់ស្កាត់ការរើសអើងក្នុងសង្គមបាន លុះត្រាយុវជនទាំងអស់សិក្សាពីបរិបទប្រវត្តិសាស្ត្រកម្ពុជាឱ្យបានស៊ីជម្រៅ និងរិះរកវិធីសាស្ត្រដោះស្រាយ ដើម្បីលើកកម្ពស់សិទ្ធិ និងទប់ស្កាត់ការរើសអើង។ ដើម្បីជាជំនួយដល់ការត្រិះរិះរបស់សិស្ស សុខគា បានផ្តល់ឱកាសឱ្យសិស្សស្វែងយល់ពីសិទ្ធិរបស់ខ្លួន និងសិទ្ធិអ្នកដទៃទៀត។ ផលប៉ះពាល់នៃការរើសអើងនៅក្នុងសង្គមលើជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងអភិវឌ្ឍន៍ចំណេះដឹងផ្ទាល់ខ្លួន តាមរយៈការទប់ស្កាត់ការរើសអើង និងការលើកកម្ពស់សិទ្ធិមនុស្ស។

ការពិភាក្សាតួនាទីរបស់យុវជន សុខគា បានលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងការពិភាក្សាពីប្រធានបទ «ការកិច្ចយុវជនក្នុងការប្រឆាំងនឹងការរើសអើង និងការលើកកម្ពស់សិទ្ធិមនុស្ស» ដើម្បីសម្រេចតាមគោលបំណងដែលបានគ្រោងទុក សុខគា បានឱ្យសិស្សពិភាក្សាពីសំណួរមួយចំនួន និងបានចំណាយពេល២០នាទី សម្រាប់ឆ្លើយសំណួរ ជាលក្ខណៈផ្ទាល់ខ្លួន ដោយស្ងៀមស្ងាត់ ដោយប្រើប្រាស់សំណួរបំផុសដល់យុវជន ដូចខាងក្រោម៖

១) តើយុវជនមានសិទ្ធិអ្វីខ្លះ ដើម្បីរួមចំណែកទប់ស្កាត់អំពើប្រល័យសាសន៍?

២) តើយុវជនចូលរួមប្រើសិទ្ធិរបស់ខ្លួនបានយ៉ាងដូចម្តេច? និង

៣) តើយុវជនត្រូវធ្វើអ្វីខ្លះ ដើម្បីទប់ស្កាត់ការរើសអើង និងការលើកកម្ពស់សិទ្ធិមនុស្ស?

ការពិភាក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរយៈពេលមួយព្រឹកពេញនេះ បានផ្តល់ចំណេះដឹងយ៉ាងច្រើនដល់សិស្សានុសិស្ស ហើយថែមទាំងបានឆ្លុះបញ្ចាំងឱ្យឃើញពីគំនិតផ្ទាល់ខ្លួនរបស់សិស្សានុសិស្សស្វែងយល់ពីការកិច្ចរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍សង្គម ដើម្បីទទួលបានសន្តិភាព និងស្ថិរភាពក្រោយពេលបញ្ចប់សង្គ្រាម។ ការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រ គឺជាគោលដៅមួយជំរុញយុវជនឱ្យចូលរួមក្នុងសកម្មភាពសង្គម ក្នុងការរិះរកមធ្យោបាយឬវិធីសាស្ត្រនានា ដើម្បីលុបបំបាត់ការរើសអើងលើសិទ្ធិមនុស្ស។ នេះបញ្ជាក់ឱ្យឃើញថា យុវជនបានរួមចំណែកយ៉ាងសំខាន់បំផុតដែលធ្វើឱ្យសង្គមជាតិទទួលបានសន្តិភាព ដែលបង្ហាញឱ្យឃើញពីការតាំងចិត្តខ្ពស់ក្នុងការរារាំង និងទប់ស្កាត់នៃការវិលត្រឡប់នៃអំពើប្រល័យពូជសាសន៍នាពេលអនាគត។

# សិស្សានុសិស្សនៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលដង្ហារ ធ្វើទស្សនកិច្ចសិក្សាអំពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅផ្ទះសហគមន៍ ភូមិក្តុលលើ ឬ សាលាគរុកណ្ឌាស្លៀង

ឈុំ រ៉ា





សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលដង្ហារ ទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ភូមិក្តុលលើ ឬសាលាគរុកណ្ឌាស្លៀង ក្នុងគោលបំណងទស្សនាផ្ទាំងពិព័រណ៍ និងសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលដង្ហារ ចំនួន៨នាក់ ក្នុងនោះមានយុវតីចំនួន៤នាក់ បានធ្វើដំណើរមកកាន់ផ្ទះសហគមន៍ភូមិក្តុលលើ ឬសាលាគរុកណ្ឌាស្លៀង ក្នុងគោលបំណងទស្សនាផ្ទាំងពិព័រណ៍ និងសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បន្ថែមពីលើការសិក្សានៅឯថ្នាក់រៀន។

ជាកិច្ចចាប់ផ្តើមលោក ឈុំ រ៉ា បុគ្គលិកប្រចាំការនៃមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើការដឹកនាំសិស្សា-នុសិស្សទស្សនាផ្ទះសហគមន៍ភូមិក្តុលលើ ណែនាំពីអត្ថន័យនៃផ្ទាំងពិព័រណ៍ចំនួនបួនផ្ទាំងរួមមាន៖ ផ្ទាំងពិព័រណ៍ទី១) បង្ហាញពីចំណុចចាប់ផ្តើម ដែលសម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូប បានចាកចេញពីកោះថ្មនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីឆ្ពោះទៅរកការកសាងកងកម្លាំងប្រដាប់អាវុធសាមគ្គី

សង្គ្រោះជាតិកម្ពុជា វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត។ ផ្ទាំងពិព័រណ៍ទី២) បានបង្ហាញអំពីដំណើរការស្វែងរកសន្តិភាពរវាងភាគីខ្មែរ និងខ្មែរ។ ផ្ទាំងពិព័រណ៍ទី៣) សន្តិភាពដោយកម្រ គឺការអនុវត្តយុទ្ធសាស្ត្រគន្លឹះរបស់សម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមដោយអនុវត្ត «នយោបាយ ឈ្នះ ឈ្នះ» ហើយនៅឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ដាក់ក្រុមខ្មែរក្រហមឱ្យនៅក្រៅច្បាប់ និងផ្ទាំងពិព័រណ៍ទី៤) បន្ទាប់ពីទទួលបានសន្តិភាពពេញលេញនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ កងយោធពលខេមរភូមិន្ទបានបំពេញតួនាទីដ៏ឧត្តុង្គឧត្តម សម្រាប់ជាតិ និងអន្តរជាតិ។

បន្ទាប់មកលោក ឈុំ វ៉ា ដឹកនាំសិស្សានុសិស្សទៅទស្សនាផ្ទាំងពិព័រណ៍ធំៗចំនួនពីរទៀត ដែលតាំងបង្ហាញនៅបរិវេណខាងក្រៅនៃផ្ទះសហគមន៍ភូមិក្តុលលើ គឺ៖១) ខ្មែរក្រហមវាយឈ្នះលើរបប លន់ នល់ ហើយចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ២) ការធ្វើដំណើរវិលត្រឡប់របស់ប្រជាជនទៅកាន់កន្លែងកំណើតបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់មកទៀតលោក ឈុំ វ៉ា ឱ្យសិស្សានុសិស្សធ្វើកិច្ចការពិភាក្សាជាក្រុមលើប្រធានបទ ចំនួនពីរគឺ ការរំលោភលើសិទ្ធិ និងពលកម្មរបស់កុមារ និងការបង្ខំឱ្យធ្វើការជាទម្ងន់។ ដោយមានការបែងចែកជាក្រុមដូចជា៖

**ក្រុមទី១៖** មានសមាជិកក្រុមចំនួនបួននាក់គឺឈ្មោះ ថុន ស្រីធី, នឿន លីលី, ណិត ណែត និង ចិប ពេជ្រ ពិភាក្សាលើប្រធានបទ ការរំលោភលើសិទ្ធិ និងពលកម្មរបស់កុមារ។ ក្រោយការពិភាក្សា សមាជិកក្រុមបានលើកឡើងថា៖ កុមារទាំងឡាយត្រូវបានបង្ហាត់បង្រៀនថា «អង្គការជាមាតាបិតារបស់កុមារាកុមារីនិងយុវជនយុវនារី។ បើម៉ែឪវាយកូន មានន័យថា មើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ»។ កម្មាភិបាលខ្មែរក្រហម បានឱ្យកុមារស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយជួនកាលកុមារទាំងនោះហ៊ានសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនទៀតផង ប្រសិនបើទទួលបានបញ្ជាពីអង្គការ។ ក្នុងរយៈកាលកន្លងផុតទៅ កុមាររាប់ម៉ឺននាក់បានជឿទៅលើអ្វីដែលអង្គការបានប្រាប់ ហើយគោរពតាមតែបញ្ជារបស់អង្គការ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ ទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ភូមិក្តុលលើ ឃុំសាលាគរុភណ្ឌ ស្ទឿង ក្នុងគោលបំណងទស្សនាផ្ទាំងពិព័រណ៍ និងសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មិនមានសាលារៀនជាផ្លូវការឡើយ។ កុមារត្រូវបានបញ្ជូនឱ្យទៅរៀននៅក្រោមដើមឈើ ឬនៅក្រោមផ្ទះប្រជាជន។ គ្រូភាគច្រើន គឺជាកសិករក្រីក្រដែលអាចអាននិងសរសេរបានតែបន្តិចបន្តួចប៉ុណ្ណោះ។ ទោះបីជាការអប់រំនៅតាមតំបន់មួយចំនួន មានការរីកចម្រើនក្នុងឆ្នាំ១៩៧៨ (កុមារទទួលបានការសិក្សាថ្នាក់បឋម ពី២ទៅ៣ម៉ោងក្នុងមួយថ្ងៃ) ក៏ដោយ នៅតែមិនទាន់មានសាលារៀនដែលមានដំណើរការពេញលេញសម្រាប់សិក្សាដែរ។ ខ្មែរក្រហមនិយាយថា «អង្គការគ្មានទេសញ្ញាបត្រ គឺមានតែសញ្ញាឃើញ។ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ» ហើយថា «ការរៀនអក្សរ រៀនលេខ មិនសំខាន់ទេ ការសំខាន់គឺការងារ និងចលនាបដិវត្តន៍»។ ក្នុងអំឡុងពេលសង្គ្រាមជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧-១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ ឬរងរបួសជាទម្ងន់។ ហេតុនេះអង្គការបានបញ្ជូនកុមារឱ្យទៅសមរភូមិមុខ ដែលនៅទីនោះ កុមាររាប់ពាន់នាក់ត្រូវរងរបួស និងស្លាប់។ ក្មេងៗត្រូវបានជ្រើសរើសឱ្យទៅចូលរួមវគ្គហ្វឹកហ្វឺនមនោគមវិជ្ជា ដើម្បីអាចបម្រើក្នុងជួរកងទ័ព កងការពារ ឬនីរសារបាន។ ក្មេងៗក៏ត្រូវបានចាត់តាំងឱ្យធ្វើការងារដែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការងាររបស់កុមារ គឺដើររើសអាចម៍គោ កាត់ទន្ទ្រានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជី និងជញ្ជូនអាវុធទៅសមរភូមិ ដែលនៅទីនោះ កុមារជួនកាលទទួលរងរបួស ឬក៏ត្រូវគ្រាប់កាំភ្លើងស្លាប់ក៏មាន។ ជាងនេះទៅទៀត កុមារាកុមារីទាំងនោះត្រូវបំបែកចេញពីឪពុកម្តាយ ហើយមិនដែលស្គាល់ភាពកក់ក្តៅក្នុងគ្រួសារឡើយ។

**ក្រុមទី២៖** មានសមាជិកក្រុមចំនួនបួននាក់គឺឈ្មោះ, ញ៉ាក់ សុខឡាន, កា៉រ រចនា, នឿន ស៊ីណា និងភ័ក្រ្ត យ៉ូរ៉ា ពិភាក្សាលើប្រធានបទ ការបង្ខំឱ្យធ្វើការជាទម្ងន់។ ក្រោយការពិភាក្សា សមាជិកក្រុមបានលើកឡើងថា៖ ប្រជាជនគ្រប់រូបត្រូវអង្គការបង្ខំឱ្យធ្វើការជាទម្ងន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កុមារត្រូវប្រើឱ្យធ្វើការងារស្រាលៗ, មនុស្សចាស់ៗត្រូវទទួលតួនាទីមើលថែទាំកុមារតូចៗនិងសត្វពាហនៈ ព្រមទាំងត្បាញកន្ត្រៃង និងល្អីជាដើម។ ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ (កុមារវ័យជំទង់) ត្រូវទទួលការងារធ្ងន់ៗ និងលំបាកព្រោះត្រូវធ្វើការតាំងពីព្រលឹមស្រាងៗ រហូតដល់ពាក់កណ្តាលយប់ទើបឈប់សម្រាក។ ប្រជាជនស្ទើរគ្រប់រូប ធ្វើការច្រើនជាង១២ម៉ោងក្នុងមួយថ្ងៃ ដោយគ្មានពេលឈប់សម្រាក ឬទទួលទានអាហារបានគ្រប់គ្រាន់។

ដំណើរទស្សនកិច្ចនៅថ្ងៃនេះ ធ្វើឱ្យសិស្សានុសិស្សមានចំណេះទាក់ទងនឹងរបបខ្មែរក្រហមកាន់តែច្រើន បន្ទាប់ពីការសិក្សានៅក្នុងថ្នាក់រៀន។





សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ ទស្សនកិច្ចសិក្សានៅផ្ទះសហគមន៍ភូមិក្តុលលើ ឬសាលាគរុកណ្ឌស្មៀង ក្នុងគោលបំណងទស្សនាផ្ទាំងពិព័រណ៍ និងសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លោកអភិបាលនៃគណៈអភិបាលស្រុក និង មន្ត្រីរដ្ឋបាលស្រុក បរិច្ចាគសៀវភៅជូន

## «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់សាធារណជនក្នុងការសិក្សាស្រាវជ្រាវ

**ស្រេង លីដា**



*លោក លី មីណា អភិបាលស្រុកបុរីអូរស្វាយ-សែនជ័យ (រូបកណ្តាល) ប្រគល់សៀវភៅជូនលោក ស្រេង លីដា បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*






នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥, លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយ -សែនជ័យ និងមន្ត្រីរដ្ឋបាលស្រុក បានបរិច្ចាគសៀវភៅចំនួន៨ក្បាល ជូន «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» ដែលជាសាខាមួយរបស់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង ដើម្បីរក្សាទុកនៅបណ្ណាល័យដែលជាទីកន្លែងផ្តល់ធនធានចំណេះដឹងដ៏សម្បូរបែប រួមមាន៖ សៀវភៅប្រវត្តិសាស្ត្រ, សៀវភៅប្រលោមលោក, សៀវភៅទស្សនវិជ្ជា, សៀវភៅសម្រាប់កុមារ និងភូមិវិទ្យា។ ការបរិច្ចាគសៀវភៅ ទាំងនេះ គឺជាការចូលរួមចំណែកគាំទ្រដល់បេសកកម្ម ក៏ដូចជាគោលបំណង

របស់ «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» នៃព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការជំរុញឱ្យមានការអានសៀវភៅ និងបង្កើនចំណេះដឹងរបស់សិស្សានុសិស្ស, គ្រូបង្រៀន, អ្នកសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋទូទៅនៅមូលដ្ឋានស្រុកបុរីអូរស្វាយ-សែនជ័យ និងខេត្តស្ទឹងត្រែង។ សៀវភៅដែលអភិបាលនៃគណៈអភិបាលស្រុកបានប្រគល់ជូន មានដូចជា៖

ទី១) សៀវភៅ៖ «សម្តេច ហ៊ុន សែន៖ ពាយន្តការឈ្នះកូវីដ-១៩»

ទី២) សៀវភៅ៖ «អ្នកយុទ្ធសាស្ត្រវ័យក្មេងនៅអាស៊ី (ភាគ ១)»

ទី៣) សៀវភៅ៖ «កូនប្រុសច្បងដ៏មានឥទ្ធិពល»

ទី៤) សៀវភៅ៖ «សម្តេចតេជោ ហ៊ុន សែន៖ អ្នកគូសវាសជោគវាសនាកម្ពុជា»

នៅក្នុងចំណោមសៀវភៅទាំងនោះ មានឯកសារសៀវភៅប្រវត្តិសាស្ត្រសំខាន់ៗ ដូចខាងក្រោម៖

ទី៥) សៀវភៅ៖ «NORODOM SIHANOUK PHOTOS-SOUVENIRS de mon CAMBODGE (ANNÉES 60)»

ទី៦) សៀវភៅ៖ «ពិធីថ្វាយគ្រឿងឥស្សរិយយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តម «មិត្តភាពនៃសាធារណរដ្ឋប្រជាមានិតចិន» ថ្វាយសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គល នៃព្រះរាជាណាចក្រកម្ពុជា (បានប្រព្រឹត្តទៅឡើងនៅទីក្រុងប៉េកាំង ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០២០)»

ទី៧) សៀវភៅ៖ «ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ ៧០ យាងចូល ៧១ ព្រះវស្សា ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដែលបានប្រារព្ធឡើងក្នុងថ្ងៃសៅរ៍ ៩ រោច និងថ្ងៃអាទិត្យ ១០ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ (កាលពីថ្ងៃទី ១៣-១៤ ខែឧសភា ឆ្នាំ ២០២៣)»

ទី៨) សៀវភៅ៖ «ព្រះរាជពិធីបុណ្យខួប ១០០ ព្រះវស្សានៃការប្រសូត (១៩២២-២០២២) និងព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធខួបឆ្នាំទី ១០ នៃការយាងចូលព្រះទិវង្គត (២០១២-២០២២) ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ»

លោកអភិបាលនៃគណៈអភិបាលស្រុក មានប្រសាសន៍ថា៖ «ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងក្តីរំភើបក្នុងការនាំយកសៀវភៅសរុបចំនួន៨ប្រភេទផ្សេងៗគ្នា ដែលសៀវភៅ៤ក្បាល ខ្ញុំបានទទួលផ្ទាល់ព្រះហស្តពីហ្វូងម៉ៃ និងសៀវភៅ៤ក្បាលទៀត ខ្ញុំទទួលបានពីប្រធានសមាគមអ្នកនិពន្ធខ្មែរ, មករក្សាទុកនៅ «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» នៃព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់សាធារណជនក្នុងការសិក្សាស្រាវជ្រាវបន្ត»។

ក្រុមការងារនៃ«អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកអភិបាលនៃគណៈអភិបាលស្រុក និងមន្ត្រីរដ្ឋបាលស្រុក ចំពោះចិត្តដ៏សប្បុរសក្នុងការបរិច្ចាគសៀវភៅ ដើម្បីលើកកម្ពស់ស្មារតីពលរដ្ឋក្នុងការអាន និងសិក្សាស្រាវជ្រាវ បង្កើនចំណេះដឹង និងបំផុសគំនិតចូលរួមអភិវឌ្ឍន៍សហគមន៍។

# ការិយាល័យព័ត៌មានសាធារណៈ





«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។






តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org







សូមអរគុណ!

# គ្មាននិស្ស័យជាមួយកូនចិញ្ចឹមទាំងពីរនាក់

**ស្រ៊ាង លីហ្វួរ**

គង់ ស៊ីម ភេទប្រុស អាយុ៥២ឆ្នាំ (២០០៨) កើតក្នុងឆ្នាំ១៩៥៦ នៅភូមិដំណាក់ត្រាច ឃុំទួលអំពិល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងបច្ចុប្បន្នរស់នៅភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ស៊ីម មានប្រពន្ធឈ្មោះ អ៊ុន ទឹម អាយុ ៥២ឆ្នាំ (២០០៨) មកពីភូមិត្រពាំងជ្រៃ។ អ្នកទាំងពីរមានកូនប្រាំពីរនាក់ ក្នុងនោះស្រីបីនាក់។ ស៊ីម គឺជាអតីតពេទ្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសព្វថ្ងៃជាជំទប់ទី១ឃុំបឹងរាំង។

នៅដើមឆ្នាំ១៩៧០ ស៊ីម រៀនត្រឹមថ្នាក់ទី៩ (សន្ដមចាស់)។ នៅខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ស៊ីម បានឈប់រៀន និងត្រឡប់ទៅរស់នៅជាមួយឪពុកម្ដាយ។ នៅឆ្នាំ១៩៧២ ស៊ីម ទើបមានអាយុប្រហែលជា១៦ឆ្នាំ បានស្ម័គ្រចិត្តចូលធ្វើជាកងឈ្លបដោយសារបញ្ហាជីវភាព។ បន្ទាប់មក ស៊ីម បានធ្វើជាកងតំបន់៥៣ ខេត្តកំពង់ស្ពឺរហូតដល់ឆ្នាំ១៩៧៥។

នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមដណ្ដើមបានទីក្រុងភ្នំពេញ។ បន្ទាប់ពីឡើងកាន់អំណាច ខ្មែរក្រហមចាប់ផ្ដើមស្រាវជ្រាវ និងឱ្យ ស៊ីម ធ្វើប្រវត្តិរូប។ ខ្មែរក្រហមបានរកឃើញថា ស៊ីម មានជាប់និន្នាការជាមួយឪពុកមា និងម្ដាយមីងដែលធ្លាប់ធ្វើជាទាហានលន់ នល់ និងដោយសារ ស៊ីម ស្នើសុំចូលធ្វើកងចល័ត ដើម្បីបានទៅនៅជិតឪពុកម្ដាយ ដូច្នេះ អង្គការខ្មែរក្រហម បានដក ស៊ីម ចេញពីខាងយោធាឱ្យទៅធ្វើការតាមកងចល័តនៅភូមិកំណើត ដោយត្រូវគ្រប់គ្រងកងចល័តកុមារ ដែលមានអាយុចាប់ពី១៥ឆ្នាំ ឡើង។ ស៊ីមបានធ្វើជាប្រធានកងចល័តកុមារតាមឃុំ ដោយត្រូវដឹកនាំកងចល័តកុមារប្រមាណ៣០នាក់ ដើរបើកទ្វារប្រឡាយទឹក ដើម្បីបង្ហូរទឹកចូលស្រែប្រាំង និងដើររែកដីដំបូក រែកដីលាមកគោ និងបាចដី។ កងចល័តកុមារ គឺហូបបាយតាមរោងកាស៊ីនបាយ។ ដោយសារការហូបចុកមិនគ្រប់គ្រាន់ ស៊ីម និងកងចល័តកុមារ ដើររកក្ដាមស្រែ និងខ្យងស្រែហូប នៅពេលកំពុងធ្វើការ។ ស៊ីម ត្រូវធ្វើការក្រោមបញ្ជាប្រធានកងរយ ឬកងវរ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈឃុំ។ នៅឆ្នាំ១៩៧៧ ស៊ីម បានធ្លាក់ខ្លួនឈឺ និងទៅសម្រាកនៅពេទ្យឃុំមួយរយៈ។ នៅពេលនោះ អង្គការក៏ចាត់តាំង ស៊ីមឱ្យរៀនពេទ្យ និងធ្វើជាពេទ្យឃុំ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានរៀបចំឱ្យ ស៊ីម ដែលមានអាយុប្រហែល២១ឆ្នាំ រៀបការដោយគ្មានការដឹងឮពីឪពុកម្ដាយ។ ស៊ីម និយាយថា ខ្លួនមិនដែលស្គាល់ប្រពន្ធរបស់ខ្លួនពីមុនមកនោះទេ អង្គការជាអ្នកចាត់តាំង និងតម្រូវឱ្យមានគ្រួសារ។ ថ្ងៃដែល ស៊ីម រៀបការ គឺមានរហូតទៅដល់ ៣៦គូ ដោយឈរចាប់ដៃគ្នា និងភាគច្រើនជាសមាជិកកងចល័ត។ ក្រោយមកទៀត ខ្មែរក្រហមរៀបចំឱ្យមានការរៀបការម្ដង ៦០ទៅ១០០គូក្នុងពេលតែមួយ ដោយខាងកងចល័តត្រូវរៀបការជាមួយកងចល័តនារី និងខាងយោធាត្រូវរៀបការជាមួយ ខាងយោធានារី។ នៅពេលរៀបការ គឺមានការចូលរួមពីគណៈឃុំ ឈ្មោះ តា ខាន់ និងគណៈស្រុកគងពិសី ឈ្មោះ តាឆែល និងតាពែល ទីតាំងរៀបការនៅក្នុងវត្តមួយកន្លែង។

បន្ទាប់ពីរៀបការ និងសម្រាកនៅវត្តនោះបានមួយយប់។ ស្អែកឡើង គណៈឃុំបានបញ្ជូនអ្នកដែលទើបតែរៀបការទាំង៣៦គូ រួមទាំងអ្នកមកពីខេត្តកំពតអ្នកខេត្តតាកែវទៅប្រជុំនិងរៀននៅត្រង់កន្លែងវង់មូលផ្សារចាស់ទីរួមខេត្តតាកែវ។ ការប្រជុំនោះមានការចូលរួមដោយផ្ទាល់ពីតាម៉ុក លេខាភូមិភាគនិរតី។ នៅពេលប្រជុំដែលមានរយៈពេលពីរថ្ងៃ តាម៉ុក ប្រាប់ថា នៅខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ គឺសម្បូរទៅដោយខ្មាំង ដោយខ្មាំងមួយចំនួនធ្លាប់ធ្វើជាយោធា។ តាម៉ុក បាននិយាយសំដៅទៅលើខ្មាំងបះបោរ

ខ្មែរសប្តុខ្មែរសេរីៗ ស៊ឹម បន្តថា អ្នកដែលត្រូវបញ្ជូនទៅបាត់ដំបង គឺត្រូវប្រុងប្រយ័ត្នមិនឱ្យមានការថ្នោះធ្លោយជាពិសេសរឿងសីលធម៌ ដោយសារនៅខេត្តបាត់ដំបងសម្បូរទៅដោយស្រីស្អាត ដូច្នេះទើបអង្គការចាត់ចែងឱ្យមានគ្រួសារ មុនពេលបញ្ជូនទៅៗ

បន្ទាប់ពីប្រជុំចប់ ខ្មែរក្រហមបានបញ្ជូន ស៊ឹម និងប្រជាជនជាច្រើនរយនាក់ធ្វើដំណើរទៅខេត្តបាត់ដំបងតាមផ្លូវរថភ្លើង អស់រយៈពេលមួយយប់មួយថ្ងៃៗ នៅពេលទៅដល់ខេត្តបាត់ដំបង គឺមានការប្រជុំនៅកន្លែងសកលវិទ្យាល័យ ខាងអន្លង់វិលៗ នៅពេលប្រជុំ ស៊ឹម ថាបានឃើញ តាម៉ុក និង តាញឹម ចាប់ដៃគ្នាៗ ស៊ឹម និយាយថា តាម៉ុក និងតាញឹម ជាមិត្តនឹងគ្នាតាំងពីពេលតស៊ូនៅក្នុងព្រៃៗ ក្រោយពីការប្រជុំនៅអន្លង់វិល ខ្មែរក្រហមក៏ដឹក ស៊ឹម និងអ្នកឯទៀតបន្តទៅប្រជុំនៅភ្នំសំពៅៗ បន្ទាប់ពីការប្រជុំរួចខ្មែរក្រហមបានដឹក ស៊ឹម និងអ្នកដែលមកពីភូមិភាគនិរតីទៅធ្វើការនៅស្រុកដូនទាវ ខ្លះទៅធ្វើការនៅស្រុកឯកភ្នំដោយត្រូវធ្វើការតាមតួនាទីរៀងៗខ្លួនដដែលៗ ចំណែក ស៊ឹម បន្តធ្វើពេទ្យនិងតាមដាន ប្រធានពេទ្យ និងអនុប្រធានពេទ្យនៅមន្ទីរពេទ្យស្រុក ដែលស្ថិតនៅចម្ងាយប្រហែលប្រាំមួយគីឡូពីសហករណ៍ព្រៃទទឹង ដែលសព្វថ្ងៃហៅថា ថ្មគោលៗ

ក្រោយពីធ្វើការនៅមន្ទីរពេទ្យនោះបានបីខែ ស៊ឹម និយាយថា កម្មាភិបាលភូមិភាគពាយ័ព្យជាច្រើននាក់ត្រូវបានចាប់ខ្លួន និងមួយឆ្នាំក្រោយមក ទើបមានការចាប់ខ្លួន រស់ ញឹម លេខាភូមិភាគពាយ័ព្យៗ បន្ទាប់ពីចាប់ខ្លួន រស់ ញឹម រួច តាម៉ុក បាននាំកម្លាំងមកពីស្រែអំបិល និងកំពង់សោមបន្ថែមទៀតៗ ប្រធានតំបន់៤ ឈ្មោះតាវង្ស រួមទាំងប្រធានពេទ្យ អនុប្រធានពេទ្យ សមាជិកពេទ្យ ត្រូវបានយោធាភូមិនិរតីចាប់ខ្លួនទាំងអស់ៗ ដូច្នេះ ស៊ឹម និងប្រពន្ធគឺត្រូវគ្រប់គ្រងមន្ទីរពេទ្យប្រមាណបីខែ រហូតដល់កងទ័ពវៀតណាមចូលមកៗ

នៅព្រឹកមួយ នាខែកក្កដា ឆ្នាំ១៩៧៨ មានមីងម្នាក់ឈ្មោះ ម៉ាន់ ដែលប្តីឈ្មោះ ណុល អតីតប្រធានសហករណ៍ព្រៃទទឹងមកជួបគាត់ៗ មីងម៉ាន់គឺជាអ្នកមកពីខាងស្វាយចិប ខេត្តកំពង់ស្ពឺ ដែល ស៊ឹម ស្គាល់នៅពេលបញ្ជូនមកខេត្តបាត់ដំបងជាមួយគ្នាៗ នៅព្រឹកនោះ មីងម៉ាន់បានមកសុំថ្នាំ និងប្រាប់ឱ្យ ស៊ឹម យកកុមារីកំព្រាម្នាក់ទៅចិញ្ចឹមៗ កុមារីនោះមានឈ្មោះ ភឿន ដែលមានអាយុប្រហែល៥ឆ្នាំៗ ឪពុករបស់កុមារីនេះ បានស្លាប់តាំងពីពេលកុមារីនេះមិនទាន់កើតៗ ចំណែកម្តាយរបស់កុមារីនេះ ត្រូវបានបងរបស់ ស៊ឹម វាយសម្លាប់ទាំងមានផ្ទៃពោះពីយប់ម្សិលមិញ ដោយសារធ្វើខុសសីលធម៌ជាមួយពោះម៉ាយម្នាក់ដែលធ្វើការនៅកងចល័តជាមួយគ្នាៗ ស្របពេលនោះ កូនស្រីបង្កើតរបស់ ស៊ឹម ដែលមានអាយុបីខែ កំពុងមានជំងឺ ដោយមានអាការក្រហមរងាលៗ ប្រពន្ធរបស់ ស៊ឹមបានតឿនឱ្យ ស៊ឹម ទៅយកកុមារីនោះមកចិញ្ចឹមៗ ដោយសារការអាណិត ស៊ឹម ក៏បានជិះកង់ទៅដឹកកុមារីនោះមកចិញ្ចឹមដូចជាកូនបង្កើតៗ នៅពេលឃើញកុមារីនោះ ស៊ឹម បានយំដោយសារដឹងអំពីរឿងរ៉ាវដ៏កំសត់របស់ឪពុកម្តាយរបស់កុមារីរូបនេះៗ

នៅខែឆ្នាំដដែល យោធានិរតីដែល តាម៉ុក បញ្ជូនមកនៅពេលក្រោយ បានចោទ ស៊ឹម ថាក្បត់ ដូច្នេះស៊ឹម បានគេចចេញពីពេទ្យទៅនៅសហករណ៍ចិនដាំស្ពៃៗ នៅពេលកងទ័ពវៀតណាមចូលមកដល់ខេត្តបាត់ដំបងនៅឆ្នាំ១៩៧៩ ស៊ឹម និងប្រពន្ធកូនបានរត់គេចខ្លួនៗ នៅពេលកំពុងធ្វើដំណើរ ស៊ឹម បានឃើញកុមារីកំព្រាម្នាក់ទៀត ដែលកំពុងយំតាមផ្លូវៗ ស៊ឹម និយាយថា គាត់បានទៅសួរនាំកុមារីនោះ អំពីឪពុកម្តាយៗ កុមារីនោះ ឆ្លើយថា៖ «ខ្ញុំអត់មានម៉ែឪទេ ម៉ែឪខ្ញុំមិនដឹងទៅណាអស់ទេមិនដែលឃើញមុខទេ»ៗ កុមារីនោះ ឈ្មោះ រីមានអាយុ ១០ឆ្នាំ ដែលធ្លាប់ស្គាល់ ភឿន ពីមុនមកៗ ស៊ឹម ក៏យកកូនកំព្រាទាំងពីរនាក់នេះរត់គេចកាត់ព្រៃ កាត់ស្ទឹងទាំងលំបាកទៅខាងចក្រី រហូតដល់បារាំងធ្លាក់ នៅតំបន់ជួរព្រំដែន ហើយរស់នៅទីនោះអស់រយៈពេលជាងបួនខែៗ

បន្ទាប់ពីរស់នៅទីនោះ ខ្មែរក្រហមក៏បញ្ជូន ស៊ឹម និងប្រពន្ធកូនទៅជំរំនៅខាងសំពៅលូន នៅជិតព្រំដែនៗ ខ្មែរក្រហមបានចែកអាវុធឱ្យ ស៊ឹម ធ្វើជាកងទ័ពជួរមុខ ចំណែកប្រពន្ធចិញ្ចឹមកូនបង្កើតម្នាក់ និងកូនចិញ្ចឹមពីរនាក់ៗ ក្រោយមកនៅខែតុលា ឆ្នាំ១៩៧៩ ស៊ឹម បានសុំមេមកមើលកូន ពីព្រោះកូនឈឺៗ នៅពេលនោះ ស៊ឹម បានត្រឡប់មកធ្វើការនៅម្តុំបារាំងធ្លាក់វិញ ខ្មែរក្រហមឱ្យ ស៊ឹម គ្រប់គ្រងអង្គភាពប្រជាជនជាង១០គ្រួសារៗ ដោយសារគ្មានអង្ករហូបគ្រប់គ្រាន់ស៊ឹមក៏សម្រេចចិត្តទៅរកស៊ីនៅប្រទេសថៃ ដោយធ្វើជាអ្នកដើរ

កាច់ពោត បានមួយបាវប្រាំបាត។ ក្នុងមួយថ្ងៃ ស៊ឹម ទទួលបានបាយ និងលុយប្រហែលជា៣០បាត ដើម្បីទិញអង្ករមួយគី ឡូទុកឱ្យកូនៗហូប។

ពីរខែក្រោយមក មានខាងអង្គការកាកបាទក្រហមអន្តរជាតិ និងខាងយូអិន (អង្គការសហប្រជាជាតិ) បាននាំស៊ឹម និងប្រពន្ធកូនទៅរស់នៅជំរំស្រះកែវ។ នៅពេលនោះ ក្នុងមនុស្សម្នាក់ ទទួលបានបបរមួយកំប៉ុងទឹកដោះគោ។ កូនចិញ្ចឹម ទាំងពីរនាក់នោះ បានទៅនៅជំរំកុមារកំព្រា និងធ្លាប់មកលេងគាត់តែមួយដងប៉ុណ្ណោះ។ បន្ទាប់ពីរស់នៅជំរំអស់រយៈពេលបីខែ នៅឆ្នាំ១៩៨០ អង្គការចាប់ផ្តើមប្រកាសជ្រើសរើសអ្នកស្ម័គ្រចិត្តទៅរស់នៅ ខាងឃុំបឹងបេង ស្រុកសំពៅលូនវិញ ឬក៏បន្តទៅរស់នៅជំរំខាវ-អ៊ីដាង ជំរំខាត់ព្រិច និងជំរំគោកធ្យូងពីរ។ ស៊ឹម និងប្រពន្ធកូនបង្កើតក៏សម្រេចចិត្តត្រឡប់មកប្រទេសកម្ពុជាវិញ ចំណែកកូនចិញ្ចឹម ទាំងពីរ មិនបានត្រឡប់មកជាមួយ ស៊ឹម នោះទេ។ ស៊ឹម និងប្រពន្ធបានបែកកូនចិញ្ចឹម ទាំងពីរនាក់នៅជំរំស្រះកែវតាំងពីពេលនោះមក។ ស៊ឹម និយាយថា គាត់និងប្រពន្ធនៅតែនឹក និងចង់ជួបកូនចិញ្ចឹម ទាំងពីរនាក់នោះ។



ក្រុមគ្រួសាររបស់នារីសិល្បៈខ្មែរក្រហមថតរូបជួបជុំគ្នា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖
កងទ័ពបដិវត្តន៍ខ្មែរក្រហមជិះលើរថពាសដែក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
ប្រជាជនកម្ពុជាធ្វើដំណើរលើស្ពានដែកខេត្តកំពតវិលត្រឡប់មកស្រុកកំណើតវិញ
បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 304, April 2025

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.